ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Jul-2012, 15:52
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២**

**ម៉ោង ០៩:០៣ នាទី**

**សវនាការលើកទី៨៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វ៉ីស៊ែល រីស៊ើ
*(Ms. Natacha WEXELS-RISER)*

លោក អេនឌ្រូ ចេមស៍ ម៉ាគីនថាយអ៊ែរ
*(Mr. Andrew James MCINTYRE)*

លោក ស៊ីម៉ុន មេសិនប៊ឺដ
*(Mr. Simon MEISENBERG)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក សាលីម ណាកចាវ៉ានី

*( Mr. Salim NAKHJAVANI )*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ហ្សាស្តើ ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក ដេវីដ ឆេនដ័ល័រ (TCE-11) | អង់គ្លេស |
| លោក រ៉ចាម តុន ហៅ ភី ភួន (TCW-564) | ខ្មែរ |

## ខ្លឹមសារ

**ការសួរសំណួរទៅអ្នកជំនាញ៖ លោក ដេវីដ ឆេនដ្លើរ (TCE-11)**

សួរដោយលោក អាកទួរ វែកគែន ផ្តើមពី៖ ....................................................................ទំព័រ ៣

**ការសួរសំណួរទៅសាក្សី៖ លោក វ៉ោម តុន ហៅ តី តួន (TCW-564)**

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី៖ ....................................................................ទំព័រ៤៤

សួរដោយលោក សេង ប៊ុនឃាង ផ្តើមពី៖ ....................................................................ទំព័រ៥១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅព្រឹកនេះ អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មរបស់អ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ដែលនឹងបន្តការតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន។ ហើយមុននឹងផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន។

លោកស្រី សេ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តនាម ភាគី និងបុគ្គលដែលអង្គជំនុំជម្រះអញ្ជើញ -- កោះអញ្ជើញ ឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

សូមអញ្ជើញ!

[០៩:០៤:០៣]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្ដីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះ។ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ ក្នុងការចូលរួមដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់រយៈពេលពេញមួយថ្ងៃនៃថ្ងៃសវនាការនេះ។

លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ចំណែកឯសាក្សីដែលអង្គជំនុំជម្រះបានកោះហៅមកផ្ដល់សក្ខីកម្មបន្ទាប់ពីបញ្ចប់សក្ខីកម្មអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ គឺសាក្សីដែលមានរហស្សនាមTCW-564។ សាក្សីរូបនេះនឹងមានវត្តមាននៅបន្ទប់រង់ចាំនៅម៉ោងដប់មួយ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលបានទទួលស្គាល់នោះទេ។

សាក្សីបានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែករួចហើយ កាលពីថ្ងៃ២៤ ខែកក្កដា២០១២។ មេធាវីប្រឹក្សារបស់សាក្សីរូបនេះ ឈ្មោះលោកមេធាវី លឹម ប៊ុនហេង។ សូមអរគុណ។

[០៩:០៥:២១]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ លោកមេធាវីបង្អង់បន្តិច!

អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមនៅក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

វេជ្ជបណ្ឌិតដែលទទួលបន្ទុកពិនិត្យ ថែទាំសុខភាពព្យាបាលជនជាប់ចោទនៅមន្ទីរឃុំឃាំង អ.វ.ត.ក បានពិនិត្យឃើញថានៅព្រឹកនេះ លោក អៀង សារី មានអាការៈហត់ខ្លាំងនៅពេលធ្វើចលនាបន្តិចបន្តួច និងផ្ដល់អនុសាសន៍ថាលោក អៀង សារី គួរតែត្រូវបានអនុញ្ញាតឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់មួយនៅខាងក្រោមសាលសវនាការនេះ។

អង្គជំនុំជម្រះយល់ឃើញថា នាពេលនេះ ជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ និងអាចសម្រួលទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីរបស់គាត់បាន។

[០៩:០៦:៣៩]

ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់អំឡុងពេលធ្វើសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះអ្នកជំនាញ ដេវីដ ឆេនដ័ល័រ ជាបន្ត។

សូមអញ្ជើញ!

[០៩:០៧:៣១]

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសុំបន្តចោទសំណួរទៅលោក ដេវីដ ឆេនដ៍ល័រ។

ជម្រាបសួរលោក ឆេនដ៍ល័រ ខ្ញុំឈ្មោះ អាកទួរ វែកគែន។ ខ្ញុំជាមេធាវីជនជាតិបារាំង និងជាមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** សំណួរទីមួយរបស់ខ្ញុំ ខ្ញុំសូមយោបល់លោកលើបុគ្គលិកលក្ខណៈនយោបាយរបស់លោក ខៀវ សំផន។ លោកបានលើកឡើងនៅចំពោះមុខតុលាការថា អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីមនុស្សទាំង៣៤នាក់ ដែលនៅ -- នៅឆ្នាំ១៩៦៣នោះ ជាមនុស្សដែលស្ដេចមិនស្គាល់ ដែលជាមនុស្សនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយដែលគេស្គាល់ថាជាមនុស្សឆ្វេងនិយម។ សំណួរខ្ញុំចង់ដឹងថា លើសពីព័ត៌មាន ៗដែលសម្ដេចមានទាក់ទងនឹងលោក ខៀវ សំផន តើវាជា -- មិនមែនជាការពិតទេឬ ដើម្បីឲ្យជាក់លាក់ជាងនេះ តើលោកយល់ឃើញថា ខៀវ សំផន ជាអ្នកកុម្មុយនីស្តដែលអនុវត្តលិទ្ធិកុម្មុយនីស្តនេះ ឬក៏យ៉ាងម៉េច? ឬក៏ជាមនុស្សចម្រើនទេ? ឬក៏ជាអ្នកដែលស្រឡាញ់បក្សកុម្មុយនីស្ត?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** សូមជម្រាបសួរ។ នេះជាសំណួរស្មុគស្មាញ ប៉ុន្តែសំណួរល្អ ខ្ញុំមិនប្រាកដថា តើខ្ញុំបានមើលឃើញ ខៀវ សំផន ដោយខ្លួនឯងទេរហូតទាល់ឆ្នាំ១៩៦៣នោះ ដែលត្រឡប់ដល់ពេលមួយដែលខ្ញុំបានមកកម្ពុជា ឆ្នាំ១៩៦២ ហើយនៅថ្ងៃនោះ ខ្ញុំមិនមានភស្តុតាងអ្វីបញ្ជាក់ថា គាត់មានអ្វីដែលថាគាត់ជាជនចម្រើនរបស់សមាជិកនៃបញ្ញវន្តកម្ពុជា។ សារព័ត៌មានបាននិយាយពីគាត់ ហើយសារព័ត៌មានត្រូវបានសម្ដេច សីហនុ បិទ។ ហើយសម្ដេច សីហនុ គិតថាកាសែតនោះវិទ្ធង្សនា គាត់មិនជា -- គាត់យល់ថាលោក ខៀវ សំផន នោះមិនមែនជាមនុស្សនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាទេ។

[០៩:១០:០០]

នៅពេលដែលគាត់បានបញ្ជាក់ថា មនុស្ស ៣៤រូបនោះ គឺកាលនោះបក្សកុម្មុយនីស្តកម្ពុជាមិនទាន់បានបង្កើតជាផ្លូវការទេ។

**ស៖** បាទ លោកឆ្លើយមកនឹងសំណួររបស់ខ្ញុំ ខ្ញុំសូមអរគុណ។ ខ្ញុំក៏ចង់ដឹងផងដែរ លោកឆេនដ៍ល័រ ពីការវាយតម្លៃរបស់លោក គឺទាក់ទងទៅនឹងសមូហភាពនៅតំបន់រំដោះមុនឆ្នាំ១៩៧៥។ ខ្ញុំចង់

ដឹងថា នៅក្នុងបរិបទនៃសម័យនោះ ចំពោះលោកតើវាជាវិធានការដែលយើងអាចដាក់ទណ្ឌកម្មបាន ឬក៏ជាវិធានការដែលអាចមានខ្លឹមសារ ហើយដែលយើងអាចជួបមនុស្សដែលមិនមែនជាអ្នកកាន់លទ្ធិកុម្មុយនីស្តឆ្គួតលីលា?

[០៩:១១:០៣]

**ឆៈ** នៅពេលដែលលោកនិយាយអំពីការសម្រេចអំពី សម្ងួហភាពនៅក្នុងឆ្នាំ១៩៦៣ នោះ ខ្ញុំមិនដឹងថា លោកចង់និយាយថាតើការផ្តន្ទាទោស ការថ្កោលទោសទៅលើអ្នកការទូតអាមេរិកាំងនោះ គេជាអ្នកបញ្ជាក់ព័ត៌មានដែលឲ្យទៅពិភពខាងក្រៅ។ គេប្រកាន់ជំហរថា ថ្កោលទោស ខ្ញុំមិនដឹងថាលោកចង់សួរសំណួរតើថា សំឡេងណាដែលទាក់ទងទៅនឹងសំឡេង ឬក៏សម្ងួហភាពនៅក្នុងសម័យកាលនោះទេ គឺវាមានលក្ខណៈមិនច្បាស់លាស់។

**សៈ** អ្វីដែលខ្ញុំចង់ដឹងអម្បាញ់មិញនោះ គឺថាដោយហេតុថាស្ថានភាពសេដ្ឋកិច្ចនៃប្រទេសកម្ពុជាថាចំពោះលោកនោះ ប្រហែលជាទំនងជាមានបំណងធ្វើសម្ងួហភាវូបនីយកម្ម ហើយដែលថាអាចយើងពន្យល់ពីហេតុផលខុសត្រូវបាន ថាមិនជាខុសអីទេ?

[០៩:១២:២៣]

**ឆៈ** ពិតហើយ។ និយាយអំពីសម្ងួហភាវូបនីយកម្មនេះគឺថាមនុស្សភាគច្រើនយល់ថា បក្សនោះបានព្យាយាមធ្វើ ប៉ុន្តែខ្ញុំមិនអាចឆ្លើយឲ្យច្បាស់ជាងនេះបានទេ។

**សៈ** បាទ សូមអរគុណ។ ខ្ញុំមិននិយាយលម្អិតអំពីផ្នែកនេះទេ។ តាមប្រវត្តិសាស្ត្រ តើជាការត្រឹមត្រូវដែរឬទេ នៅក្នុងការនិយាយថា នៅក្នុងឆ្នាំ -- ពីឆ្នាំ៧០ ដល់ ៧៥ វៀតណាមមិនត្រឹមតែមានវត្ត-មាននៅប្រទេសកម្ពុជាដែលមកស្នាក់នៅប្រទេសកម្ពុជានោះទេ ក៏ប៉ុន្តែថែមទាំងមកបង្កើតការគ្រប់គ្រងថ្នាក់ភូមិឃុំ នៅអាជ្ញាធរ ដើម្បីរើសកងទ័ពខ្មែរ ដើម្បីយកទៅដាក់នៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ តើអ៊ីចឹងមែនទេ?

[០៩:១៣:៣១]

**ឆៈ** ខ្ញុំមិនមានភស្តុតាងសកម្មភាពវៀតណាម -- នយោបាយវៀតណាមនៅកម្ពុជាទេ។ ក្រោយពីឆ្នាំ១៩៧២ មានកងទ័ពមួយចំនួនបានដកទៅវិញ ហើយគឺថាមានកងទ័ពខ្លះដែលខ្មែរក្រហមគេអនុញ្ញាតឲ្យមានការពាក់ព័ន្ធនោះ ប៉ុន្តែខ្ញុំមិនអាចបញ្ជាក់ច្បាស់នៅទីនេះ។ ខ្ញុំមិនបានអានអំពីឯកសារនយោបាយបែបនេះទេ គឺតាមពិតខ្មែរក្រហមខ្លួនឯងគឺស្ថិតនៅក្នុងសម័យនេះ រហូតដល់ឆ្នាំ១៩៧២ គេបានកសាង

កងទ័ព គេបានទទួលការបណ្តុះបណ្តាលធ្វើដំណើរការក្នុងកម្រិតធំក៏ដោយសម្ព័ន្ធមិត្តជាមួយនឹងវៀត-ណាមរបស់គេនោះឯង។

**ស៖** បាទ ខ្ញុំយល់ស្រប ក៏ប៉ុន្តែអ៊ីចឹងដើម្បីឲ្យច្បាស់លាស់គឺថា លោកមិនដែលឮអំពីទ្រឹស្តីដែលថាមកស្រុកខ្មែរហើយ មកចង់គ្រប់គ្រងខ្មែរទៀតនេះ។ តើលោកអត់ដែលឮអ៊ីចឹងទេឬ?

**ឆ៖** ខ្ញុំមិនអាចឆ្លើយបានទេ។ ខ្ញុំមិនចាំប្រភពដែលបាន -- ខ្ញុំប្រើក្នុងការស្នាដៃរបស់ខ្ញុំនៅកម្ពុជា ខ្ញុំមិនដែលបានសរសេរ ប៉ុន្តែមានអ្នកណាម្នាក់អាចប្រាប់ខ្ញុំក្នុងរយៈពេល៣០ឆ្នាំទៅហើយ។ ប៉ុន្តែខ្ញុំមិនអាចឆ្លើយថា ខ្ញុំធ្លាប់ឮទេ ប៉ុន្តែបើមានការពិភាក្សាមែន ខ្ញុំមិនចាំខ្លឹមសារនៃការសន្ទនានោះទេ។

[០៩:១៥:០០]

**ស៖** បាទ មីក្រូរបស់លោកនៅបើកនៅឡើយទេលោក។ តើជាការត្រឹមត្រូវដែរឬទេ តាមបែបប្រវត្តិសាស្ត្រ ថាតើជនជាតិខ្មែរ ហើយនិងជនជាតិវៀមណានោះ គឺថារត់ប្រជែងប្រណាំងគ្នា ដើម្បីរំដោះរបស់ខ្លួនតាមលំដាប់លំដោយ ទីក្រុងភ្នំពេញ ហើយនិងទីក្រុងសៃហ្គនហូជីមិញវីល តើមែនទេ?

**ឆ៖** ខ្ញុំមិនច្បាស់ទេ ថាតើសំណួរថាតើវៀតណាមក្រុមណា? ទីក្រុងណា? ហើយកាលបរិច្ឆេទណា? ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យច្បាស់ពីសំណួររបស់លោកឡើងវិញ។

**ស៖** នៅឆ្នាំ១៩៧៥ តើជាការត្រឹមត្រូវដែរឬទេ ដែលថាវៀតណាមម្ខាង ខ្មែរនោះម្ខាង គឺថានាំគ្នារត់ប្រណាំងដើម្បីរំដោះទីក្រុងរបស់ខ្លួន គឺទីក្រុងសៃហ្គន សម្រាប់ជនជាតិវៀតណាម ហើយនិងទីក្រុងភ្នំពេញសម្រាប់ជនជាតិខ្មែរ។ តើយើងអាចនិយាយយ៉ាងដូច្នេះបានដែរឬទេ គឺថាមានការរត់ប្រណាំងដើម្បីរំដោះទឹកដីរបស់ខ្លួននោះ?

[០៩:១៦:៤៨]

**ឆ៖** នេះគឺវិធីមួយដែលខ្មែរក្រហមបានបកស្រាយ។ គេបាននិយាយភាគច្រើន ជាការប្រណាំងគ្នា ដើម្បីរំដោះទីក្រុងហ្នឹង គឺថាមិនមានកំណត់ត្រាផ្លូវការទេ។ ប៉ុន្តែខ្ញុំមិនចាំថាបានឃើញកំណត់ត្រាដែលថាវៀតណាមបានប្រកួតជាមួយខ្មែរ ថារំដោះសៃហ្គនឲ្យបានមុននោះទេ ប៉ុន្តែយើង បានឮអ៊ីចឹង។ ហើយប៉ុន្តែក្រោយមក គឺថាខ្មែរក្រហមបានរំដោះទីក្រុងភ្នំពេញពីរសប្តាហ៍មុន ដែលវៀតណាមបានរំដោះទីក្រុងសៃហ្គន។ ដូច្នេះ ហើយខ្មែរក្រហមគេថា គេឈ្នះទៅលើវៀតណាម។ ហើយដូច្នេះហើយកងទ័ពវៀតណាមគេមានការរៀបចំបានល្អ បើនិយាយពីកងទ័ពបរទេស ហើយនេះហើយក្នុងករណីប្រទេសកម្ពុជា ដោយមានការលើកលែង ដូចដែលខ្ញុំបាន -- ដែលយើងហៅថា ការទម្លាក់គ្រាប់បែក

នៅក្នុងឆ្នាំ១៩៧៣ ដូចជាកងទ័ពបរទេស។ ខ្ញុំមិនគិតថា ការប្រណាំងប្រជែងគ្នាទេ ការរំដោះទីក្រុងទាំងពីរនេះ។ ប៉ុន្តែនេះជាការអះអាងរបស់ខ្មែរក្រហមក្រោយមកទេ ដែលខ្លួនថា ខ្លួនរំដោះភ្នំពេញ ពីរសប្តាហ៍មុនដែលវៀតណាមរំដោះទីក្រុងសៃហ្គនបាននោះ។

**ស៖** បាទ ឥឡូវ យើង ដោយយើងគិតពីគំនិតរបស់ខ្មែរក្រហម តើផ្នែកភូមិសាស្ត្រនយោបាយវាហាក់ដូចជា ការយល់អំពីស្ថានភាពនៅសម័យនោះនោះ គឺវាលក្ខណៈត្រឹមត្រូវ ពីព្រោះថាជាការសំខាន់ណាស់ ចំពោះពួកគាត់ ផ្នែកភូមិសាស្ត្រនយោបាយក្នុងការឈ្នះការប្រណាំងគ្នានេះ ទោះបីជាវៀតណាមខ្លួនឯងផ្ទាល់នោះ មិនដឹងថា ខ្លួនកំពុងតែប្រកួតប្រណាំងនឹងខ្មែរ ក៏ដោយចុះ។

[០៩:១៨:៤៨]

**ឆ៖** បាទ ខ្ញុំឃើញថា អរគុណហើយ ដែលបានប្រាប់ខ្ញុំពីបញ្ហានេះ។

**ស៖** បាទ ដើម្បីបញ្ជាក់បំភ្លឺបន្តិច តើនៅក្នុងបរិបទភូមិសាស្ត្រនយោបាយនោះ គឺថាវាមិនមានខ្លឹមសារអ្វីទេ ក្នុងការគិតថា ចំពោះខ្មែរដែលគិតថា វៀតណាមអាចមកដេញខ្លួនចេញពីទីក្រុងភ្នំពេញ។ តើនេះជាការគ្មានន័យខ្លឹមសារដែរឬទេ?

**ឆ៖** ពិតហើយ នៅឆ្នាំ១៩៧៥ គឺថាវៀតណាម និយាយថា គេមិនមានការចាប់អារម្មណ៍ទេ គឺថាដែលថាគេមានការងារសំខាន់របស់គេដែលធ្វើ គេមិនចាប់អារម្មណ៍នឹងខ្មែរក្រហមថាធ្វើអ្វីនោះទេ។ ហើយមូលហេតុរបស់ខ្មែរក្រហមនោះ គឺជាគំនិតអំពីពិភពលោកនោះ គឺអាចនឹងប្រវត្តិសាស្ត្រក្រោយមក គេអាចពង្រីកអត្តន័យរបស់គេ គឺថាគេយល់ថាអាទិភាពរបស់អំណាចបរទេសនោះគឺទាក់ទងជាមួយកម្ពុជា គឺថាកម្ពុជា គឺស្ថិតនៅក្នុងបញ្ជីខាងក្រោមនៃដែលរងឥទ្ធិពលបរទេសតិច។ ដូច្នេះ ខ្ញុំគិតថា គំនិតដែលថាវៀតណាមមានការងារធ្វើច្រើនជាជាងមកកាន់កាប់ភ្នំពេញក្រោយពីឆ្នាំ១៩៧៥ហ្នឹង គឺថាគេៗកាន់កាប់ប្រទេស ដែលមានប្រជាជន៧០លាននោះ គឺជាការងារសម្រាប់ច្រើនណាស់ អ្វីដែលក្នុងគំនិតគេនៅពេលនោះគឺ គេមិនចង់ប្រកាន់គំនិតថា មកកាន់កាប់ភ្នំពេញទេ គឺថាមិនមែនថាពួកគេភ័យខ្លាចទេ គឺថាប្រហែលជា ខ្ញុំអាចយល់ខុសពីរឿងវៀតណាម ប៉ុន្តែគំនិតអាទិភាពសំខាន់របស់វៀតណាម ជានយោបាយបរទេស នោះគឺថា គឺធ្វើម៉េចកុំឲ្យមានការកាន់កាប់បរទេសនៅក្នុងទឹកដីរបស់គេ ទោះបីរដ្ឋាភិបាលមុន ឬក្រោយក៏ដោយតាមដែលខ្ញុំដឹង។

[០៩:២១:១៤]

**ស៖** បាទ សូមអរគុណ។ បាទ ខ្ញុំមានសំណួរមួយ ប្រហែលជាលោកគិតថា ខ្ញុំហ្នឹងជាមនុស្ស

ឆោតល្ងង់ហើយ គឺថាសំណួរទាក់ទងទៅនឹងចំនួនអ្នកស្លាប់ នៅក្នុងចន្លោះឆ្នាំ៧០-៧៥ ពីព្រោះថា នេះជារឿងតួលេខ ហើយយើងបាននិយាយហើយ ហើយលោកបាននិយាយតួលេខក្នុងសៀវភៅជាច្រើន ហើយនៅក្នុង -- ដោយហេតុអីចឹងហើយបានយើងនិយាយ អំពីតួលេខនៅក្នុងចំពោះមុខតុលាការ។ ហើយខ្ញុំចង់និយាយផងដែរ អំពីភាពមិនច្បាស់លាស់ ទាក់ទងនឹងតួលេខនេះ ខ្ញុំគិតថា មានមនុស្សស្លាប់ម្នាក់នោះ ក៏វាជា -- លើសម្នាក់នោះក៏វាជាលើសបាត់ទៅហើយ។ តើខ្ញុំចង់ដឹង ថាតើនៅក្នុងប្រទេសកម្ពុជានៅបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយបន្ទាប់ពីព្រឹត្តិការណ៍ជាច្រើនបានកើតឡើងមកដូចជា ទម្លាក់គ្រាប់បែកសង្គ្រាមប្រឆាំងនឹង លន់ នល់ គ្រោះទុរភិក្ស ហើយនិងរបបកម្ពុជាប្រជាធិបតេយ្យ ជម្លោះប្រឆាំងនឹងវៀតណាម តើយើងអាចបែងចែកឲ្យបានច្បាស់លាស់ ថាអ្នកណាដែលធ្វើ អ្នកហ្នឹងទទួលខុសត្រូវ។ តើយើងត្រូវធ្វើនែ៎ -- លោកអាចនិយាយអំពីបញ្ហានេះបានដែរឬទេ? ហើយតាមរបៀបណា?

[០៩:២២:៤៨]

**ឆ៖** សូមអរគុណ។ ខ្ញុំមិនអាចប្រាប់បានច្រើនទេ។ ខ្ញុំគឺផ្អែកទៅលើការងាររបស់ខ្ញុំ ដែលស្រាវជ្រាវតែប៉ុណ្ណោះ គឺខ្ញុំផ្អែកលើរបាយការណ៍ប្រជាសាស្ត្រ គឺថាមានការធ្វើជំរឿនពីដើមគឺថា ទីមួយនៅឆ្នាំ១៩៦២ ដែលថាមានប្រជាជន ៥.៨លាន ហើយក្រោយមកគឺថា មាន៦លាន ហើយអ្នកប្រជា-សាស្ត្របានផ្អែកលើតួលេខនោះគឺថា ជាអត្រាគឺថា គេបញ្ជាក់ថា ១៣លាននោះគឺថា កើនរហូតមកដល់ឆ្នាំ១៩៨១ ហើយនៅក្នុងរយៈកាលពីរនេះ គឺថាម៉្យាងទៀតនៅក្នុងឆ្នាំ១៩៦៨ គឺមានតួលេខខ្ពស់ ឆ្នាំ១៩៧០ គឺមានតួលេខខ្ពស់ ហើយមកឆ្នាំ១៩៧០ដល់៩៦ គឺចំនួនហ្នឹងគឺគេធ្វើជំរឿនបានជាក់លាក់ គឺថា -- បើចង់ដឹងថា មនុស្សប៉ុន្មាននាក់ដែលស្លាប់នោះ គឺក្នុងករណីនេះ ខ្ញុំយោងទៅរកមតិដែលយល់ស្របគ្នានៅក្នុងការសិក្សាប្រជាសាស្ត្រ ដែលយើងមានរបាយការណ៍គេ អ្នកជំនាញរបស់គេ តួលេខដែលគេ -- ចំនួនសរុបគឺខ្ញុំមិនច្បាស់ គឺខ្ញុំមិនចង់ឲ្យលោកស្តីបន្ទោសខ្ញុំ អំពីតួលេខដែលខ្ញុំបញ្ជាក់នោះ ខ្ញុំគឺថា ដោយសារគេបញ្ជាក់ថា កន្លះលាននៅក្នុងសង្គ្រាមស៊ីវិល ហើយនិងការទម្លាក់គ្រាប់បែក គឺថា១.៨ ឬក៏ មួយ ដែលហេវ៉ាលីន ជាអ្នកប្រជាសាស្ត្រនោះគឺថា ប្រហែលជា៣លាន គាត់បានសន្និដ្ឋាននូវចំនួនមនុស្សស្លាប់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម។

[០៩:២៤:៣៨]

ហើយជំរឿនហ្នឹងក៏បានបញ្ជាក់ថា ប្រហែលជា១.៥, ១.៧ លាន បាទ ដូច្នេះហើយ ក្នុងចំពោះ

តួលេខ៣លាននោះ គឺថា កងទ័ពវៀតណាមជាអ្នកប្រមូលព័ត៌មាននោះ ហើយជនជាប់ចោទនិយាយថា -- ម្នាក់និយាយថា បើសិនជា៣លានមែន គឺមានតែវៀតណាមទេជាអ្នកសម្លាប់នោះ។ នេះហើយជាតារាងនៅជើងឯកមានឃើញបញ្ជាក់ពីតួលេខ ខ្ញុំមិនចាំច្បាស់ទេ ប៉ុន្តែខ្ញុំថាតួលេខហ្នឹងគឺថាមិន -- ពីព្រោះថាពាក្យ៣លាននេះ គឺជាការប៉ាន់ប្រមាណដែលមិនផ្អែកទៅលើការសិក្សាលម្អិតទេ ប៉ុន្តែបើ១.៥ ឬក៏១.៧ នោះគឺវាផ្អែកទៅលើលក្ខណៈដែលវាមានអ្នកជំនាញដែលគេបានធ្វើការសិក្សា។ ប៉ុន្តែមានការធ្លាក់ចុះនៃចំនួនប្រជាជន ដោយមានមុលហេតុមួយចំនួន។ ឧទាហរណ៍ថាការកាប់សម្លាប់ ឬការស្លាប់ក្នុងសម័យ ប៉ុល ពត ដោយសារអត់អាហារ ដោយសារការងារលើសកម្លាំង ជំងឺផ្សេងៗ ប៉ុន្តែយើងពិបាកនឹងសម្រេច ថាតួលេខណាមួយដែលច្បាស់លាស់ប្រាកដនោះ។

មានអ្នកខ្លះ គាត់អាចនិយាយមិនច្បាស់លាស់ពីតួលេខ ពេលខ្លះ គឺថា ពេលដែលនិយាយហ្នឹងគឺថាគេមិនអាចកំណត់បានទីកាប់សម្លាប់ហ្នឹងមួយៗនោះ សម្លាប់ប៉ុន្មានទេ គឺគេគ្រាន់តែប៉ាន់ប្រមាណ។ ជាពិសេសគឺ យើងបានសម្ភាសជនភៀសខ្លួនមួយចំនួនពីខាងដើម គឺថាដែលគេកំណត់យកតួលេខពីអ្នកជំនាញជប៉ុនជាដើម នេះគឺនៅជាចំណោទជាបញ្ហាដែលលើកឡើងថា មិនមានតួលេខច្បាស់លាស់ដែលយើងមាននោះទេ។ នេះជាចំណុចមួយដែលថានៅតែចោទជាបញ្ហា។ នេះជាចម្លើយទៅនឹងសំណួរគឺថាផ្អែកទៅលើសំណួររបស់ហ្នឹងគឺថា តួលេខសុទ្ធតែផ្អែកទៅលើការប៉ាន់ប្រមាណ គឺថាសក្ខីកម្មនៅក្នុងតុលាការនោះគឺ -- ឬក៏អ្នកផ្សេងដែលឆ្លើយក្រៅពីតុលាការនេះពីចំនួនតួលេខនោះគឺៗសមាជិកក្នុងក្រុមគ្រួសារនោះគឺ គ្រប់ -- សឹងតែគ្រប់សមាជិកគ្រួសារបានបាត់បង់នៅក្នុងសម័យខ្មែរក្រហម។

[០៩:២៧:០០]

ហើយខ្ញុំមិនគិតថាអ្នកទាំងអស់នោះនិយាយការមិនពិតនោះទេ។ ហើយប្រជាជនគឺថាគេគិតថាការសម្លាប់ -- ស្លាប់មនុស្សហ្នឹងគឺថារវាង ១.៣ ទៅ ១.៥លាន នោះឯង។ ហើយវាលើកឡើងនូវបញ្ហាឬថាអាចខ្ពស់ជាងហ្នឹង គឺថាអាចពី ១ ទៅ ២លាន ដែលថានៅក្នុងឆ្នាំ១៩៧០ ដល់ --៧៥ ដល់ ៧៩ នោះ គឺថាវាអាស្រ័យទៅលើកាលបរិច្ឆេទដែលលើកឡើងមកពិភាក្សានោះ តួលេខអាចនឹងល្អៀងប៉ុណ្ណឹង។

**ស៖** បាទ សូមអរគុណ ដែលបាននិយាយយ៉ាងលម្អិតយ៉ាងដូច្នេះ។ បាទ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីបញ្ហាមួយដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ ខ្ញុំសូមសួរលោកថា តើចំពោះលោកប្រភេទសមូហភាពូនីយកម្ម ដែលនៅមុនឆ្នាំ១៩៧០ -- នៅឆ្នាំ៧០, ៧៥ ហើយក្រោយមកមាននៅឆ្នាំ១៩៧៥ តើចំពោះលោក -- ប្រហែលជាមានរបៀបធ្វើមួយមុន ដែលថាវាមានលក្ខណៈទន់ភ្លន់ បត់បែន

ជាង ហើយឬក៏ពេលក្រោយមកវាតឹងរ៉ឹងជាង? តើការធ្វើបែបនេះ គឺអាចគ្រោងទុកបានទេ កាលនៅសម័យនោះៗ អាចទស្សន៍ទាយទុកមុនបានទេ?

[០៩:២៨:៤៦]

**ឆ៖** ខ្ញុំស្តាប់មិនបានសំណួររបស់លោកមួយផ្នែក គឺថាគេអាចប្រមើលមើលបាននៅក្នុងឆ្នាំ១៩៧៣ ព័ត៌មានដែលយើងទទួលបានដោយលោក កេណ្ណេត ឃ្វីន ឬក៏អ្វី ខ្ញុំយល់ថាចម្លើយខ្ញុំយល់ថា ព័ត៌មានដែលលោក ឃ្វីន ទទួលបានពីជនភៀសខ្លួនដែលរត់ទៅវៀតណាមនៅក្នុងឆ្នាំ១៩៧៣ នោះទំនងជាបង្ហាញថា -- បានបញ្ជាក់ថាកម្មវិធីជាច្រើនក្រោយមកគឺថា កម្ពុជាប្រជាធិបតេយ្យយកមកអនុវត្តហ្នឹងគឺថា ការឲ្យស្លៀកពាក់ដូចគ្នា ឲ្យហូបរួម ហើយការបំបាត់កម្មសិទ្ធិឯកជន និងគោលនយោបាយនោះ គឺដាក់ឲ្យអនុវត្តដោយ តាម៉ុក ហើយនិងសមាជិកនៃគណៈមជ្ឈិម ហើយនិងសមាជិកនៃគណៈអចិន្ត្រៃយ៍ បង្ហាញឲ្យយើងឃើញថា -- ហើយគេធ្វើឡើងអាចក្នុងបរិបទរបស់បក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំគិតថានយោបាយនោះ ប្រវត្តិសាស្ត្របង្ហាញថានេះគឺជា តំបន់នៅក្នុងឆ្នាំ១៩៧៣ ដែលជាកន្លែងមិនសមស្របដែលត្រូវអនុវត្ត នូវការងារដែលហៅថាសមូហភាវូបនីយកម្ម ឬក៏ការបង្កើតសហករណ៍នេះដូចជាតាកែវ ដែលថាតំបន់ប្រយុទ្ធជាច្រើនដែលគេរំដោះបានហ្នឹង គឺថាប៉ុន្តែ គឺបក្សកុម្មុយនីស្តកម្ពុជាកាន់កាប់រឹងមាំ ដែលគេរំដោះបានក្នុងសម័យសង្គ្រាមស៊ីវិល នៅក្នុង តាម៉ុក -- តំបន់របស់ តាម៉ុក ដែលអ្នកដែលស្មោះស្ម័គ្រ ហើយនិងមានគាំទ្រច្រើននៅក្នុងតំបន់ភូមិភាគនិរតីនោះ។ បាទ នេះគឺជាផែនការការចាប់ផ្តើមដ៏ជោគជ័យនៃនយោបាយរបស់គេ ដែលក្រោយឡើង គឺថាគេយកមកប្រើនៅក្នុងសម័យគឺថា--

**ស៖** ខ្ញុំចង់ដឹងថា បើតាមប្រវត្តិសាស្ត្រនោះ តើមានការៗ តឹងរ៉ឹងខ្លាំងជាងមុន រឺតបណ្តឹងជាងមុនដែរឬទេ?--

[០៩:៣១:០៤]

**ប្រធានអង្គជំនុំ៖**

ឈប់ៗសិន! លោកមេធាវី ដូចជាញាប់ពេក ឲ្យមានការឃ្លាតគ្នារវាងប្រសាសន៍របស់លោកអ្នកជំនាញ ហើយជាមួយនឹងសំណួរថ្មីរបស់លោកដែលនឹងតាំង។ អ្នកបកប្រែបកមិនទាន់ទេ ទីមួយ។ ទីពីរដូចជា អ្នកជំនាញឆ្លើយមិនទាន់ចប់មែនទេ លោក ដេវីដ ឆេនដ៍ល័រ? មានបញ្ហាអីទេ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

ការឆ្លើយតបរបស់ខ្ញុំចប់ហើយ។ ក៏ប៉ុន្តែយើងហាក់ដូចជាអត់ទុកពេលវេលាសម្រាប់ឲ្យអ្នកបកប្រែ។ ហើយខ្ញុំឃើញថា មេធាវីនោះគឺគាត់បានចាប់ផ្តើមសួរសំណួរថ្មីទៅហើយ ដូច្នេះហើយទើបខ្ញុំអម្បាញ់មិញចាប់ផ្តើមឆ្លើយវិញដែរ។ ខ្ញុំដឹងទៅលើចំណុចដែលយើងត្រូវទុកពេលវេលាសម្រាប់អ្នកបកប្រែ។

[០៩:៣២:០១]

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** បាទ លោក ដេវីដ ឆេនដ៍ល័រ តាមពិតខ្ញុំចង់កាត់ផ្តាច់លោក អ៊ីចឹងហើយបានមានការជាន់គ្នានេះ។ ខ្ញុំមានអារម្មណ៍ថា នៅក្នុងចម្លើយរបស់លោកនោះ ថាក្នុងចម្លើយរបស់លោកនុ៎ង វាហាក់ដូចជាសំណួរខ្ញុំមុននុ៎ងមិនសូវច្បាស់។ អ៊ីចឹងហើយបានខ្ញុំមិនចង់ឲ្យខាតពេលវេលា។ អ៊ីចឹងហើយបានខ្ញុំបានកាត់ផ្តាច់លោកអម្បាញ់មិញនោះ។ អ៊ីចឹងហើយបានមានការជាន់សំឡេងគ្នាអម្បាញ់មិញនេះ។

អ្វីដែលខ្ញុំចង់សួរលោកនោះ ខ្លឹមសារសំណួររបស់ខ្ញុំអម្បាញ់មិញនោះ គឺថាខ្ញុំចង់ថា បើតាមការវិភាគរបស់លោក តើមានការរឹតត្បិតតឹងឡើងនៃគោលនយោបាយសម្ងួហភាវូបនីយកម្មដែរឬទេ? តើមានភាពខុសគ្នារវាងរយៈកាលមុនឆ្នាំមួយប្រាំរយ -- ១៩៧៥ ឬទេ ៧០-៧៥នេះ មុន៧០ ហើយនិងក្រោយ៧០មក -- មុន៧៥ ហើយនិងក្រោយ ៧៥?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំគិតថា ខ្ញុំមិនចាប់សំណួររបស់លោកអត់បាន។ ចំណុចខុសគ្នានោះ គឺថាវាមានភាពខុសគ្នារវាងគោលនយោបាយដែលគេអនុវត្ត។ ជាពិសេសនូវគោលនយោបាយនៅក្នុងតំបន់មួយចំនួន ប្រជាជន -- សាក្សីជាច្រើន យើងឃើញថាវាមាននៅក្នុងតំបន់មួយចំនួនតូច ហើយអ្នកសាក្សីមួយចំនួនរស់នៅក្នុងតំបន់ផ្សេង។ ពេលខ្លះទៅយើងនិយាយអំពីភស្តុតាងដែលលេចចេញមកពីប្រទេសនេះទាំងមូល គឺចេញពីខេត្តណាមួយ។ ភស្តុតាងបានបង្ហាញថា វាការតឹងរ៉ឹង រឹតត្បិតនោះ វាមានកាន់តែខ្លាំងឡើង។ នេះគឺជាបាតុភាពនៅពេលនោះ។

[០៩:៣៣:៥២]

**ស៖** ហើយចំពោះបញ្ហានៃភាពកាន់តែតឹងរ៉ឹងឡើងនោះ យ៉ាងម៉េចវិញដែរ? សូមលោកពន្យល់។ តើលោកកំពុងតែប្រាប់យើងខ្ញុំថា យោងទៅតាមភស្តុតាងដែលយើងទទួលបាននោះ គឺវាមានផល

ប្រយោជន៍ ឬមួយក៏លោកចង់និយាយថា មានបញ្ហាខ្លះដូចវាមិនសូវច្បាស់ ហើយជួនកាលមានភស្តុតាងជាក់លាក់ច្បាស់លាស់បង្ហាញអំពីភាពកាន់តែតឹងឡើងៗនេះ។ តើលោកអាចពន្យល់បានទេ?

**ឆ៖** សំណួរល្អ។ ឃើញមានភស្តុតាងជាច្រើន ថាមិនបានបង្ហាញថា គ្មានអ្នកណាតឹងរ៉ឹងដូចតាម៉ុក នោះទេ។ ក៏ប៉ុន្តែគាត់ គឺមានអ្នកប្រជាជនមូលដ្ឋាននៅក្នុងសម្ហូភាព ក្រោមការគ្រប់គ្រងរបស់គាត់នៅភូមិភាគនិរតី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រជាជននៅខាងពាយ័ព្យនោះ គឺថាគេឃើញមានប្រជាជនថ្មីភាគច្រើន ដែលគេបានបញ្ជូនទៅពាយ័ព្យផងដែរ។ ហើយគេ -- រដ្ឋាភិបាលរំពឹងឲ្យប្រជាជននោះធ្វើការងារតាមដែលគេចង់បាន។ ភាពតឹងរ៉ឹង ភាពលំបាកលំបិន គឺកើតមានឡើង។

[០៩:៣៥:០៤]

ខ្ញុំគិតថា យើងឃើញមានជំពូកសរសេរដោយ ម៉ៃខល វីកឃើរី ដែលនិយាយអំពីជនភៀសខ្លួននៅក្នុងឆ្នាំ៨១ និងឆ្នាំ៨០ នៅក្នុងប្រទេសថៃ ដែលនៅក្នុងពេលនោះគេបង្ហាញអំពីភាពខុសគ្នារវាងគោលនយោបាយ ដែលអនុវត្តនៅតាមតំបន់ផ្សេងៗ ខុសៗគ្នា។ នៅខាងភូមិភាគឧត្តរនោះ គឺមិនមានការបះបោរដោយកម្មាភិបាលនោះទេ ហើយនៅក្នុងតំបន់មួយចំនួនគ្រប់គ្រងដោយកម្ពុជាប្រជាធិបតេយ្យនោះ គឺយើងឃើញថាមានការអនុវត្តលក្ខណៈរលូនជាងតំបន់ផ្សេង។ ខ្ញុំគិតថា នៅខាងនិរតីនោះគឺមិនមានអ្វីដែលវាថា កាន់តែរឹតត្បិតខ្លាំងឡើងនោះទេ គឺក៏ប៉ុន្តែយ៉ាងណាក៏ដោយ នៅក្នុងតំបន់មួយចំនួនគឺវាអាចមានលក្ខណៈតឹងរ៉ឹង ហើយវាអាចធូរស្រាល វាមិនដូចៗនៅខាងនិរតីនោះទេ។

**ស៖** សូមអរគុណ។ ហើយពាក់ព័ន្ធទៅនឹងប្រធានបទនេះដែរ បើតាមចំណេះដឹងដែលលោកទទួលបាននោះ តើជាការត្រឹមត្រូវដែរឬទេ ក្នុងការនិយាយថា នៅតាមតំបន់ខ្លះនោះ ប្រធាន មេស្រុក ប្រធានឃុំ ប្រធានភូមិអីហ្នឹង គឺថា គាត់ថាជាដូចជាស្ដេច ជាអធិរាជ ឬក៏ជាស្ដេចត្រាញ់អីនៅតាមតំបន់របស់ខ្លួនអីចឹង ទៅតាមពាក្យពេចន៍ដែលលោកប្រើនោះ គឺថាគាត់មិនខ្វល់អំពី -- គាត់ថាមិនរាយការណ៍អំពីសកម្មភាពគាត់ទៅអំណាចមជ្ឈិមទេ គឺគាត់ធ្វើអីតាមតែចិត្តគាត់ចង់ តើអីចឹងមែនទេ?

[០៩:៣៦:៤៨]

**ឆ៖** ខ្ញុំដូចជាមិនចង់ប្រើពាក្យហ្នឹងទេ អ្វីដែលយើងដឹងនោះគឺថា តើរាយការណ៍ មិនរាយការណ៍នោះ គឺត្រូវមើលលើឯកសារ។ យើងឃើញថា វាមានចំណុចជាច្រើនពាក់ព័ន្ធទៅនឹងកេរ្តិ៍ឈ្មោះនៅក្នុងចំណោមបុគ្គលដែលធ្វើនៅក្នុងភូមិភាគ។ ឧទាហរណ៍ថា សោ ភឹម គឺគាត់បានធ្វើអត្តឃាតនៅក្នុងឆ្នាំ១៩៧៨ ហើយអ្នកដែលជនភៀសខ្លួនបាននិយាយថា គឺគេបានគិតទុកអំពីបញ្ហាបុគ្គលរូបនេះ។ អ្នក

ផ្សេងទៀត ដូច តាម៉ុក ដែលមានលក្ខណៈតឹងរ៉ឹងចំពោះប្រជាជនថ្មីនៅក្នុងក្រោមការគ្រប់គ្រងរបស់គាត់។ ខ្ញុំស្ទាក់ស្ទើរក្នុងការប្រើពាក្យនោះណាស់។ យើងនៅពេលនេះនិយាយអំពីប្រទេសមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងលក្ខណៈមជ្ឈិការ។ ដូច្នេះហើយ ខ្ញុំមិនចង់ប្រើប្រាស់ពាក្យនោះទេ។

**ស៖** តើលោកអាចជម្រាបបានទេថា នៅក្នុងលក្ខខណ្ឌដូចដែលកើតមាននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺថាវាមានធ្វើឲ្យមេថ្នាក់ក្រោមនោះ គឺគាត់បញ្ជូនព័ត៌មានទៅឲ្យថ្នាក់លើតាមរបៀបអំណាចពីរ៉ាមីត គឺថាគាត់រៀបរាប់ព័ត៌មានពិតប្រាកដទៅថ្នាក់លើ ឬក៏គាត់ព្យាយាមលាបពណ៌ ឬថាធ្វើយ៉ាងម៉េចថាឲ្យព័ត៌មានដែលគាត់បញ្ជូនទៅហ្នឹង គឺថាល្អឥតខ្ចោះនោះ?

[០៩:៣៨:៣០]

**ឆ៖** សំណួរល្អ វាមិនអាចឆ្លើយងាយបាននោះទេ យើងត្រូវគិតថាតើការឆ្លើយឆ្លងគ្នារវាងភូមិភាគនោះ វាយ៉ាងណា។ យើងឃើញហើយថា នៅក្នុងករណីមួយចំនួនគឺគេមិនបានបំពេញទៅតាមតម្រូវការ។ របាយការណ៍ គឺពេលខ្លះទៅគេមិនបាននិយាយថាកូតាហ្នឹងបានបំពេញទៅតាមលក្ខខណ្ឌ ឬក៏យ៉ាងណានោះទេ។ ដូច្នេះចំណុចនេះ គឺខ្ញុំមិនអាចលើកឡើងចំពោះរបាយការណ៍ថាត្រូវបញ្ជូនទៅថ្នាក់លើ ឬក៏យ៉ាងណានោះទេ។ យើងមិនដឹងថា តើរបាយការណ៍នោះសរសេរត្រូវ ឬក៏ភរនោះទេ។ យើងមិនមានភស្តុតាងណាមួយបានបង្ហាញស៊ីសង្វាក់ទៅលើចំណុចនោះទេ។ យើងមិនដឹងថាតើគេនិយាយតែការពិត ឬក៏យ៉ាងណានោះទេ។ យើងដឹងហើយថា អ្នកដែលនៅក្នុងរបបនោះ គឺត្រូវតែនិយាយតែការពិត ប្រសិនបើគេកុហកនោះ គឺត្រូវតែបានគេកម្ទេចចោល នៅពេលដែលគេដឹងការពិត។ ដូច្នេះហើយខ្ញុំអាចនិយាយក្នុងន័យអ៊ីចឹងបាទ។

[០៩:៣៩:៤៣]

**ស៖** ពាក់ព័ន្ធទៅនឹងការបោសសម្អាត ខ្ញុំមានសំណួរមួយ ដែលខ្ញុំគិតថាប្រហែលជាមិនទូទៅពេកនោះទេ។ ហើយប្រសិនបើលោកគិតថា ទូទៅពេក លោកមិនបាច់ឆ្លើយក៏បានដែរ។ តើលោកគិតថាអ្វីដែលគេហៅថា ជាខ្មាំងនោះគឺត្រូវបានគេបោសសម្អាតចោលពីព្រោះថា គេគិតថាជាអ្នកប្រឆាំងទៅនឹងរបប ឬក៏គេបោសសម្អាតខ្មាំងដោយសារតែគាត់ជនជាតិភាគតិច ឬក៏គាត់ជនជាតិណា ឬក៏គាត់មានវណ្ណភាពអីបែបណានោះ?

**ឆ៖** នេះជាសំណួរមួយដែលត្រូវការស្រាវជ្រាវច្រើន ខ្ញុំមិនត្រូវ -- មិនអាចឆ្លើយជាលក្ខណៈកំណត់នោះទេ ភស្តុតាងដែលបង្ហាញនោះ គឺថាការបោសសម្អាតនោះក៏ផ្អែកទៅលើជន -- ថាគាត់ជា

ជនជាតិភាគតិចណា ឬក៏យ៉ាងម៉េចនោះដែរ។ អ្វីដែលថាខ្មាំងវណ្ណៈនោះ វាពិបាកនិយាយណាស់ថាតើបុគ្គលទាំងអស់នោះគឺជាសមាជិករបស់ក្រុមប្រឆាំង វណ្ណៈប្រឆាំងដែរឬទេ។ យើងឃើញ ដឹងហើយថាគេមានប្រើពាក្យថា "ខេ.ដី.ប៊ី" ថាអ្នកដែលប្រឆាំងនឹងគោលការណ៍នេះ គឺត្រូវតែកំណត់ថាជាជនអ៊ីចេះជនអ៊ីចុះ។ ដូច្នេះហើយជាទូទៅការបោសសម្អាតនោះ គឺផ្អែកទៅលើមូលដ្ឋានជាក់លាក់ ប៉ុន្តែវាពិបាកក្នុងការនិយាយណាស់។ ហេតុផលដែលគេចង់កម្ទេចវៀតណាមនៅក្នុងឆ្នាំ១៩៧៨ យើងអាចហៅថាវាជាការបោសសម្អាតមួយ។ នេះគឺជាការគិតរបស់ខ្ញុំ។ ខ្ញុំថាត្រូវនិយាយយ៉ាងម៉េច របបនេះធ្វើចំពោះវៀតណាមនោះ គឺយើងអាចយល់ថាវាជាអំពើប្រល័យពូជសាសន៍តាមអនុសញ្ញារបស់អង្គការសហប្រជាជាតិ។ ការបោសសម្អាតមួយចំនួននោះ គឺថាមិនអាចជាអំពើប្រល័យពូជាសាសន៍នោះទេ។

[០៩:៤១:៤៤]

ដូច្នេះហើយការបោសសម្អាតពាក់ព័ន្ធទៅនឹងក្រុមជនជាតិភាគតិចនោះ គឺធ្វើឡើងនៅចុងរបបនោះ ជាជាងនៅដើមរបបឆ្នាំ៧៥, ៧៦ ឬ៧៧។

**ស៖** ដើម្បីបន្តទៅលើបញ្ហាបោសសម្អាតនេះដដែល ក៏ប៉ុន្តែខ្ញុំចង់លើកឡើងនូវផ្នែកមួយផ្សេងទៀត។ យើងដឹងច្បាស់ណាស់ថា នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ការបោសសម្អាតនោះគឺប៉ះពាល់ទៅដល់ឥស្សរជនជាន់ខ្ពស់ផងដែរ។ ហើយខ្ញុំមិនសូវយល់អំពីទិដ្ឋភាពពីរនៃសក្ខីកម្មរបស់លោកនៅក្នុងសវនាការនេះ ដូចជាមានភាពចម្រូងចម្រាសគ្នា។ ដូច្នេះខ្ញុំនឹងអាចពន្យល់អំពីអ្វីដែលខ្ញុំមិនយល់នេះបាន។ ម្ខាងលោកនិយាយថា មានការជជែកពិភាក្សាគ្នាទូលំទូលាយតិចតួចនៅក្នុងថ្នាក់លើ នៅសម័យកម្ពុជាប្រជាធិបតេយ្យ ហើយម្ខាងទៀតលោកនិយាយថា ការសម្រេចអ្វីៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺធ្វើឡើងជាសមូហភាព ដូចដែលលោកបានសរសេរនៅក្នុងសៀវភៅរបស់លោក។

[០៩:៤២:៥៦]

សំណួររបស់ខ្ញុំ គឺថា តើយើងអាចសម្រេចសេចក្ដីជាសមូហភាពយ៉ាងម៉េចបើអត់មានការជជែកពិភាក្សាគ្នាជាទូលំទូលាយផងនោះ?

**ឆ៖** វាអាស្រ័យទៅលើក្រុមសមូហភាពនោះតិចប៉ុនណា ឬច្រើនប៉ុនណា? ការពិភាក្សាជាចំហនោះវាមិនមែនលក្ខណៈរបស់កម្ពុជាប្រជាធិបតេយ្យនោះទេ គឺខ្ញុំគិតថា វាមិនមែនជាបញ្ហាត្រង់នេះនោះទេ។ ខ្ញុំគិតថា សក្ខីកម្មរបស់ខ្ញុំអាចវាមានលក្ខណៈផ្ទុយគ្នា ក៏ប៉ុន្តែខ្ញុំអធ្យាស្រ័យចំពោះចំណុចហ្នឹង ក៏ប៉ុន្តែ -- ខ្ញុំសូមបន្ថែមយើងមិនមានភស្តុតាងដែលបង្ហាញថា ការបោសសម្អាតនៅក្នុងថ្នាក់លើនោះគឺធ្វើឡើង

ដែលថា វាបើកជាការជំទាស់តវ៉ាពីក្នុងរបបនោះទេ។ ខ្ញុំគិតថា ចំណុចនេះហើយវាពាក់ព័ន្ធទៅនឹង វន វ៉េត ហើយនិងបុគ្គលផ្សេងទៀត។

[០៩:៤៤:០២]

យើងដឹងហើយថាចម្លើយសារភាពវែងនោះ យើងមិនអាចយកធ្វើជាភស្តុតាងនេះទេ ក៏ប៉ុន្តែ មិនមានភស្តុតាងណាបង្ហាញទៅលើចំណុចនេះឡើយ។ ហើយគឺថាការដែលគេធ្វើដូច្នោះ វាអាចបើកឲ្យមានការជំទាស់ទៅនឹងការប្រជុំជាសមូហភាពរបស់ពួកគេ។

**ស៖** ដូច្នេះលោកគិតថា គឺអាចធ្វើបានឡើងដោយសេរីមែនទេ លោកជំនាញ? គឺថាពួកគេអាចបញ្ចេញមតិយោបល់បាននៅក្នុងកិច្ចប្រជុំដោយសេរី មិនមានការរឹតត្បិតអីមែនទេ?

**ឆ៖** ជាការពិតអត់មានទេ។ យើងត្រូវគិតថា តើមានអ្វីបានកើតឡើង។ ប្រជាជនទាំងអស់នេះ គឺគាត់បានទុកចិត្តគ្នាទៅវិញទៅមកនៅក្នុងនាមជាក្រុម។ ឧទាហរណ៍ថា អ្នកដែលក្រុមរៀបចំការងារនៅប៉ង់តាហ្គោន ចំពោះសង្គ្រាមវៀតណាមដូចគ្នានោះដែរ។ ដូច្នេះហើយអ្នកដែលគាត់នៅក្នុងនោះ គឺគេទទួល ថាតើទទួលការដឹកនាំរបស់ ប៉ុល ពត ឬក៏របស់គណៈអចិន្ត្រៃយ៍ដែរឬទេ។

យើងឃើញមានបញ្ហាចោទមួយចំនួន ដែលគេលើកឡើង ហើយបណ្ណសារឯកសារមួយចំនួនវាបានបាត់បង់អស់ហើយ ដែលយើងមិនបានឃើញ ក៏ប៉ុន្តែទម្លាប់របស់ពួកគេចំពោះខ្ញុំនោះនៅពេលដែលខ្ញុំមើលបញ្ហាកុម្មុយនីស្តនោះ។ ជាពិសេសនៅប្រទេសចិន និងសហភាពសូវៀត វៀតណាម។ ចំណុចនេះ វាបើកឲ្យមានការពិភាក្សាពាក់ព័ន្ធទៅនឹងភាពខុសគ្នារវាងគោលនយោបាយ និងការតវ៉ាទៅលើលេខារបស់បក្ស។ ក៏ប៉ុន្តែបុគ្គលមួយចំនួនមិនធ្វើដូច្នោះនោះទេ។ ខ្ញុំមិននិយាយថា វាជាការពិភាក្សាដោយចំហនោះទេ។ វាជាពិភព ឬក៏ស្ថានភាពមួយខុសគ្នាពីកន្លែងផ្សេង។

[០៩:៤៦:២១]

**ស៖** ខ្ញុំចង់ចូលទៅចំណុចមួយទៀត។ អម្បាញ់មិញនេះ យើងនិយាយអំពីបណ្ណសារ នៅពេលដែលលោកមេធាវី សុន អរុណ នៃក្រុមការពារក្ដី នួន ជា បានសួរលោកថា តើលោកបានពិនិត្យមើលគ្រប់កន្លែងដែលលោកបានសរសេរឯកសារទេ ហើយលោកគិតថា វាជាការសំខាន់នៅក្នុងកិច្ចការរបស់ទស្សនៈ -- របស់អ្នកប្រវត្តិវិទូនោះ។ ខ្ញុំចង់ដឹងថា ពាក់ព័ន្ធទៅនឹងឯកសារពីសម័យនោះ ក្នុងទ្រង់ទ្រាយដើម។ លោកក៏លោកទទួលស្គាល់ដែលថា បរិបទប្រវត្តិសាស្ត្រ បរិបទនយោបាយកម្ពុជានោះមានភាពធ្ងន់ធ្ងរខ្លាំងណាស់តាំងពីចុងរបបកម្ពុជាប្រជាធិបតេយ្យមក គឺថារហូតធ្វើទៅឲ្យមាន -- ឯកសារមួយ

ចំនួនបាត់បង់ ខូចខាត។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើចំពោះអ្នកប្រវត្តវិទូនោះ តើវាមិនជាការសំខាន់ទេ ឬក្នុងការមានឯកសារនៅក្នុងដៃដែលជាឯកសារដើមនោះ ជាជាងការប្រមូលឯកសារជារបៀបកូពី ថតចម្លងមកពីណា ពីណី ដែលយើងមិនដឹងច្បាស់នោះ?

**ផ៖** ជាការពិតដូច្នោះមែន។ វាបញ្ជាក់យ៉ាងច្បាស់ យើងឃើញ យើងមានអត្ថបទច្បាប់ដើមរបស់សម័យកម្ពុជាប្រជាធិបតេយ្យ ដែលកើតចេញពី -- ដែលយកមកពី ស-២១ វាជាឯកសារដើម ក៏ប៉ុន្តែយើងត្រូវតែពិនិត្យមើលថា តើវាជាឯកសារក្លែងក្លាយប្រឌិត ឬក៏យ៉ាងណា។ យើងត្រូវមើលប្រភពនៃឯកសារចេញមកពីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ក៏ប៉ុន្តែយ៉ាងហោចណាស់ ក៏យើងមានឯកសារដែរ បើទោះបីជាឯកសារនោះថតចម្លងក៏ដោយ។ យើងគិតថា វាអាចទុកចិត្តបានចំពោះឯកសារទាំងអស់នោះ។ យើងឃើញថា វាអាចមានជាបញ្ហាដែលកើតឡើងនៅទីនេះ ក៏ប៉ុន្តែខ្ញុំមិនចង់បញ្ជាក់ទៅលើចំណុចនោះទេ ដោយសារបញ្ហានេះលើកឡើងដោយក្រុមមេធាវីការពារក្តី នួន ជា។ យើងពេលខ្លះទៅ មិនអាចធ្វើសេចក្តីសម្រេចច្រើននោះទេ ក៏ប៉ុន្តែយើងអាចធ្វើសេចក្តីសម្រេចមួយចំនួនដែរ ផ្អែកទៅលើឯកសារទាំងអស់នេះ។ ហើយដោយសារឯកសារនេះ វាជាកំណត់ហេតុមួយសម្រាប់យើង។ អ្វីដែលយើងចង់ឃើញ ឧទាហរណ៍ថា កំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍អ៊ីចឹង គឺយើងគិតថា គេបានសរសេរឡើងរហូតមកដល់ចុងឆ្នាំ៧៨។ នេះជាឧទាហរណ៍មួយ។

[០៩:៤៩:០៦]

**ស៖** កាលពីម្សិលមិញនៅក្នុងសវនាការនេះ លោកបានបញ្ជាក់ថា “យ៉ាងហោចណាស់ ក៏មានកិច្ចប្រជុំគណៈអចិន្ត្រៃយ៍៣០០ដងដែរ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ” ក៏ប៉ុន្តែរហូតមកដល់ថ្ងៃនេះ គឺថាយើងមានកំណត់ហេតុតែ១៩ទេ ដែលបញ្ជាក់ណាស់នៅក្នុងចំណងនោះថា “កិច្ចប្រជុំគណៈអចិន្ត្រៃយ៍”។ ខ្ញុំមិនច្បាស់ខាងតួលេខអីប៉ុន្មានទេ ខ្ញុំមិនមែនជាអ្នកជំនាញខាងតួលេខទេ ក៏ប៉ុន្តែបើសិនជា ១៩ ហើយនិង៣០០នោះ គឺវាខុសគ្នាឆ្ងាយណាស់។ ដូច្នេះ ខ្ញុំមិនចោទថាអ្នកណាត្រូវទទួលខុសត្រូវលើរឿងនេះទេ។ ខ្ញុំមិនចោទទេ មិនមែនជាគោលដៅរបស់ខ្ញុំទេ។ អ្វីដែលខ្ញុំចង់ដឹងនោះ គឺខ្ញុំចង់ដឹងថា ក្នុងនាមលោកជាអ្នកប្រវត្តិវិទូនោះ លោកអាចបញ្ជាក់បានទេថាវាខុស -- យើងបាត់អស់ហើយកំណត់ហេតុ ៩២ភាគរយហើយ បើគិតមើលទៅនោះ ដែលបញ្ជាក់អំពីសកម្មភាពរបស់ថ្នាក់លើនោះ។ ដូច្នេះ វាស្ថានភាពនេះ វាលំបាកណាស់ បើយើងគិតមើលទៅ ពីព្រោះថា រវាង ១៩ ហើយនិង ៣០០ នេះ វាខុសគ្នាឆ្ងាយណាស់។ អ៊ីចឹងតើលោកអាចពន្យល់បានទេ ចំពោះចំណុចនេះ?

**ឆ៖** វាកម្រិតខ្លះ នោះគឺថាកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ រួមទាំងរបស់ខាងកុម្មុយនីស្តនៅសូវៀតនោះ ក៏មិនមានសម្រាប់អ្នកសរសេរសៀវភៅផងដែរ។ ប្រវត្តិសាស្ត្រពាក់ព័ន្ធនឹងរបបនោះ គឺយើងអាចទាញចេញពីប្រភពផ្សេងបាន។ ខ្ញុំគិតថា ឯកសារជាង១០០ ដែលថាយើងមិនមាននោះ ក៏វាមិនមែនជាបញ្ហាចោទសម្រាប់យើងនោះដែរ។ យើងឃើញហើយថា របបនេះជាងបីឆ្នាំ គឺគេប្រជុំជាញឹកញាប់។ ហើយយើងឃើញហើយថា ខៀវ សំផន បានធ្វើសេចក្តីថ្លែងការណ៍នេះ ថាមានការប្រជុំពីរដងក្នុង -- ម្តងក្នុងពីរសប្តាហ៍។

[០៩:៥១:១៩]

ដូច្នេះហើយ គឺឯកសារទាំងអស់នោះ គឺភាគច្រើនហ្នឹង មិនមាននោះទេ ហើយក៏ជាឯកសារសម្ងាត់ដែរ។ អ្នកដែលសរសេរប្រវត្តិសាស្ត្រនោះ គឺគេមិនអាច -- គេមិនចាំបាច់ផ្អែកទៅលើចំណុចទាំងអស់នោះទេ។ គេត្រូវតែទទួលយកការពិតតែម្តង។ ខ្ញុំមិនដឹងថា តើលោកនិយាយថា យើងសម្រេចគោលដៅ ឬក៏យ៉ាងនោះទេ? យើងអាចសរសេរបាន ដោយមិនចាំបាច់មានចំណុចទាំងអស់នេះ។ គេអាចសរសេរប្រវត្តិរូប -- ប្រវត្តិសាស្ត្រនោះដោយល្អ ដោយមិនចាំបាច់ផ្អែកទៅលើឯកសារទាំងអស់នេះតែម្តង ក៏បានដែរ។

**ស៖** តើការខ្វះខាតឯកសារនៅសម័យនោះ ដែលខ្ញុំបានលើកឡើងនេះ អាចពន្យល់បានទេថា វាជា -- ប្រសិនបើយើងប្រៀបធៀបទៅនឹងស្នាដៃឯកសាររបស់លោកនោះ ដូចជាសៀវភៅ "សំឡេងចេញពីស-២១" ដែលសៀវភៅនោះ គឺផ្អែកទៅលើបណ្ណសារសំខាន់ៗ ដែលរកបាននៅមន្ទីរស-២១ ហើយបើធៀបទៅនឹងសៀវភៅផ្សេងៗទៀត ដែលនិយាយអំពីប្រវត្តិនៃរបបនេះ គឺថាវា -- ឯកសារខ្លះគឺរៀបរាប់របៀបដូចជាប្រលោមលោក ដូចជាការនិទានរឿងអ៊ីចឹង។ គឺដូចជាលោក កាណាវាស ក៏គាត់បានគាត់បានអានឃ្លាឃ្លោងមួយចំនួនហើយ នៃសៀវភៅមួយចំនួននោះ។ តើតាមរយៈនេះ គឺមានប្រភពឬក៏មានការពន្យល់អ្វីទេ ពាក់ព័ន្ធទៅនឹងភាពខុសគ្នានៃស្នាដៃ ឬក៏នៃសៀវភៅផ្សេងៗនេះ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំគួរតែសរសេររឿងប្រលោមលោក ក៏ប៉ុន្តែខ្ញុំមិនដែលសរសេររឿងប្រលោមលោកនោះទេ ហើយជីវប្រវត្តិ សៀវភៅជីវប្រវត្តិ ហើយនិងប្រលោមលោកមានលក្ខណៈខុសគ្នា។ វាមាន *ហ្សង់* ប្រភេទវាខុសៗគ្នា នៅក្នុងការសរសេរសៀវភៅនោះ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ វាមានភាពខុសគ្នារវាងការសរសេរសៀវភៅ "សោកនាដកម្មកម្ពុជា" និង "សំឡេងស-២១"។

[០៩:៥៣:៣៣]

យើងដឹងហើយ ខ្ញុំកាលពីមុន គឺខ្ញុំមិនដែលធ្លាប់មកប្រទេសកម្ពុជានោះទេ ក៏ប៉ុន្តែក្រោយមក គឺខ្ញុំមកដល់ ហើយមានឯកសារមួយចំនួន ចេញពីមកពីបុគ្គលដែលធ្វើការនៅស-២១ រួមទាំងចម្លើយសារភាព។ ខ្ញុំបានពិនិត្យមើលទៅលើកំណត់ហេតុមួយចំនួនរបស់គណៈអចិន្ត្រៃយ៍ ហើយសៀវភៅដែលនិយាយអំពី "តើ ប៉ុល ពត ឡើងកាន់អំណាចដោយរបៀបណា?" ខ្ញុំក៏បានមើលដែរ។ ហើយនៅក្នុងសៀវភៅមួយចំនួននោះ គេសរសេរពីរបបសម័យនោះផងដែរ។ ចំពោះសៀវភៅស្តីពី "បងធំទី១" គឺសៀវភៅ ប៉ុល ពត នោះ គឺខ្ញុំបានមើលឯកសារដើម រួមទាំងសេចក្តីថ្លែងការណ៍របស់ ប៉ុល ពត ដោយផ្ទាល់ និងខ្ញុំមើលឯកសារសម័យខ្មែរក្រហមពីមុនមក រួមទាំងទស្សនាវដ្តីទង់បដិវត្តផងដែរ។

ខ្ញុំមើលបានចម្លើយសារភាពផ្សេងៗ ចេញពីបណ្ណសារស-២១ ហើយខ្ញុំបានត្រឡប់មកប្រទេសកម្ពុជាឡើងវិញ នៅក្នុងឆ្នាំ១៩៨១ ហើយរៀបចំជា *មែនញូលស្ក្រីប* នោះ នៅក្នុងឆ្នាំ១៩៩២។ សៀវភៅទី៣របស់ខ្ញុំមិនមែនជាការនិទានរឿងនោះទេ វាជាការប្រវត្តិ ស-២១។ នៅក្នុងជំពូកទី១ គឺវាជាការនិទានមែន ក៏ប៉ុន្តែសៀវភៅនោះ គឺការវិភាគទៅលើប្រតិបត្តិការរបស់ ស-២១។ តាមអ្វីដែលយើងរកឃើញមូលដ្ឋានឯកសារ ជាពិសេសយកឯកសារចេញពីបណ្ណសារដ្ឋាននៅកន្លែងនោះ។ ដូច្នេះហើយ គឺថាវាមានប្រភពជាច្រើន អាចយកទៅសរសេរក្នុងសៀវភៅទីមួយ ក៏ប៉ុន្តែប្រភពមួយចំនួនតិចទេ យើងសរសេរនៅក្នុងសៀវភៅក្រោយៗ។ ដូច្នេះហើយថា ការសរសេរសៀវភៅមួយ និងសៀវភៅមួយទៀត គឺវាត្រូវការបច្ចេកវិទ្យា និងវិធីសរសេរខុសគ្នា។ គឺខ្ញុំមិនទទួលយកគំនិតដែលថា ខ្ញុំសរសេរជាលក្ខណៈរឿងប្រឌិតនោះទេ។

[០៩:៥៥:៤៥]

**ស៖** សំណួរខ្ញុំដូចជាមិនចង់បានន័យទេលោក ឆេនដ៍ល័រ ប៉ុន្តែវាមិនអីទេ។ ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ គេបានបង្ហាញជូននូវឯកសារថតចម្លងមួយចំនួន ជូនឲ្យលោកពិនិត្យមើលដែលគេសន្មតថាជាឯកសារដែលកើតឡើងនៅសម័យកម្ពុជាប្រជាធិបតេយ្យ។ ក្នុងចំណោមឯកសារដែលគេបានបង្ហាញជូនរយៈពេលប៉ុន្មានថ្ងៃនេះ នៅក្នុងអាជីពរបស់លោកជាអ្នកស្រាវជ្រាវនោះ តើលោកមានធ្លាប់ឃើញឯកសារណាមួយ ដែលលោកពិនិត្យហ្នឹងមានច្បាប់ដើមទេ ឯកសារនៅសម័យនុ៎ង?

**ឆ៖** ខ្ញុំឃើញមាន។ កំណត់ហេតុគណៈអចិន្ត្រៃយ៍ វាជាឯកសារដើម។ ខ្ញុំបានទទួលឯកសារនោះនៅពេលយប់ ហើយបន្ទាប់មក ខ្ញុំប្រគល់ឲ្យគេវិញនៅថ្ងៃស្អែក គឺខ្ញុំមាននៅក្នុងដៃមុនពេលដែលខ្ញុំអានចម្លើយសារភាពមួយចំនួនពីស-២១។ ឯកសារដើម ខ្ញុំមាន ខ្ញុំបានឃើញ។ នេះគឺជាអ្វីដែលខ្ញុំធ្លាប់

បានឃើញមែន។

**ស៖** ដើម្បីឲ្យកាន់តែច្បាស់ថែមទៀតនោះ ដើម្បីផ្តល់ជាឧទាហរណ៍នៅក្នុងបញ្ហានេះ។ នៅថ្ងៃដំបូងនៃសវនាការ លោកបានពន្យល់ថា ច្បាប់ដើម នៃកំណត់ហេតុថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦ គឺថា គេបានផ្តល់ឲ្យលោក ឬក៏ឲ្យទៅលោក ប៉ែន យៀរនិន ដែលគេបានរកឃើញនៅក្នុងផ្ទះមួយនៅឆ្នាំ៧៩។ តើលោកអាចប្រាប់ឈ្មោះ អ្នកដែលប្រគល់ឯកសារនេះជូនលោក ឬក៏ជូនលោក ប៉ែន យៀរនិន បានទេ? ឯកសារដែលថាកើតឡើងនៅសម័យនោះ។

[០៩:៥៧:៥៥]

**ឆ៖** ជាការពិត គឺវាការកត់ត្រានៅក្នុងតុលាការមិនមែនជាចំណុចដែលថា វាជាឯកសារសម្ងាត់នោះទេ។ គាត់ -- ឯកសារមួយចំនួននោះបានផ្តល់ទៅដល់ ប៉ែន យៀរនិន នៅក្នុងឆ្នាំ១៩៨២ គឺឯកសារឆ្នាំ៦៧ -- ឯកសារចំនួន៦៧ ច្បាប់គឺគេបានផ្តល់ឲ្យលោក ប៉ែន យៀរនិន នៅក្នុងឆ្នាំ១៩៩០ នៅពេលដែលខ្ញុំមក ត្រឡប់មកប្រទេសកម្ពុជា ខ្ញុំបានជួបលោក ខៀវ កាញ៉ារិទ្ធ ហើយគាត់លើកឡើងថា គាត់មានការអន់ចិត្តចំពោះឯកសារមួយ ដែលខ្ញុំបានផ្តល់ឲ្យទៅ ប៉ែន យៀរនិន។ គាត់បានថា ខ្ញុំចង់ផ្តល់លោកទៅលើឯកសារមួយចំនួនទៀត ដែលខ្ញុំមាន គាត់នៅពេលនោះ ផ្តល់ឲ្យខ្ញុំឯកសារប្រាំពីរទៅប្រាំបីច្បាប់មកខ្ញុំ ហើយខ្ញុំឲ្យគាត់វិញនៅថ្ងៃស្អែក។ ដូច្នេះហើយការប្រគល់ឯកសារនេះគឺថា តាមរយៈលិខិតស្នើ និងលិខិតបញ្ជូនទៅដល់គាត់។ ខ្ញុំបានទទួលឯកសារមួយចំនួន។ ដូច្នេះ ឯកសារប្រហែលជាពាក់កណ្តាល គឺគេបានរកឃើញ ហើយគឺគេចាំរកមើលដែរ ថាតើនឹងឯកសារទាំងអស់នឹងមានការបោះពុម្ពផ្សាយដែរឬទេ។ ខ្ញុំបានប្រើឯកសារទាំងអស់នេះ នៅក្នុងសៀវភៅ។ ឯកសារមួយ ដែលខ្ញុំបានទទួលពីគាត់នោះគឺ ការប្រៀបធៀប ហើយគាត់បានឲ្យខ្ញុំលាក់បាំងចំពោះអ្នក -- ឈ្មោះដែលអ្នកផ្តល់ឲ្យមកខ្ញុំនេះ ដោយសារចំណុចនេះ វាសំខាន់ណាស់នៅពេលនោះ។ ឯកសារដប់ច្បាប់ ដែលផ្តល់មកឲ្យខ្ញុំនោះគឺសម្រាប់ការស្រាវជ្រាវ ហើយបានផ្តល់ទៅឲ្យអ្នកស្រាវជ្រាវមួយចំនួន ដូចជា យៀរនិន និងខ្ញុំផងដែរ។ យើងអាចនិយាយចំណុចនេះជាលក្ខណៈសាធារណៈបាន ប្រសិនបើលោកចង់លើកឡើង។

[១០:០០:២០]

**ស៖** អ្នកទទួលខុសត្រូវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានមកផ្តល់សក្ខីកម្មនៅក្នុងសវនាការនេះដែរ កាលពីប៉ុន្មានខែមុននោះ។ ហើយយើងបានសួរសំណួរទៅកាន់ប្រធានមជ្ឈមណ្ឌលនោះថាគាត់អាចបញ្ជាក់បានទេថា កន្លែងណាដែលគាត់រក្សាឯកសារដើមដែលកើតឡើងនៅសម័យកម្ពុជាប្រជាធិប-

តេយ្យនោះ។ ហើយខ្ញុំគិតថាសំណួរនេះជាសំណួរសំខាន់ណាស់ ដែលខ្ញុំសួរគាត់នោះ វាមានលក្ខណៈ ជាលក្ខណៈច្បាប់ លក្ខណៈ -- វាមានសារៈសំខាន់ណាស់ចំពោះបញ្ហាឯកសារច្បាប់ដើមនេះ។ ចំពោះ លោកវិញ តើលោកមានគំនិតអ្វីវិញទេ ពាក់ព័ន្ធទៅនឹងមូលហេតុដែលថា មជ្ឈមណ្ឌលឯកសារកម្ពុជា គាត់មិនចង់បញ្ចេញប្រាប់អំពីកន្លែងដែលគាត់រក្សាទុកឯកសារច្បាប់ដើមនោះ?

[១០:០១:២០]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប! ចាំស្តាប់សេចក្តីជំទាស់លើសំណួរនេះដោយតំណាងសហព្រះរាជអាជ្ញា។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោក លោកស្រីចៅក្រម ជាបឋម ខ្ញុំមិនគិតថាអង្គហេតុដែលមេធាវីការពារលើកឡើងនោះ ជាការពិតនោះទេ។ ខ្ញុំមិនៗចាំថាសាក្សីមកពីមជ្ឈមណ្ឌលឯកសារគាត់មិនអល់អែក មិនចង់ទម្លាយពីប្រភពដើម ឬក៏ទីកន្លែងនៃឯកសារនោះទេ ឬក៏ថាអាច -- គឺមានការមានការសន្និដ្ឋានខុសពីការឆ្លើយរបស់ពួកគាត់នោះ ដោយសារថាយើងមានប្រភពឯកសារនោះហើយ ហើយមិនបានយោងទៅរកឯកសារអីជាក់លាក់ក្នុងពីរបីថ្ងៃនេះទេ។ ប៉ុន្តែសំណួរនេះគឺមិនគប្បីតុលាការទទួលយកៗទេ ពីព្រោះថាចង់ឲ្យអ្នកជំនាញចង់ឲ្យគាត់ផ្តល់យោបល់ទៅលើការយល់ឃើញ ឬក៏គំនិតរបស់សាក្សីផ្សេងនោះបាទ។

**លោក អាកទូរ វែកគែន៖**

លោកប្រធាន ខ្ញុំចង់បញ្ជាក់អំពីចំណុចនេះ។ លោក លោកស្រីចៅក្រមជាទីគោរព ខ្ញុំគិតថាព្រះរាជអាជ្ញាគាត់ច្រឡំសំណួររបស់ខ្ញុំហើយ។ ខ្ញុំមិនបាននិយាយថា អ្នកនៅមជ្ឈមណ្ឌលឯកសារនោះគាត់មិនបដិសេធមិនព្រមផ្តល់ប្រភពទេ គឺគាត់មិនព្រមប្រាប់ពីកន្លែងរក្សាទុកឯកសារដើម ខ្ញុំមិននិយាយពីប្រភពទេ។ ខ្ញុំនិយាយពីកន្លែងទុករក្សាឯកសារដើម។ គឺខ្ញុំបានសួរទៅប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាដែលថារក្សាឯកសារដើម រក្សាទុកនៅឯណា ហើយគាត់មិនចង់ឆ្លើយទៅនឹងសំណួររបស់ខ្ញុំនោះទេកាលនោះ។ ដូច្នេះឥឡូវនេះខ្ញុំសួរលោក ឆេនដ៍ល័រ ថាគាត់អាចមានព័ត៌មានពាក់ព័ន្ធទៅនឹងមូលហេតុដែលខាងមជ្ឈមណ្ឌលមិនព្រមប្រាប់ពីកន្លែងទុកដាក់ឯកសារដើមនោះ។

[១០:០៣:១៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០៣:៥៧]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់នៃតំណាងសហព្រះរាជអាជ្ញាធ្វើឡើងមានមូលដ្ឋានត្រឹមត្រូវ ដូច្នេះសេចក្ដីជំទាស់ហ្នឹងមានប្រសិទ្ធភាព។ សំណួរនេះគឺមិនពាក់ព័ន្ធទៅនឹងភាពជំនាញរបស់អ្នកជំនាញរូបនេះទេ អង្គជំនុំជម្រះមិនចាំបាច់ស្ដាប់ចម្លើយអ្នកជំនាញរូបនេះតបទៅនឹងសំណួរនេះទេ។

**លោក អាកទួរ វែកគែន៖**

បើអ៊ីចឹងខ្ញុំសូមចូលទៅសំណួរផ្សេងទៀត។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោក ដេវីដ ឆេនដ៍ល័រ កាលពីថ្ងៃដំបូងៗនៃសវនាការនេះ លោកស្រីចៅក្រម ខាតវ៉ាយថ៍ បានសួរឲ្យលោកផ្ដល់យោបល់មួយចំនួនពាក់ព័ន្ធទៅនឹងកំណត់ហេតុចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលមានចំណងជើងថា ខ្ញុំសូមដកស្រង់៖ "សេចក្ដីសម្រេចរបស់គណៈមជ្ឈិមទៅលើបញ្ហាមួយចំនួន"។ កំណត់ហេតុនេះមិនមានចុះហត្ថលេខាទេ ហើយក៏មិនមានបញ្ជីឈ្មោះអ្នកដែលចូលរួមនោះដែរ។ ហើយដើម្បីបំភ្លឺអំពីស្ថានភាពនោះ លោកស្រីចៅក្រម ខាតវ៉ាយថ៍ បានសួរលោកថា "នៅខែមីនា ឆ្នាំ៧៦ ជនជាប់ចោទដែលនៅទីនេះគាត់មានវត្ត-- គាត់ស្ថិតនៅក្នុងគណៈមជ្ឈិមដែរឬទេ?" សំណួររបស់ខ្ញុំគឺមិនចង់ចោទសួរទៅលើចំណុចជាក់លាក់នោះទេ អ្វីដែលខ្ញុំចាប់អារម្មណ៍នោះ គឺយោបល់ផ្ទាល់របស់លោកទៅនឹងអង្គការ ដែលចេញឯកសារនេះ។ លោកបានឃើញជាច្រើនរួចមកហើយឯកសារហ្នឹង បើសិនជាលោកត្រូវការ ខ្ញុំអាចផ្ដល់ជូនលោកបានមួយច្បាប់។ កំណត់ហេតុនេះ គឺបញ្ជាក់ច្បាស់ថាជាឯកសារគណៈអចិន្ត្រៃយ៍ -- គណៈមជ្ឈិម សូមទោស!។ ក៏ប៉ុន្តែអ្នកស្រាវជ្រាវមួយចំនួនដូចជា ក្រេក អេតឆេសាន់ ជាដើម គាត់បានផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង ឌុច នោះ គាត់បានថាឯកសារនេះមិនមែនមកពីគណៈមជ្ឈិមទេ មកពីគណៈអចិន្ត្រៃយ៍ទេ។ តើលោក លោកអាចមានមតិយោបល់អីពាក់ព័ន្ធទៅនឹងកំណត់ហេតុមួយនេះទេ?

[១០:០៦:៣៧]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតបទៅនឹងសំណួរនេះ! ចាំស្ដាប់អង្គជំនុំជម្រះសម្រេចលើសេចក្ដី

ជំទាស់របស់តំណាងសហព្រះរាជអាជ្ញាទៅលើការតាំងសំណួរនេះជាមុនសិន។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

នេះជាសំណួរសំខាន់ណាស់លោក លោកស្រីចៅក្រម។ នេះគឺជា -- មេធាវីសុំឲ្យអ្នកជំនាញយោងទៅរកចំណុចមួយដែលមិនច្បាស់ដូចជា ចម្លើយរបស់លោក ក្រេក អេតឆេសាន់ គឺថាគាត់មិនអាចដឹងថា ចំណុចផ្នែកណាជា -- បើសិនជាមេធាវីការពារចង់យោងទៅរកឯកសារណាមួយ ឬក៏សៀវភៅរបស់អ្នកជំនាញ សូមឲ្យឃើញពិនិត្យមើលនៅក្នុងបញ្ជី តើមានឯកសារនោះដែរឬអត់? បើសិនជាគាត់យោងទៅរកទៅលើចម្លើយដោយចម្លើយសេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញ ឬក៏សាក្សីផ្សេងនោះគឺមិនគប្បីឲ្យសាក្សីរូបនេះឆ្លើយបញ្ជាក់បានទេ បាទ។

[១០:០៧:៣៣]

**ប្រធានអង្គជំនុំ៖**

បានត្រឹមត្រូវហើយ យើងស្ដាប់នូវការតាំងសំណួររបស់លោកមេធាវី ដូចជាមិនទាន់បានបង្ហាញនូវអត្តសញ្ញាណឯកសារច្បាស់លាស់ទេ។ គ្រាន់តែបង្ហាញនូវឯកសារថ្ងៃទី៣០ ខែ៦ ឆ្នាំ១៩៧៦ ការបង្ហាញបែបប៉ុណ្ណឹង គឺមិនទាន់គ្រប់គ្រាន់ទេ។ គប្បីបង្ហាញអត្តសញ្ញាណនៃឯកសារហ្នឹងឲ្យបានច្បាស់លាស់។ លេខប៉ុន្មានទៅ លេខឯកសារហ្នឹង? ហើយបញ្ហាផ្សេងទៀត គឺសូមបង្ហាញជាលក្ខណៈ -- បង្ហាញអត្តសញ្ញាណឯកសារ ហើយបើអាចធ្វើបាន គឺចំពោះឯកសារដែលមិនទាន់មាន សូមបង្ហាញឲ្យបានត្រឹមត្រូវមុននឹងតាំងសំណួរពាក់ព័ន្ធទៅនឹងអ្នកជំនាញ ឬក៏សាក្សីដទៃទៀត។

**លោក អាកទួរ វែកគែន៖**

បាទ លោកប្រធាន ជាការពិតណាស់ដែលថាខ្ញុំនិយាយដូចប្រញាប់ប្រញាល់ពេក។ ក៏ប៉ុន្តែទន្ទឹមនឹងនោះ គឺថាជាៗឯកសារដែលយើងពិភាក្សាគ្នាហ្នឹង រាប់សប្ដាហ៍មកហើយ។ បាទ គឺក្នុងកំណត់ហេតុនៃសេចក្ដីសម្រេចរបស់គណៈមជ្ឈិមហ្នឹង មានលេខកូដ E3/12។

[១០:០៩:១២]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកមេធាវីជូនទៅសាក្សីពិនិត្យ!

**លោក អាកទូរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** លោក ឆេនដ៍ល័រ តើលោកដឹងអំពីការពិភាក្សាបច្ចេកទេសមួយ ដែលទំនងជាទាក់ទងទៅនឹងអង្គភាពដែលចេញកំណត់ហេតុនេះ តើលោកដឹងដែរឬទេ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** អត់ទេ ដូចដែលបង្ហាញនៅឯកសារនេះ ខ្ញុំមិនដឹងថាការពិភាក្សាជាបច្ចេកទេសរបស់គេនោះដូចម្តេចទេ។ សូមអភ័យទោស ប្រសិនបើលោកចង់និយាយថា មិនមែនជាប្រភពដែលឯកសារនេះដែលយើងលើកខាងដើមទេ ប៉ុន្តែគឺចំណងជើងនៃឯកសារខាងលើនេះ នៅក្នុងន័យនោះខ្ញុំមិនៗដឹងអំពីការពិភាក្សាបច្ចេកទេសដែលនាំឲ្យចេញឯកសារនេះទេ។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមចូលនិយាយប្រធានបទមួយទៀត ខ្ញុំចង់លើកអំពីបញ្ហាទាក់ទងទៅនឹងមន្ទីរ៨៧០ នៅចំពោះមុខតុលាការលោកបានពន្យល់អំពីពាក្យថា “មន្ទីរ៨៧០”?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*។

[១០:១១:២១]

**ប្រធានអង្គជំនុំ៖**

លោកអ្នកជំនាញអត់ទាន់ -- ក្បាលមីក្រូអត់ទាន់ប្រតិបត្តិការទេ លោកមានប្រសាសន៍អំមិញអត់ចូលទៅក្នុងការ -- ប្រព័ន្ធបកប្រែទេបាទ។ រង់ចាំបន្តិចបាទ។

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** សូមអភ័យទោស។ ខ្ញុំត្រូវនិយាយ គឺថាកូនក្តី -- អ៎! កូនស្រីរបស់ខ្ញុំនៅញូវយ៉កគឺថា ក៏ត្រូវប្រយ័ត្នគឺថា ត្រូវប្រយ័ត្ននៅពេលតុលាការ កុំ -- ធម្មតា ហើយខ្ញុំសូមអភ័យទោស ហើយខ្ញុំសូមបំភ្លឺខ្ញុំមិនដឹងថា មេធាវីការពារនិយាយជាភាសាបារាំង ជាភាសាអង់គ្លេស គឺថាមន្ទីរ៨១០ ប៉ុន្តែថាតើកំណត់ត្រាដែលត្រឹមត្រូវនោះ ចង់សួរមន្ទីរ៨៧០ ឬក៏៨១០? ខ្ញុំនឹងចាំស្តាប់សំណួរឡើងវិញ ហើយខ្ញុំនឹងឆ្លើយ។

[១០:១២:០៧]

**ស៖** បាទ ខ្ញុំពិតជានិយាយថា មន្ទីរ៨៧០។ លោកបានពន្យល់ទៅតុលាការអំពីពាក្យនេះ ថាជា

មានន័យថា ជាឈ្មោះកូដដើម្បីសំដៅលើ ប៉ុល ពត ហើយលោកក៏បានពិពណ៌នាផងដែរ មន្ទីរ៨៧០នេះជាកន្លែងមួយដែលរៀបចំឯកសារនៅក្នុងបក្ស។

ខ្ញុំចង់ឲ្យយើងពិនិត្យមើលកំណត់ហេតុមួយទៀតដែលចុះនៅថ្ងៃទី០៩ ខែ១០ ឆ្នាំ១៩៧៥។ លេខឯកសារគឺ E3/182។ ហើយខ្ញុំសូមជូន -- អនុញ្ញាតជូនឯកសារនេះទៅលោកអ្នកជំនាញ។

**លោក អាកឡូវ វែកគែន៖**

លោកប្រធានតើលោកអនុញ្ញាតដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីយកទៅជូនអ្នកជំនាញពិនិត្យ!

[១០:១៣:៥៦]

**សួរដោយលោក អាកឡូវ វែកគែន៖**

**ស៖** បាទ សំណួរខ្ញុំទាក់ទងនឹងទំព័រ២ -- ទី២នៃឯកសារនេះ។ នៅទំព័រនេះ គឺថាយើងអាចសង្កេតឃើញថាមានការបែងចែកតំណែង ហើយពាក្យ “៨៧០” នេះក៏ត្រូវបានគេប្រើពីរដងនៅក្នុងទំព័រនេះ។ នៅចំណុចទី៨ មានសរសេរថា “សមមិត្ត ឌឿន ប្រធានមន្ទីរនយោបាយរបស់៨៧០” ហើយនិងចំណុចទី១២ មានសរសេរគណ: -- “សមមិត្ត យ៉េម ការិយាល័យ៨៧០”។ ខ្ញុំសូមសួរលោកថា តើលោកអាចបែងចែកឲ្យដាច់ពីគ្នារវាងរដ្ឋបាលទាំងពីរនេះ ដែលមានឈ្មោះ ៨៧០ដូចគ្នា? លោកអាចពន្យល់បានទេពីភាពខុសគ្នា?

**ឆ៖** សូមអនុញ្ញាត សូមឲ្យបង្វិលទំព័រលើ អេក្រង់នេះមកខាងឆ្វេងដៃបន្តិចដើម្បីឲ្យខ្ញុំមើលបានឃើញទាំងអស់។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការជួយរៀបចំគាត់បន្តិច!

**លោក ដេវីដ ឆេនដ៍ល័រ៖**

បាទ គឺបង្វិលទៅខាងលើ បាទ ដើម្បីខ្ញុំមើលឯកសារនៅខាងក្រោម។

*(មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលការងារបច្ចេកទេស)*

[១០:១៦:៣៩]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** សូមអរគុណ គឺថាដែលបានបង្ហាញនេះ ខ្ញុំអាច គឺថាមានភាពខុសគ្នារវាងឈ្មោះមន្ទីរ ហើយនិងការិយាល័យនេះមួយដែលថា ឌឿន ឈ្មោះ សឿ វ៉ាស៊ី ហៅ ឌឿន។ ដោយមិនបានជូនដំណឹងជាមុននោះ ខ្ញុំមិនបានរកឃើញថា តើសមមិត្តយ៉ែម ជាអ្នកណាទេ? ជាឈ្មោះកាត់ហ្នឹង? គឺថានេះជាមនុស្សមួយផ្សេង។ តាមអ្វីដែលខ្ញុំដឹង គឺថាឈ្មោះកាត់របស់ ខៀវ សំផន ហ្នឹងគឺថា ដូចដែលលោកដឹងនោះ គឺថាឈ្មោះ យ៉ែម នោះខ្ញុំមិនដឹងថាឈ្មោះពេញគាត់នោះឈ្មោះអ្វីនោះទេ?

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** ក៏ប៉ុន្តែទាក់ទងនឹងការ មុខការរបស់ការិយាល័យទាំងពីរនេះ តើ៨៧០ទាំងពីរនេះ តើលោកដឹងថាការងារការិយាល័យទាំងពីរហ្នឹងខុសគ្នាយ៉ាងម៉េចទេ? ឬក៏លោកមិនអាចនិយាយឲ្យបានលើសពីនេះទេ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំមិនអាចបញ្ជាក់អ្វីលើសពីការសិក្សារបស់ខ្ញុំទេ។ កថាខណ្ឌនៅខាងក្រោមដែលសរសេរនេះ គឺថា គឺការងារធម្មតាដែលបញ្ជូនមកការិយាល័យនេះ មន្ទីរនេះ ប្រហែលជា ប៉ុល ពត អាចនិយាយដោយខ្លួនឯង គឺថាអាចជាការងារក្រដាសស្នាមដ៏ច្រើន ហើយខ្ញុំសន្និដ្ឋានថា តួនាទីរបស់អ្នកទាំងអស់នេះ គឺគ្រាន់តែបញ្ជូនឯកសារឡើងចុះជាកិច្ចការដែលអាចគ្រប់គ្រងបានក្នុងឯកសាររបស់គេនោះ ហើយនៅក្នុងឱកាសមួយចំនួនដែលឆ្លើយទៅនឹងសំណួររបស់លោក។ ខ្ញុំមិនធ្លាប់បានឆ្លើយ។ ខ្ញុំថាឯកសារទាំងអស់ទាក់ទងនឹងបក្សចូលទៅមន្ទីរ៨៧០នោះទេ។ ប្រសិនបើឯកសារទាំងអស់ដែលទាក់ទងនឹងបក្សទៅចូលកន្លែងហ្នឹងគឺថា មន្ទីរនោះគឺអាចនឹងពោរពេញទៅដោយឯកសារ។ គឺថាមានតែឯកសារដែលបញ្ជូនទៅមន្ទីរ៨៧០ទេ ដែលទៅនោះ គឺថាឯកសារទាំងអស់មិនទៅហ្នឹងទេ គឺថាឯកសារភាគច្រើនទៅកន្លែងហ្នឹង។ ប៉ុន្តែមិនមែននិយាយពីឯកសារដែលពាក់ព័ន្ធនឹងបក្សទាំងអស់ត្រូវតែទៅកន្លែងហ្នឹងទេ។ ហើយខ្ញុំមិនអាចឆ្លើយអ្វីលើសពីហ្នឹងបានទេ។

[១០:១៩:០០]

**ស៖** ខ្ញុំបាននិយាយអម្បាញ់មិញនេះ គឺគ្រាន់តែដើម្បីគោរពខ្លឹមសារនៃពាក្យពេចន៍លោករបស់លោកនៅថ្ងៃទី -- នៅខែកញ្ញា -- កក្កដា នេះទេ។ ហើយលោកក៏បាននិយាយផងដែរចំពោះមុខតុលាការថា គំនិតដែល ខៀវ សំផន ជំនួស ឌឿន ជាប្រធានមន្ទីរនយោបាយរបស់៨៧០។ ខ្ញុំចង់ដឹងអំពីប្រភព

ភស្តុតាងដែលលោកមាន តើលោកចង់យោងទៅឯកសារណាក្នុងការបញ្ចេញមតិយ៉ាងដូច្នេះនោះ?

**ឆ៖** ខ្ញុំអាចបានឆ្លើយបាន ថាខ្ញុំអានឯកសារជាច្រើនដែលបានបង្ហាញព័ត៌មាននេះ ប៉ុន្តែខ្ញុំមិនអាចយោងទៅឯកសារជាក់លាក់ ឬក៏ប្រភពជាក់លាក់។ ប៉ុន្តែវាជាព័ត៌មានទូទៅ ហើយខ្ញុំមិនមានមូលហេតុអី ដែលខ្ញុំនិយាយថា ការមិនពិតទេ។ អ្វីដែលខ្ញុំធ្វើឲ្យខ្ញុំដឹងថា ដែលថាចំណុចមួយ ដែលកូនក្តីរបស់លោកបដិសេធ។ អ៊ីចឹងហើយគឺត្រូវតែមានភស្តុតាងផ្ទុយពីហ្នឹង។ អ៊ីចឹងបើមានភស្តុតាង គឺខ្ញុំអាចយកមកថ្លឹងថ្លែងរវាងទាំងពីរនេះ។ ដូច្នេះហើយ នៅក្នុងដំណាក់កាលនេះ គឺខ្ញុំអាចឆ្លើយជូនលោកបានត្រឹមប៉ុណ្ណឹង។

**ស៖** ខ្ញុំមានសំណួរមួយដូចឆ្ងល់ ហើយលោកអាចចោទមកខ្ញុំវិញថា ប្រហែលជាឆ្ងល់មិនសមស្រប។ កាលពីម្សិលមិញ លោកបាន -- សប្តាហ៍មុន ក្នុងពេលមួយនោះ លោកបាននិយាយទាក់ទងនឹងមន្ទីរ៨៧០ ដែលគេកំពុងតែគេ លោកត្រូវបានចោទសំណួរនោះ។ លោកក៏ជំទាស់ក្នុងការបញ្ចេញយោបល់លើការស្រាវជ្រាវរបស់លោក ហេដឌ័រ។ តើខ្ញុំចង់ដឹងពីមូលហេតុនៃការបដិសេធ មិនបញ្ចេញយោបល់នេះ តើលោកមានអ្វីពន្យល់ទេ?

[១០:២១:៣៣]

**ឆ៖** ខ្ញុំមិនគិតថា ខ្ញុំមិនបានបដិសេធទៅ -- មិនឆ្លើយនឹងការងាររបស់លោក ស្ទីវ ហេដឌ័រនោះទេ។ ហើយអ្វីដែលនេះនោះ គឺខ្ញុំផ្អែកទៅលើការគិតគូររបស់ខ្ញុំ គឺថាការអ្វីដែលលោក ហេដឌ័រ គាត់សរសេរនោះ គឺថាវាវិវត្តន៍។ ហើយរីឯអត្ថបទការងាររបស់អ្នកផ្សេង ដែលធ្វើដោយឯករាជ្យនោះ គឺថាឯកសាររបស់ ស្ទីវ នោះជាប្រភពមួយ ក្នុងចំណោមប្រភព តាមទស្សនៈរបស់ខ្ញុំ ដែលថាលោក ខៀវ សំផន គឺជាអ្នកកាន់តំណែងនេះ។ ហើយឯកសារដែលគាត់បានប្រើនោះ ខ្ញុំមិនអាចយកមកបញ្ជាក់ផ្ទៀងផ្ទាត់បានទេ។ ប៉ុន្តែខ្ញុំ -- ខ្ញុំទទួលស្គាល់ស្នាដៃរបស់លោក ស្ទីវ ហេដឌ័រ ហើយដែលមានព័ត៌មានហ្នឹងបាទ។

[១០:២២:៣០]

**ស៖** បាទ ឥឡូវនេះ ខ្ញុំសូមដូរប្រធានបទ ហើយខ្ញុំសូមចោទសំណួរមួយ ទាក់ទងទៅនឹងចម្លើយដែលលោកបានផ្តល់លើប្រធានបទ នៃខ្សែព័ត៌មានដែលទាក់ទង -- ដែលចេញពីមន្ទីរស-២១ ទៅដល់កំពូលនៃកម្ពុជាប្រជាធិបតេយ្យ។ នៅពេលដែលលោក -- គេចោទសំណួរលោកទាក់ទងនឹងបញ្ហានេះ លោកបានរំឭកអំពីចម្លើយរបស់ ឌុច នៅក្នុងការជម្រះសេចក្តីរបស់គាត់ ដែលគាត់ -- ដែលលោកថា

គាត់បានរាយការណ៍ទៅតែ សុន សេន ទេ ហើយគាត់ក៏បាន -- លោកបាននិយាយផងដែរ ថាចម្លើយរបស់លោក នៅថ្ងៃ១៨ កក្កដា គឺថានៅម៉ោង ១៥:២១ ដល់ ១៥:២២ សុន សេន និយាយថា មន្ទីរ ស-២១ នេះ មានសារៈសំខាន់ដើម្បីនិយាយទៅសមាជិកបក្សផ្សេងទៀត។

[១០:២៣:៣៩]

ខ្ញុំចង់សួរលោកថា នៅក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវរបស់លោក តើលោកមានបានរកឃើញ ឬក៏ជួប ឬក៏សិក្សាឯកសារសរសេរកាលពីសម័យនោះ ដែលបង្ហាញថា លោក ខៀវ សំផន បានទទួលព័ត៌មានពី សុន សេន ព័ត៌មានដែលចេញមកពីមន្ទីរស-២១?

**ឆ៖** ទេ ខ្ញុំមិនដែលបានឃើញទំនាក់ទំនងនោះទេ ហើយការបញ្ជូនហ្នឹង គឺថានៅថ្ងៃទី១០ កក្កដា នោះ លោកសរសេរ ការបកប្រែដែល -- គឺមិនមែនថ្ងៃទី១០ទេ គឺថ្ងៃទី២០ ដែលខ្ញុំមក។ ហើយខ្ញុំមិនៗបដិសេធថាមិនឆ្លើយទេ ប៉ុន្តែខ្ញុំចង់ឃើញឯកសារដែលលោកយោងឲ្យបានពិតប្រាកដ។

**ស៖** បាទ ដើម្បីជាប្រតិចារឹក គឺថាថ្ងៃទីមួយ នៃសវនាការនេះ គឺថាថ្ងៃទី១៨ កក្កដា ២០១២។ បាទ សំណួរបន្ទាប់ទៀតរបស់ខ្ញុំនោះ គឺទាក់ទងទៅនឹងថ្ងៃទី១៩ គឺថាថ្ងៃទីពីរ នៃសវនាការយើងនេះ។ គេបានសួរលោកទាក់ទងទៅនឹងចម្លើយ ដែលលោកបានផ្តល់ជូន។ ត្រង់ចំណុចនេះ ខ្ញុំចង់លើកលោកវគ្គមួយដែលលោកបាននិយាយថា ឥឡូវខ្ញុំសូមដកស្រង់ គឺទំព័រ២៩-៣០ ម៉ោង ១០:០៤ ជាភាសាបារាំង "ហាក់ដូចជា រយៈកាលចប់ទសវត្សរ៍ទី៦០នេះ វានៅក្នុងព្រៃទាក់ទងទៅនឹងគោលនយោបាយ ដែលគេអនុវត្តនៅពេលដែលគេចូលទៅកាន់នយោបាយ ជាជាងការចៀសរត់គេចពីប៉ូលិសរបស់ សីហនុ"។ ហើយខ្ញុំ -- តាមពិតទៅ ខ្ញុំមិនសូវយល់ចម្លើយរបស់លោក ចម្លើយដែលលោកបានឆ្លើយជូនមកនេះ។ ខ្ញុំកាន់តែមិនយល់ទៀតនៅពេលដែលខ្ញុំប្រៀបធៀបចម្លើយហ្នឹង ទៅអ្វីដែលលោកបានឆ្លើយនៅពេលក្រោយ គឺថាលោកបាននិយាយពេលក្រោយមកថា "ដោយសារតែការរត់ចូលព្រៃរបស់ពួកគាត់នោះ អ្នកដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានគេចផុតពីការជាប់គុករបស់ស្តេច"។ ហើយលោកក៏បាននិយាយផងដែរ ពីការគាបសង្កត់នៅ -- ការបះបោរនៅសំឡូត ហើយលោកក៏បាននិយាយផងដែរថា "បើសិនជាមិនមានការគាបសង្កត់ដ៏តឹងរ៉ឹងយ៉ាងដូច្នេះទៅលើលោក ខៀវ សំផន ទេ លោក ខៀវ សំផន ក៏មិនចូលព្រៃម៉ាគីដែរ"។ អ៊ីចឹង ខ្ញុំមិនយល់ទេ ខ្ញុំចង់ឲ្យពន្យល់ពីភាពចម្រូងចម្រាសនេះ តើលោកបដិសេធ ឬក៏លោកចង់និយាយអំពីការគាបសង្កត់ដ៏ធ្ងន់ធ្ងរទៅលើការបះបោរនៅសំឡូត ឬក៏ការគំរាមកំហែងទៅលើលោក ខៀវ សំផន ដែលធ្វើឲ្យគាត់រត់ចូលព្រៃ -- ចេញពីភ្នំពេញរត់ទៅចូលព្រៃ? ឬក៏ការយល់របស់ខ្ញុំ

នេះ ខ្ញុំស្តាប់យល់ច្រឡំទេ?

[១០:២៦:០២]

**ឆ៖** ខ្ញុំបានអានទៅលើឯកសារដែលខ្ញុំបានចងក្រងបន្ទាប់ពីវគ្គនេះ ខ្ញុំបានពិនិត្យឃើញថា គឺថា អាច សីហនុ អាចចោទប្រកាន់ដែលថា គាត់មានការពាក់ព័ន្ធទៅនឹង គឺថា ហេតុការណ៍នៅសំឡូត ហើយលោក ខៀវ សំផន -- ខ្ញុំមិនអាចឆ្លើយជំនួសគាត់បានទេ។ ប្រយោគបែបនេះ ដែលធ្វើឲ្យគាត់មានការភ័យខ្លាច គឺថា ដោយមានការឆ្លើយដាក់គឺថា អាចនឹងបញ្ជាក់ពី អ្នកណាដែលពាក់ព័ន្ធ គឺថានឹងត្រូវជាប់គុកប៉ុន្មានឆ្នាំជាដើម។ អាហ្នឹងគឺជាកត្តាដែលបង្ខំឲ្យ ខៀវ សំផន ហើយខ្ញុំយល់ថា ពេលនោះគាត់ចង់ធ្វើការនៅភ្នំពេញ ក៏ប៉ុន្តែគាត់ត្រូវបង្ខំចិត្ត ឬក៏ដោយប្រការអីមួយ គាត់ត្រូវតែរត់ទៅចូលព្រៃម៉ាគី។

**ស៖** បាទ ទាក់ទងនឹងរយៈកាលនេះដដែល ក្នុងសៀវភៅរបស់លោក “សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា” ដែលមានលេខឯកសារ D108/50/1.75 ជាភាសាអង់គ្លេស អត់មានបកប្រែជាភាសាខ្មែរនោះទេ គឺថា អង់គ្លេសគឺទំព័រ១៦៧ ERN 00193250។ បាទលោកបានលើកឡើងអំពីការកាន់ទុក្ខរបស់និស្សិតចំនួន១៥ពាន់នាក់ ដែលអំពីការដែលលោក ខៀវ សំផន បានទទួលមរណភាព។ សំណួររបស់ខ្ញុំចង់ដឹងថា តើស្ថានភាពនេះ ចំពោះលោកនោះអាចជាជំរុញឲ្យ ប៉ុល ពត ឆ្លៀតឱកាសយកចំណេញពីប្រជាប្រិយភាពរបស់លោក ខៀវ សំផន តើអាចអ៊ីចឹងទេចំពោះលោក?

[១០:២៩:២៦]

**ឆ៖** ខ្ញុំមិនឯកភាពជាមួយការអះអាងនេះទេ។ មិនមានភស្តុតាងគាំទ្រ។ ខ្ញុំភ្លេចកាលបរិច្ឆេទ សូមទោស ហើយលោក ខៀវ សំផន នៅក្នុងសម័យកាលនេះគឺ គាត់ជាបេក្ខភាពនៅក្នុងមណ្ឌលបោះឆ្នោតនោះគាត់បាន -- គាត់ឆ្លើយតប ហើយនិងយកចិត្តទុកដាក់នៅក្នុងការលំបាកនៅក្នុងតំបន់ ហើយខ្ញុំបានជួបមនុស្សមួយ -- ច្រើននៅក្នុងតំបន់បោះឆ្នោតរបស់គាត់ ហើយខ្ញុំ -- ហើយមនុស្សទាំងអស់នោះយល់ថា នេះគឺជាតំណាងរាស្ត្រដែលមានភាពស្មោះត្រង់ខុសពីអ្នកធម្មតា ហើយខ្ញុំមិនគិតថាបក្សកុម្មុយនីស្តកម្ពុជាជាអ្នករៀបចំបែបនោះទេ គឺពេលនោះ គឺថាបក្សកុម្មុយនីស្តកម្ពុជា ថ្នាក់ដឹកនាំនៅរតនគិរី ហើយយើងឃើញទូរលេខមួយចំនួន ដែលថាបញ្ជូនទៅនៅថ្នាក់កណ្តាលនៅ -- ដែលអាចនឹងកៀងគរកងកម្លាំង ឬក៏និស្សិត ១៥.០០០នាក់នេះទេ។ គឺថា -- ប៉ុន្តែវាអាចឲ្យជឿជាក់ថាគេប្រកាសថាលោក ខៀវ សំផន ត្រូវបានគេសម្លាប់។ ហើយប៉ុន្តែខាងខ្មែរក្រហមគេមិនដែលទទួលស្គាល់ថាមានការចាប់ខ្លួនជំនុំជម្រះ ឬសម្លាប់នោះទេ គេគ្រាន់តែដឹងថាគាត់បាត់ខ្លួន។ ហើយការបាត់ខ្លួនរបស់គាត់ធ្វើឲ្យស្ថាប័ន

ឬក៏ក្រុមបញ្ញវន្តមានការតក់ស្លុត ឬក៏ថាភ្ញាក់ផ្អើល។ នេះគឺជាប្រវត្តិនៃទំនាក់ទំនងរវាង ប៉ុល ពត និង ខៀវ សំផន ដែលបង្ហាញថា ប៉ុល ពត មានការព្រួយបារម្ភអំពីវិទ្ធង្សនា ដោយប្រជាប្រិយភាពរបស់ ខៀវ សំផន ទេ។ ប៉ុន្តែសម្តេច សីហនុ មិនចូលចិត្តពីប្រជាប្រិយភាពរបស់លោក ខៀវ សំផន ទេ។ ខ្ញុំ មិនអាចនិយាយជំនួសអ្នកទាំងអស់នោះទេ សូមអភ័យទោស។ ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ។

[១០:៣១:២៣]

**ស៖** បាទ តាមពិតទៅលោកឆ្លើយនឹងសំណួររបស់ខ្ញុំ យ៉ាងពិតប្រាកដត្រឹម ច្បាស់លាស់ហើយ។ តាមពិតទៅ ខ្ញុំនេះសួរមិនសូវល្អទេ។ ហើយៗខ្ញុំមិនបានប៉ាននិយាយថា ការកាន់ទុក្ខរបស់និស្សិតទាំង ១៥.០០០នាក់ នេះ ដែលនៅខេត្តកណ្តាលនោះត្រូវបានបង្វិលដូចកូនអុក អំពីសំណាក់បក្សនោះទេ។ នេះ បើតាមពិតនេះអ្វីដែលខ្ញុំលើកឡើងនេះ គ្រាន់តែជាលើកពីឧទាហរណ៍អំពីប្រជាប្រិយភាពរបស់លោក ខៀវ សំផន នោះទេ។

ឥឡូវនេះ ខ្ញុំសូមឲ្យលោកត្រឡប់ទៅនិយាយអំពីស្ថានភាពនៅសម័យនោះ ស្ថានភាពនៃប្រជា-ប្រិយភាពរបស់លោក ខៀវ សំផន។ អ៊ីចឹងហើយបានជាខ្ញុំឲ្យឧទាហរណ៍នេះ ទាក់ទងនៅនឹងខេត្ត កណ្តាលនេះ។ គ្រាន់តែចង់និយាយថាប្រជាប្រិយភាពរបស់លោក ខៀវ សំផន នោះវាអាចធ្វើឲ្យខាង ផ្នែកនយោបាយខ្មែរក្រហមនោះចាប់អារម្មណ៍ តើអ៊ីចឹងមែនទេ?

**ឆ៖** ហើយកាយវិការយ៉ាងហ្នឹង គេប្រើពាក្យថា "ខ្មោចទាំង៣"។ តាមខ្ញុំៗយល់ថា នេះគឺធ្វើការ ងារតាមការដឹកនាំរបស់បក្ស គឺថារស់នៅ គឺថាដោយចំហ។ ប៉ុន្តែធ្វើការបម្រើរណសិរ្សតាមដែលអាច ធ្វើទៅបាន គឺថាគោល -- ត្រូវគោរពទៅតាមគោលបំណងទូទៅ គឺថាប្រជាប្រិយភាពរបស់គាត់គឺធ្វើ ឲ្យៗមេដឹកនាំសប្បាយចិត្ត។ យើងមិនមានអ្វីបង្ហាញទេ ប៉ុន្តែៗគេមិនដែលប្រើភាសាហ្នឹងថា ការងារ ហ្នឹងធ្វើការល្អមិនល្អ គេមិនដែលសរសើរទេ។ ប៉ុន្តែការងារដែលគេធ្វើល្អ នៅក្នុងឆ្នាំ១៩៦៧នោះ គឺវា ចោទជាបញ្ហាមួយថា ខៀវ សំផន គឺមិនបានគ្រោងទុកទេ គឺគាត់មានភ័យខ្លាចដោយភាសាដែលសម្តេច សីហនុ ប្រើចំពោះគាត់ដែលថា ដែលជាកត្តាធ្វើឲ្យគាត់គិតថា "បើខ្ញុំនៅយូរ ហើយខ្ញុំ -- គេនឹងយកខ្ញុំទៅ ដាក់គុក"។

[១០:៣៣:៣៤]

ដូច្នេះហើយខ្ញុំបានសម្ភាសមនុស្សមួយចំនួននៅពេលសរសេរសៀវភៅនោះ គឺថាបារាំងម្នាក់ ដែលនៅកៀកសម្តេច សីហនុ នោះគាត់បានប្រាប់ថាលោក ខៀវ សំផន ទៅជួបគាត់ ហើយជាមួយនឹង

មិត្តភក្តិម្នាក់របស់គាត់។ ហើយមុនពេលដែលគាត់ចាកចេញគឺថា គាត់ប្រាប់អ្នកដែលខ្ញុំសម្ភាសនោះថា ខ្ញុំ -- លោក ខៀវ សំផន ថា “ខ្ញុំត្រូវតែចេញពីក្រុង សូមទោស”។ នេះគាត់និយាយថា ត្រូវតែនិយាយថា *អូរីវ័រ* ហើយអ្នកដែលខ្ញុំសម្ភាសនោះគឺថា នោះគឺជាឱកាសមួយដែលទុក្ខព្រួយដោយសារថាលោក ខៀវ សំផន គឺជិតស្និទ្ធជាមួយនឹងមិត្តភក្តិបារាំងរបស់គាត់នោះឯង។ ហើយ ប៉ុន្តែ ហើយនៅកាលនោះ គឺអ្នកសម្ភាសមិនបង្ហាញខ្ញុំថា គាត់វំពូកពីបក្សកុម្មុយនីស្តកម្ពុជាទេ គាត់គ្រាន់តែថា គាត់ចេញទៅតែប៉ុន្នឹង។

**ស៖** ឆេនដ៍ល័រ កាលនោះគាត់មិនមែនជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជាទេ អ៊ីចឹងហើយបានខ្ញុំវាឆ្ងល់។ លោកពណ៌នាលោក ខៀវ សំផន ហាក់ដូចជាអ្នកធ្វើការចំពោះបក្ស ហើយនិងធ្វើយ៉ាងណាឲ្យបក្សពេញចិត្ត។ តែចំពោះខ្ញុំវិញ ខ្ញុំដូចជាឆ្ងល់អំពីការពណ៌នាលើលោក ខៀវ សំផន នេះ ហើយខ្ញុំចង់ដឹងថា តើលោកយោងទៅលើប្រភពណាដែរ ហើយដើម្បីធ្វើការវិភាគរបស់លោកនេះ?

[១០:៣៥:០០]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលឆ្លើយតប!

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

ពាក់ព័ន្ធទៅនឹងមេធាវីការពារក្តី ដែលគាត់សួរទៅនឹងសម្ភារៈនោះ យើងមិនជំទាស់ទៅលើការសួរសំណួរនោះទេ។ ក៏ប៉ុន្តែយើងមិនអាចសួរការដាក់ជាឧទាហរណ៍ ដឹកនាំមុខទៅដល់លោកសាស្ត្រាចារ្យ អំពីថាតើបញ្ហាគាត់គួរសរសើរនៅក្នុងមិនមែនជាសមាជិកបក្សកុម្មុយនីស្តនោះ គឺយ៉ាងណានោះឡើយ។

[១០:៣៥:៣៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៦:១៥]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាធ្វើឡើងមានមូលដ្ឋានត្រឹមត្រូវ។ ដូច្នេះសេចក្តីជំទាស់ហ្នឹងមានប្រសិទ្ធភាព។ លោកមេធាវីបើសិនជាមានបំណងក្នុងការតាំងសំណួរលើបញ្ហាដដែលនេះ សូមរៀបចំសំណួរឲ្យបានត្រឹមត្រូវ និងសមស្របក្នុងការតាំង --

សួរចំពោះអ្នកជំនាញ។

**លោក អាកទួរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោក ផេនដ៍ល័រ គេបកប្រែចម្លើយរបស់លោកអម្បាញ់មិញនេះថា មុនពេលដែលលោក ខៀវ សំផន ចេញទៅចូលព្រៃ លោកពិពណ៌នាសកម្មភាពរបស់គាត់នោះ ដូចជាសកម្មភាពរបស់អ្នកដែលគោរព -- ស្តាប់បង្គាប់បក្ស។ អ៊ីចឹងសំណួរខ្ញុំគឺថា ចង់សួរលោកថា នៅក្នុងទស្សនៈរបស់លោកមុនឆ្នាំ១៩៧០នោះ -- ៦៧ តើលោក ខៀវ សំផន នោះជាសមាជិកបក្ស ឬក៏យ៉ាងណា? ហើយបើសិនជាអ៊ីចឹងមែន តើលោកលោកមានធាតុផ្សំអ្វីណាទេ ដើម្បីទាញបញ្ចេញគំនិតបែបនេះនោះ?

[១០:៣៧:៥១]

**លោក ដេវីដ ផេនដ៍ល័រ៖**

**ឆ៖** នេះគឺជាការសន្និដ្ឋាន ហើយនិងសំណួរមុនរបស់លោក គឺមានការពិបាកដែលថាខ្ញុំនិយាយតាមឃ្លារបស់លោក។ គាត់មិនមែនជាសមាជិកបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំនោះទេ។ យើងមិនមានព័ត៌មានពាក់ព័ន្ធថាអ្នកណាគេខ្លះ ជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏មិនមែននោះទេ។ វាជាព័ត៌មានសម្ងាត់។ យើងដឹងហើយថា យើងមិនអាចធ្វើការទស្សន៍ទាយនោះទេ។ យើងដឹងហើយថាបុគ្គលនេះជាសមាជិកបក្សកុម្មុយនីស្តបារាំង ហើយទស្សនវិស័យរបស់គាត់នោះ គឺគាត់បានគិតគូរអំពីប្រវត្តិសាស្ត្រ ហើយក្រោយមកគឺគាត់មានទំនាក់ទំនងជាមួយនឹងសមាជិកបក្សកុម្មុយនីស្តកម្ពុជា នៅសាលាកម្ពុជបុត្រ។ ហើយយើងដឹងហើយថា ទោះបីជាអ្នកទាំងអស់នោះមិនមែនជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជានៅពេលនោះក៏ដោយ ប៉ុន្តែពួកគេធ្វើការងារដើម្បីជាផលប្រយោជន៍ទៅដល់គណបក្សនោះ។ នេះជា១ចំណុចមួយដែលគេបានដឹងជាទូទៅ។ ខ្ញុំត្រូវតែធ្វើការពិនិត្យមើលឲ្យបានលម្អិតឡើងវិញទៅលើចំណុចនេះ។ វាមិនអាចលើកឡើងថា ខៀវ សំផន គឺជាបុគ្គលដែលងាកទៅខាងឆ្វេងនិយមហើយជាអ្នកសេរីនិយមនោះទេ។ គឺគាត់បានផ្តាច់ចេញពីចលនាកុម្មុយនីស្តអន្តរជាតិ ហើយគឺគាត់បានធ្វើការកាត់ផ្តាច់នៅក្នុងចលនានេះ។ ហើយក៏គាត់បានចូលរួមចលនាជាមួយនឹងបុគ្គលមួយចំនួនទៀតមកពីប្រទេសបារាំង ដូចជា សុន សេន, អៀង សារី, ប៉ុល ពត។ នៅពេលដែលត្រឡប់មកប្រទេសកម្ពុជាវិញ គឺគាត់បានចូលរួមជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា។

[១០:៤០:១០]

ដូច្នេះនៅពេលដែលយើងនិយាយថា គាត់មិនបានធ្វើសកម្មភាពទាំងអស់នេះ ដោយសារតែគាត់មិនមែនជាសមាជិកបក្សកុម្មុយនីស្តកម្ពុជានោះ គឺវាពិបាកលើកឡើងដូច្នេះណាស់។ យើងដឹងហើយថាបញ្ហាទាំងអស់នេះ សមាជិកបក្សកុម្មុយនីស្តកម្ពុជានេះ គឺគេបានលាក់ការសម្ងាត់ ក៏ប៉ុន្តែយើងមិនអាចចោទប្រកាន់ទៅលើ ខៀវ សំផន ដែលថា ដោយសារបទល្មើសទាំងអស់នោះហើយ ដែលនាំឲ្យគាត់រត់ចូលព្រៃ រត់គេចខ្លួននោះ។ គាត់បានរត់ទៅទីជនបទ ហើយនៅពេលនោះគឺចែដន្យជួប តាម៉ុក តែម្តង។

នេះគឺជាផ្នែកនៃចំណុចមួយដែលថា យើងពេលខ្លះទៅមិនគួរឲ្យជឿដែរ ដែលថា នៅពេលដែលគាត់រត់គេចខ្លួននោះ គឺគាត់ចាប់ផ្តើមបង្កើតទំនាក់ទំនងជាមួយនឹងក្រុម ដែលគាត់ពុំធ្លាប់មានទំនាក់ទំនងពីមុនមក។ នេះគឺជាចំណុចចម្លើយរបស់ខ្ញុំ ដែលឆ្លើយទៅនឹងសំណួររបស់លោក ទោះបីជាខ្ញុំគិតថា មិនជាការឆ្លើយទៅគប្បី ឬក៏ល្អចំពោះលោកក៏ដោយ។

[១០:៤១:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅនេះរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមុននឹងសម្រាកអង្គជំនុំជម្រះសូមសួរទៅលោកមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន តើលោកត្រូវការពេលវេលាប៉ុន្មានទៀតក្នុងការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ?

**លោក អាកទូរ វ៉ែកកែន៖**

បើពេលត្រឡប់មកវិញនោះ បានខ្ញុំអាចឆ្លើយតបនឹងសំណួររបស់លោកប្រធានបាន លោកប្រធាន។ ទាល់ខ្ញុំពិនិត្យមើលសំណួររបស់ខ្ញុំសិន ខ្ញុំអត់ប៉ានឆ្លើយតបទៅនឹងលោកប្រធានឥឡូវទេលោកប្រធាន។

[១០:៤២:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់។ ប៉ុន្តែជម្រាបលោកថា លោកមិនអាចប្រើប្រាស់ពេលវេលាហួសពីពេលសម្រាកអាហារថ្ងៃត្រង់ទេ។ ដូច្នេះសូមលោករៀបចំនូវការសំណួររបស់លោក ធ្វើយ៉ាងណាដើម្បីប្រើប្រាស់ឲ្យមានប្រសិទ្ធភាពនូវពេលវេលាដែលនៅសេសសល់សម្រាប់លោកនេះ។

សម្រាក -- មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅកន្លែងបន្ទប់សម្រាករបស់សាក្សី/ជំនាញ ដល់អ្នកជំនាញ ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤៣ នាទី ដល់ម៉ោង ១១:០១ នាទី)*

[១១:០១:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកទួរ វែកគែន៖**

**ស៖** លោកដេវីដ ឆេនដ៍ល័រ ខ្ញុំចង់ត្រឡប់មកចំណុចដែលយើងនិយាយមុនពេលឈប់សម្រាកវិញ។ គេឲ្យលោករៀបរាប់អំពីយោបល់ ដែលខ្ញុំគិតថាមានភាពចម្រូងចម្រាសគ្នា គឺម្ខាងលោកបានលើកឡើងថា ឋានៈជាសមាជិកបក្សគឺជាបញ្ហាសម្ងាត់។ ហើយលោកក៏បានមិនបានបញ្ជាក់ច្បាស់លាស់អំពីកាលបរិច្ឆេទ ហើយទន្ទឹមគ្នានឹងដែរ លោកក៏បានលើកឡើងថា ទោះបីជាមានការសម្ងាត់នេះក៏ដោយ គឺលោកបានរៀបរាប់អំពីលោកខៀវ សំផន មុនឆ្នាំ៦៧ ថាជាអ្នកដែលធ្វើការឲ្យបក្សរួចទៅហើយ។ ទោះបីជាថាមានការសម្ងាត់ពាក់ព័ន្ធទៅនឹងសមាជិកភាពនេះក៏ដោយ។ ដូច្នេះ ខ្ញុំគិតថា ដូចជាមានភាពផ្ទុយគ្នា ហើយខ្ញុំចង់ដឹងថាតើលោកបានប្រភពមកពីណាដើម្បីយកមកធ្វើការរៀបរាប់បែបនេះនោះ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** សូមអរគុណ។ ខ្ញុំសង្ឃឹមថាមិនមានការផ្ទុយគ្នានោះថា ភស្តុតាងដែលថា ភស្តុតាងថា

សមាជិកសម្ងាត់នោះមិនមានទេ។ ប៉ុន្តែការសន្និដ្ឋានរបស់ខ្ញុំ ខ្ញុំធ្វើឲ្យយល់ថាគាត់ជាសមាជិកនៅពេលហ្នឹង គឺថាចេញមកពីអ្វី ជីវិតរបស់គាត់គឺដោយថា គាត់មានភាពស្មោះត្រង់ជាដើម។ តាមពិត ខ្ញុំអាចបញ្ជាក់ថា ជំហររបស់ខ្ញុំ វាអាចថាគាត់ស្ថិតនៅក្នុងអត្ថប្រយោជន៍របស់បក្ស គឺថាក្នុង មិនទាន់ដាក់បញ្ចូលជាក្នុងភ្លាមទេ គឺគ្រាន់ចាត់ទុកថា ឲ្យគាត់ដើរតួជួរមុខ ដើម្បីទាក់ទងនឹងគោលនយោបាយនេះ វាឆ្លុះបញ្ចាំងអំពីអង្គហេតុ គឺថា គេមិនដាក់ចូលទៅក្នុងគណៈមជ្ឈិមរហូតទាល់តែឆ្នាំ១៩៧១។ អ៊ីចឹងនោះគាត់ថាគាត់ក្លាយទៅជាអ្នកបម្រើបក្សហ្នឹងតាំងពីឆ្នាំមួយពាន់ប្រាំបួនរយ -- មុនឆ្នាំ៧១ នោះមកម្ល៉េះ។

[១១:០៥:៤៧]

ប៉ុន្តែខ្ញុំយល់ថា ដូចជាអ្នកផ្សេងទៀត ដែលមកពីបារាំងដែរ ដែលចូលបក្សកុម្មុយនីស្តបារាំងហ្នឹង ហើយបានធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធនៅក្នុងសាលានៅក្នុងភ្នំពេញ ថា -- ហើយពេលខ្លះគឺគាត់ធ្វើការតែម្នាក់ឯង ដែលថា ដែលលាក់កំបាំងពីអាទិភាពរបស់បក្សកុម្មុយនីស្តកម្ពុជាអំពីវិធីដែលគាត់ធ្វើការងារហ្នឹង។ ហើយពេលខ្លះមានការប្រជុំសម្ងាត់ គឺមិនមានភស្តុតាងថានៅក្នុងឆ្នាំ១៩៦០ហ្នឹង គឺថាមានការប្រជុំបក្ស ហើយគាត់ គេមើលឃើញថាក្រុមការងាររបស់គាត់ដែលមកពីបារាំង ក្រោយមកក៏ចូលជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាទាំងអស់។ ហើយមិនមានអ្វីដែលធ្វើឲ្យខ្ញុំមិនច្បាស់អំពីរឿងនេះទេ ប៉ុន្តែព័ត៌មានតែប៉ុណ្ណឹង។ ហើយខ្ញុំអាចនឹងឆ្លើយបែបនោះ គឺថាគាត់ជាអ្នកធ្វើការរួមជាមួយអ្នកផ្សេងទៀតបង្រៀននៅក្នុងសាលាដដែលជាដើមអីហ្នឹង។

**ស៖** ខ្ញុំគិតថាយើងអាចជជែកគ្នាដោយគ្មានទីបញ្ចប់ទេ ចំពោះចំណុចនោះ ពីព្រោះថាយើងគិតថាយើងប្រហែលជាយើងអាចស្មាន។ ដូច្នេះបើសិនជាខ្ញុំចេះតែបន្តទៅទៀតទៅលើចំណុចហ្នឹង គឺថាមិនងាយនឹងចប់ទេ។ ដូច្នេះ ខ្ញុំសូមចូលទៅចំណុចមួយទៀត ដែលថាមិនឃ្លាតឆ្ងាយពីចំណុចមុនប៉ុន្មានទេ គឺពាក់ព័ន្ធទៅនឹងកិច្ចប្រជុំរបស់គណៈមជ្ឈិម។ នៅសវនាការនេះ លោកបានឆ្លើយថា បើតាមលោកនោះ គឺសេចក្ដីសម្រេចក្នុងការជម្លៀសប្រជាជនចេញពីភ្នំពេញនោះ គឺត្រូវបានធ្វើឡើងដោយគណៈមជ្ឈិម ដែលបានប្រជុំនៅខែកុម្ភៈ ឆ្នាំ៧០ -- សូមទោស ខែមេសា ឆ្នាំ៧៥។ គឺលោកបាននិយាយនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ គឺថាសាធារណជនដឹងច្បាស់ណាស់ ថាយើងរកឃើញបាននៅក្នុងប្រភពជាច្រើន ដែលបញ្ជាក់ពីការសម្រេចជម្លៀសប្រជាជននេះ។

[១១:០៧:១៥]

ដូច្នេះសំណួរខ្ញុំ គឺថាតើមានធាតុផ្សំរូបិយអ្វីខ្លះ ដែលអាចឲ្យលោកបញ្ជាក់បានថាសេចក្ដីសម្រេច

ជម្លៀសប្រជាជននោះគឺត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិមនោះ?

**ឆ៖** ផ្អែកតាមសក្ខីកម្មដែលលោកបានលើកឡើងនោះ គឺថាដោយផ្អែកលើប្រតិចារឹក ខ្ញុំបានៗបានស្តាប់ឮហើយ ខ្ញុំផ្អែកការសន្និដ្ឋាននោះ គឺថាការប្រជុំនៅខែកុម្ភៈ ស្តី -- ដែលថាការបោះពុម្ពផ្សាយដោយ ប៉ែន យៀរនិន គាត់បានសម្ភាសជាមួយមនុស្សមួយចំនួនដែលបានចូលរួមក្នុងកិច្ចប្រជុំនោះ។ ដែលបានចូលរួមក្នុងប្រជុំធំ បន្ទាប់ពីការប្រជុំគណៈមជ្ឈិមនេះមក។ ហើយ ប៉ែន យៀរនិន មិនបានសម្ភាសជាមួយអ្នកដែលចូលរួមក្នុងកិច្ចប្រជុំគណៈមជ្ឈិមហ្នឹងទេ។ នេះជាការចងចាំរបស់ខ្ញុំ ខ្ញុំអាចខុស។

[១១:០៨:៤០]

**ស៖** ខ្ញុំសូមទោស ខ្ញុំកំពុងតែចាំ ព្រោះខ្ញុំគិតថាការបកប្រែជាភាសាបារាំងនេះដូចជាមិនសូវច្បាស់សោះ។ ខ្ញុំមិនសូវយល់អំពីអ្វីដែលលោកបានលើកឡើងអម្បាញ់មិញនេះពាក់ព័ន្ធទៅនឹងកិច្ចប្រជុំ។ តើលោកអាចនិយាយម្តងបានទៀតទេ ម្តងទៀតបានទេ ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំទូលាយនេះ? ព្រោះអម្បាញ់មិញនេះ លោកនិយាយអំពីគណៈមជ្ឈិម ឬក៏ស្អីផ្សេងទៀត។ ខ្ញុំដូចជាមិនសូវយល់ទេ សូមឲ្យលោកបញ្ជាក់ម្តងទៀត។

**ឆ៖** នេះជាវិធីដែលគេប្រជុំ ដែលគេធ្វើការប្រកាសសេចក្តីសម្រេច គឺមិនមែនជាការប្រជុំធ្វើសេចក្តីសម្រេចទេ។ តាមដែលខ្ញុំបញ្ជាក់នោះ ខ្ញុំៗមិនបានដឹងពីលក្ខណៈពិសេសនៃកិច្ចប្រជុំនោះដោយខ្លួនឯងនោះទេ។

**ស៖** តើលោកដឹងទេ ថាអ្នកនិពន្ធផ្សេងៗទៀត ឧទាហរណ៍ដូចជា ហ្វីលីព ស្សត គាត់មិនបានបញ្ចេញមតិដូចគ្នាទេ ពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទនៃការធ្វើសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះ?

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមជំទាស់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា! សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

ដោយមូលហេតុ ដូចខ្ញុំជំទាស់ខាងដើម គឺថាការយោងដោយស្រពេចស្រពិល ទៅរកទស្សនៈ

របស់អ្នកជំនាញផ្សេងទៀត ដោយមិនបានយោងទៅរកប្រភពជាក់លាក់ ដែលមានសារប្រយោជន៍ ហើយមិនអាចនឹងបានភស្តុតាងសម្រាប់សាលាដំបូងទេ ប្រសិនបើមេធាវីការពារយោងទៅរកសំណេរ របស់ ហ្វីលីព ស្សូត គឺសូមបង្ហាញឯកសារជាក់លាក់។ ហើយឯកសារនៅក្នុងបញ្ជី ឬក៏នៅក្នុងកន្លែង ណា ហើយយើងមិនអាចឲ្យមេធាវីសង្ខេបមតិយោបល់របស់អ្នកផ្សេងទៀត ដើម្បីអ្នកជំនាញរូបនេះ ឆ្លើយបញ្ជាក់នោះទេបាទ។

[១១:១១:០៧]

**លោក អាកទូរ វែកគែន៖**

លោកប្រធា!ន យើងកំពុងតែសួរអ្នកជំនាញ គឺគាត់ជាអ្នកដែលបានដឹងអំពីព័ត៌មានជាច្រើន ពាក់ព័ន្ធទៅនឹងអង្គហេតុ។ ហើយគាត់បានបញ្ជាក់ហើយ ថាតាំងពីគាត់មកផ្តល់សក្ខីកម្មនេះ ថាគាត់ ទទួលបានព័ត៌មាន ជួនកាលទៅវាមានលក្ខណៈផ្ទុយ។ ដូចថាអាចមានព័ត៌មានផ្ទុយគ្នា ពាក់ព័ន្ធទៅនឹង រឿងហេតុណាមួយ។ ដូច្នេះ ខ្ញុំអាចផ្តល់សៀវភៅរបស់លោក ហ្វីលីព ស្សូត នេះបាន ក៏ប៉ុន្តែដើម្បីឲ្យ មានភាពងាយស្រួលនោះ ខ្ញុំគ្រាន់តែសួរគាត់ ថាតើគាត់ដឹងអំពីទ្រឹស្តីផ្សេងទៀត ធ្វើអ៊ីចឹង ដើម្បីឲ្យយើង អាចឈានទៅមុខបានលឿន។ ហើយអ៊ីចឹងទៅ គឺថាខ្ញុំមិនចាំបាច់ថា ត្រូវតែផ្តល់ឯកសារយោងជានិច្ច នោះទេ។ ពីព្រោះថាគាត់ ក៏គាត់បានដឹងច្បាស់ហើយ ពីសៀវភៅរបស់លោក ហ្វីលីព ស្សូត នេះ។ ទោះបីជា យ៉ាងណាក៏ដោយ នៅក្នុង *អាំងទែរហ្សាស* គឺលេខឯកសារ E3/9, ERN ជាភាសាបារាំង 00639458, អង់គ្លេស 00361999, ជាភាសាខ្មែរ 00 --

[១១:១២:៥០]

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យមេធាវីគាត់អាន ERN ជាភាសាខ្មែរម្តងទៀត។

[១១:១៣:០០]

**សួរដោយលោក អាកទូរ វែកគែន៖**

**ស៖** ហើយឯកសារនេះ មានចំណងជើងថា "ប្រវត្តិនៃសុបិនអាក្រក់របស់ ប៉ុល ពត"។ ខ្ញុំសូម អានជាភាសាអង់គ្លេស ពីព្រោះថាសៀវភៅនេះ ជាសរសេរជាភាសាអង់គ្លេស។

**ប្រធានអង្គជំនុំ៖**

លោកអានលេខ ERN ជាភាសាខ្មែរឡើងវិញ ពីព្រោះគ្មានការបកប្រែទេ។ ព្រោះអ្នកបកប្រែ

ស្តាប់លោកមានប្រសាសន៍មិនទាន់ទេ។

**លោក អាកខ្វូរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាកខ្វូរ វែកគែន៖**

**ស៖** ERN ជាភាសាខ្មែរ 00755581។ ខ្ញុំសូមដកស្រង់៖ “នៅដើមឆ្នាំ១៩៧៤ នៅពេលដែលសេចក្តីសម្រេចត្រូវបានឡើង ដើម្បីជម្លៀសទីក្រុងភ្នំពេញ”។ លោក ឆេនដ័ល័រ តើលោកបានដឹងអំពីអាទិភាពនៃកាលបរិច្ឆេទផ្សេង ខុសពីអ្វីដែលលោកបានជម្រាបនេះដែរឬទេ? ហើយលោកគិតយ៉ាងម៉េចដែរ ចំពោះកាលបរិច្ឆេទខុសគ្នានេះ?

[១១:១៤:២៦]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** សូមអរគុណ។ ខ្ញុំបានអានសៀវភៅនេះ ហើយខ្ញុំអានទំព័រនេះ ប្រហែល៦ឆ្នាំមុន ខ្ញុំដឹងច្បាស់ថា គឺថាមានបញ្ហាមួយចំនួន -- ខ្ញុំសូមឲ្យប្រាកដថា ខ្ញុំបានឃើញសេចក្តីយោងក្នុងគោលបំណងនោះ ដែលនិយាយអំពីឆ្នាំ៧៤, ៧៥ ដែលនិយាយពីសេចក្តីសម្រេចដែលបានធ្វើឡើងហ្នឹង។ ហើយខ្ញុំត្រូវការមើលលេខយោងទំព័រ ហើយដើម្បីឆ្លើយសំណួរនោះ។ ហើយគឺថាអាចនឹងឆ្លើយបានច្បាស់ជាងនេះ។ សំណួរនេះ តាមដែលខ្ញុំដឹងនោះ គឺថាមានទស្សនៈខុសគ្នា ហើយខ្ញុំដឹងថា ស្ទូត ហ្នឹង គាត់និយាយជាទូទៅ គឺអ៊ីចឹងមែននោះ។ ជាពិសេសចំណុចនេះ ដែលលោកលើកឡើងហ្នឹង គឺថាវាមានភាពខុសគ្នាអ៊ីចឹងមែនពីកាលបរិច្ឆេទនោះ។

**ស៖** ឥឡូវនេះខ្ញុំចង់សួរលោក អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ បើតាមចំណេះដឹងរបស់លោក ពីព្រោះថានៅក្នុងសក្ខីកម្មរបស់លោកនោះ លោកបាននិយាយអំពីការជម្លៀសដែលបានគិតទុកមុនឆ្នាំ១៩៧៥ ហើយការជម្លៀសនេះបង្កឲ្យមានការបាត់បង់យ៉ាងធ្ងន់ធ្ងរ។ បើតាមទស្សនៈរបស់លោកផ្ទាល់ ការជម្លៀសមុនឆ្នាំ៧៥នោះ តើវាជាការប្រាប់ដំណឹងឲ្យមុនច្បាស់អំពីលទ្ធភាពនៃវិធានការនេះដែរឬទេ?

[១១:១៦:៥៩]

**ឆ៖** ផ្នែកមួយនៃសំណួររបស់លោក គឺថាមិនមានមធ្យោបាយមួយដែលថាមានធ្ងន់ធ្ងរ ដែលថាទំហំនោះគឺថាជម្លៀសតូចទេនៅក្រុងឧដុង្គនិងខេត្តក្រចេះនោះ។ ប៉ុន្តែភ្នំពេញវាធំជាង ប៉ុន្តែឯកសារ

សម្ភាសទាក់ទងទៅនឹងការចាត់វិធានការលើអ្នកទាំងនោះ ជាផ្នែកមួយនៃនយោបាយទូលំទូលាយ។ ខ្ញុំមិនអាចនិយាយបានទេ ប៉ុន្តែខ្ញុំយល់ថា ចំណុចនេះជម្លៀសមុនឆ្នាំ១៩៧៥នេះ គឺតាមទម្លាប់មួយ គឺថាមិនជាការឈ្លានពានកងកម្លាំងចូលទៅក្នុង ចូលយកទីក្រុងទាំងនោះ គឺឧដុង្គ និងក្រចេះដើម្បីឲ្យប្រជាជនចេញទៅធ្វើអ្វីតាមការងាររបស់ប្រជាជននៅឧដុង្គ គឺត្រូវបានគេដកចេញដើម្បីកុំឲ្យរបប លន់ នល់ កាន់កាប់ ឬក៏មានធនធានមនុស្សនៅទីនោះ។ ចំពោះនៅខេត្តក្រចេះ ខ្ញុំមិនដឹងច្បាស់ពិស្តារទេ។ ប៉ុន្តែហើយវាមានការអន្តរាយធ្ងន់ដូចនៅឧដុង្គទេ ពីព្រោះឧដុង្គជាតំបន់ដែលមានសង្គ្រាម ប៉ុន្តែក្រចេះមិនមានសង្គ្រាមទេ ពេលដែលគេជម្លៀសដកប្រជាជនចេញនោះ។

**ស៖** បើសិនជាខ្ញុំយល់ចម្លើយរបស់លោកច្បាស់នោះ គឺថាចំពោះឧដុង្គ គឺជាជំហានមួយនៃការដណ្តើមអំណាច។ តើអ៊ីចឹងមែនទេ គឺជាឈានទៅរកការដណ្តើមយកអំណាចទាំងស្រុងនោះ?

[១១:១៨:៤០]

**ឆ៖** បាទ គឺថាអ្វីៗដែលគេធ្វើឡើងហ្នឹង គឺសង្គ្រាមស៊ីវិល គឺដើម្បីក្តោបក្តាប់យកដណ្តើម គឺពិតអ៊ីចឹង។

**ស៖** ក្នុងសៀវភៅ “ជីវប្រវត្តិ ប៉ុល ពត” ដែលជាសៀវភៅរបស់លោកនោះ ខ្ញុំនឹងផ្តល់លេខទំព័រ ពីព្រោះខ្ញុំត្រូវយោងទៅលើឯកសារនេះ គឺលេខទំព័រ៦០ ឯកសារគឺលេខ E3/17, ERN ជាភាសាអង់គ្លេស 00392974, ជាភាសាខ្មែរ 00821724។ ក្នុងសៀវភៅនោះ លោកបានសរសេរថា “នៅដើមឆ្នាំ៦០ ជនជាតិវៀតណាម គឺណែនាំឲ្យមេដឹកនាំកម្ពុជាតស៊ូ បន្តការតស៊ូខាងផ្នែកនយោបាយ”។ តើលោកអាចពន្យល់បានទេថាតើការតស៊ូនយោបាយនេះ វាមានន័យយ៉ាងម៉េចដែរ ដែលជាការសម្លាប់ខ្លួនឯងទៅវិញនោះ ការតស៊ូនយោបាយជាការសម្លាប់ខ្លួនឯង?

[១១:២០:១៧]

**ឆ៖** ការបន្តតស៊ូនយោបាយនោះ គឺមិនមែនជាការអត្តឃាតខ្លួនឯងទេ គឺដោយសារថា កុម្មុយនីស្តខ្មែរមិនអាចមានប្រដាប់អាវុធបានទេ បើសិនមានការបង្ក្រាបនោះ។ នេះហើយគឺ ឲ្យគេនៅស្ងៀម ឬក៏គេបះបោរទទួលការសម្លាប់នេះ គឺថាឯកសារចង្អុលបង្ហាញថា ខ្មែរក្រហមនិយាយច្រើន គឺថាអ្វីដែលគេចង់បាន អ្វីដែលវៀតណាមចង់បាននៅក្នុងកម្ពុជា ដំណាក់កាលនេះគឺ ការតស៊ូនយោបាយត្រូវតែធ្វើឡើងដើម្បីប្រឆាំងសម្តេច សីហនុ ប៉ុន្តែមិនអាចធ្វើអ្វីបាន ដើម្បីរារាំង ឬក៏ដើម្បីបង្ក្រាបអំពីសម្ព័ន្ធមិត្តរបស់សម្តេច សីហនុ ជាមួយវៀតណាមទេ។ នេះគឺវាអាចធ្វើឲ្យចុះខ្សោយនូវអ្វីដែលកើតឡើងនៅក្នុងឆ្នាំ

១៩៦០ ឬក៏៧០ នៅពេលខ្មែរក្រហម កាន់ប្រដាប់អាវុធប្រឆាំងនឹងរបបសម្តេច សីហនុ មុនរដ្ឋប្រហារនោះ។ ហើយពួកគេធ្វើការក្រោមការណែនាំរបស់ ប៉ុល ពត -- អ៊ំ! របស់វៀតណាម ហើយៗគេយល់ថា វៀតណាមជាអ្នកក្បត់គោលនយោបាយរបស់គេ។ ហើយវៀតណាមគេមិនចង់ឲ្យគេ -- ខ្មែរក្រហមតស៊ូប្រដាប់អាវុធជាមួយសម្តេច សីហនុ ទេ ពីព្រោះអាចជាអត្តឃាតខ្លួនឯង។ ដូច្នេះហើយចលនាខ្មែរក្រហម គឺថាជ្រើសរើសយកជម្រើសដើម្បីតស៊ូខ្លួនឯង ដើម្បីតទល់នឹងការបំពានមកលើក្រុមខ្លួននោះ។

[១១:២១:៥៤]

**លោក អាកទួរ វែកគែន៖**

សូមអរគុណច្រើនលោក ឆេនដ័ល័រ។ លោកប្រធានខ្ញុំអស់សំណួរហើយ។

[១១:២២:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២២:២២]

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន។ ឥឡូវនេះ កិច្ចពិភាក្សាដេញដោលចំពោះលោកអ្នកជំនាញ ឃើញថា ដល់ទីបញ្ចប់ហើយ។ ហើយលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ័ល័រ ក្នុងនាមខ្ញុំ ក្នុងនាមអង្គជម្រះសាលាដំបូង ខ្ញុំសូមអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកសាស្ត្រាចារ្យ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អញ្ជើញចូលរួម និងផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ នៅក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលក្នុងរយៈពេលប្រាំមួយថ្ងៃកន្លងមកនេះ។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទាន ក្នុងការលាតត្រដាងស្វែងរកការពិតនៃរឿងក្តីនេះ។ ហើយសូមលោកជួបតែសំណាងល្អ និងធ្វើដំណើរប្រកប -- វិលវិញប្រកបដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញរៀបចំការវិលត្រឡប់របស់លោកអ្នកជំនាញផង។

សូមអញ្ជើញលោកអ្នកជំនាញ!

[១១:២៣:២៧]

**លោក ដេវីដ ឆេនដ័ល័រ៖**

ដោយសង្ខេបលោកប្រធាន សូមអរគុណចំពោះមតិទាំងឡាយ ហើយខ្ញុំសូមជម្រាបថា ហើយ

នេះជាឱកាសដ៏ល្អបំផុតសម្រាប់ខ្ញុំ ហើយខ្ញុំសង្ឃឹមថា ខ្ញុំបានឆ្លើយបានល្អ ខ្ញុំចង់ឲ្យតុលាការកត់ត្រាតុលាការ។ ខ្ញុំសូមអំណរគុណចំពោះអង្គជំនុំជម្រះ ដែលបានអញ្ជើញខ្ញុំ ហើយសូមកោតសរសើរចំពោះបុគ្គលិកដែលគាំទ្ររបស់សាលាក្តី ដែលជួយខ្ញុំជាច្រើនក្នុងការរៀបចំធ្វើដំណើរផ្សេងៗ ហើយសូម -- ទីបំផុតហ្នឹង ក៏ខ្ញុំសូមអរគុណចំពោះមេធាវី មេធាវីការពារ ហើយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានធ្វើការយ៉ាងខ្លាំង ដើម្បីសួរសំណួរដ៏សំខាន់ៗ ហើយទាក់ទងទៅប្រវត្តិសាស្ត្រនោះគឺជា សំណួរដ៏មានសារប្រយោជន៍។ ដើម្បីបញ្ចប់ ខ្ញុំសូមសម្តែងនូវអំណរគុណចំពោះប្រជាជន អ្នកទាំងអស់ ដែលបានធ្វើការជាមួយខ្ញុំចំនួនបីថ្ងៃកន្លះនេះ ខ្ញុំរីករាយ ហើយសូមអរគុណ។ ជាពេលវេលាដែលខ្ញុំរីករាយក្នុងការធ្វើការងារ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកផង។ អង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលថ្ងៃនេះ ដើម្បីពិសាអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះសូមជម្រាបភាគី និងសាធារណជនថា នៅរសៀលនេះ ចាប់ផ្តើមពីម៉ោងមួយសាមសិបនាទី អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-564 ដែលអង្គជំនុំជម្រះបានអញ្ជើញគាត់មកត្រៀមបម្រុងទុករួចហើយ។

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ហើយកូនក្តីរបស់ខ្ញុំលោក នួន ជា សូមអនុញ្ញាតទៅតាមដានសវនាការពីបន្ទប់ខាងក្រោមនេះ។ ហើយគាត់មានបញ្ហាក្នុងការផ្តង់អារម្មណ៍ ហើយមានការឈឺក្បាលហើយនិងឈឺខ្នងផងដែរ។ សូមអនុញ្ញាតតុលាការដើម្បីយើងខ្ញុំនឹងដាក់លិខិតបោះបង់សិទ្ធិជូនអង្គតុលាការ ហើយសូមអនុញ្ញាតឲ្យគាត់បានទៅតាមដានល្ងាច ពីសាលខាងក្រោមបាទ។

[១១:២៥:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយរសៀលនេះ។ ដោយមូលហេតុមានអាការៈឈឺក្បាល ឈឺខ្នង

ហើយនិងថមថយនូវលទ្ធភាពផ្តល់អារម្មណ៍ក្នុងការតាមដានកិច្ចដំណើរការ។ ហើយក្រុមមេធាវីការពារក្តីសន្យាថាខ្លួននឹងប្រគល់មកអង្គជំនុំជម្រះភ្លាម នូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការរបស់ជនជាប់ចោទ។

អង្គជំនុំជម្រះយល់ឃើញថាលោក នួន ជា បានលះបង់សិទ្ធិក្នុងការចូលសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះដោយ -- តែគាត់អាចតានដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈប្រព័ន្ធសោតទស្សន៍។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលកិច្ចដំណើរការសវនាការពេញមួយរសៀលនេះ។ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការដោយចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

[១១:២៧:០៧]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោម ក្នុងរយៈពេលកិច្ចដំណើរការសវនាការនៅរសៀលនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់សាលសវនាការនេះវិញឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

[១១:២៧:៤៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:២៧ នាទី ដល់ម៉ោង ១៣:៣៣នាទី)*

[១៣:៣៣:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅរសៀលនេះដូចអង្គជំនុំជម្រះបានជម្រាបជូនសាធារណជននិងភាគីរួចហើយ កាលពីព្រឹកមិញថា អង្គជំនុំជម្រះនឹងចាប់ផ្ដើមស្ដាប់នូវសក្ខីកម្មសាក្សីមួយរូបដែលមានរហស្សនាម TCW-564។ ហើយបន្តិចទៀតនេះ បើមិនមានបញ្ហាអ្វីពីភាគីទេ អង្គជំនុំជម្រះនឹងកោះអញ្ជើញសាក្សីហ្នឹងចូលបន្ទប់សវនាការ។

សូមអញ្ជើញលោក ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោកប្រធាន សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់ និងសាធារណជនផងដែរ។

មុននឹងសាក្សីបង្ហាញខ្លួន ខ្ញុំចង់លើកបញ្ហាមួយជម្រាបតុលាការឲ្យបានជម្រាប ហើយនិងសហព្រះរាជអាជ្ញាផងដែរ។ ទាក់ទងទៅនឹងសាក្សីរូបនេះ ហើយអ្វីដែលយើងខ្ញុំនឹងបន្ត ឬក៏ដំណើរការដោយផ្អែកលើអ្វីដែលថា ជានីតិវិធីធម្មតាន៎ុង សាក្សីបានឆ្លើយនៅក្នុងចម្លើយកំណត់ហេតុពីរទៅសហចៅក្រមស៊ើបអង្កេតនោះ។ ចម្លើយទីពីរ ថ្ងៃទី២១ កញ្ញា ឆ្នាំ២០០៨។

[១៣:៣៥:០៤]

ដូចដែលលោកចៅក្រមជ្រាបហើយ នៅក្នុងបទពិសោធន៍ពីមុនដែលយើងជួបប្រទះនៅតុលាការនេះនោះ។ ការអនុវត្តគឺថា ដើម្បីឲ្យមានការពិនិត្យលើបទសម្ភាសន៍វែង ហើយឲ្យសង្ខេប ហើយយើងត្រឡប់មកសង្ខេប ហើយសេចក្ដីសង្ខេបន៎ុងប្រើជាកំណត់ហេតុផ្លូវការ។ ពេលខ្លះសេចក្ដីសង្ខេបជួនកាលប្រាំទំព័រ ឬ១០ទំព័រ ទោះបីជាការពិភាក្សាន៎ុង គឺថាប្រើពេលច្រើនម៉ោងក៏ដោយ។

នៅក្នុងករណីពិសេសមួយនេះ ប្រសិនបើយើងពិនិត្យមើលកំណត់ហេតុទីពីរ គឺ E3/63 ហើយផ្ដាប់ដាក់ឈ្មោះថា D107/3 បាទ។ ការសម្ភាសចាប់ផ្ដើមឡើងនៅម៉ោងប្រាំបួន ហើយបញ្ចប់នៅម៉ោងដប់មួយ។ គឺថាការសម្ភាសហ្នឹងតែពីរម៉ោងទេ។ ផ្អែកលើការពិនិត្យរបស់ខ្ញុំ គឺថាយើងពិនិត្យមើលខ្សែអាត់ថតសំឡេង ថាតើខ្សែអាត់ហ្នឹងស្របជាមួយនឹងសេចក្ដីសង្ខេបដែរឬអត់? គឺថាមានផ្នែកខ្លះមិនត្រូវ

បានកត់ត្រាលើកំណត់ហេតុទេ។ នៅក្នុងករណីនេះយ៉ាងហោចណាស់សហសេវិកខ្ញុំ ទាំង អាង ឧត្តម ទាំង ម៉ូស្សេទី ហើយនិងមេធាវីបានស្តាប់ខ្សែអាត់ហ្នឹង ហើយក៏បានស្តាប់ឮថា សាក្សីអាននូវចម្លើយ។ មិនមែនជាការសន្ទនាទេ គឺគេអានសំណួរ ហើយឲ្យគាត់អានចម្លើយហ្នឹងមកវិញ។

[១៣:៣៦:៤៦]

ដូច្នេះយើងមានការពិភាក្សាទូលំទូលាយអំពីការសម្ភាសហ្នឹង គឺប្រតិចារឹកទៅជាភាសាអង់គ្លេស ដើម្បីឲ្យខ្ញុំបានឃើញច្បាស់។ អ្វីដែលខ្ញុំបានឃើញនោះ គឺទាំងអង់គ្លេស ទាំងខ្មែរនោះគឺសេចក្តីសង្ខេប នៅក្នុងកំណត់ហេតុនេះ គឺជាចម្លើយ គឺជាខ្លឹមសារដូចគ្នាបេះបិទនៅក្នុងខ្សែអាត់សំឡេងនោះឯង។ ប៉ុន្តែ នៅក្នុងបទសម្ភាសន៍ទីពីរ ប្រហែលជានៅពេលដែលយើងពិនិត្យមើលឈ្មោះខាងដើម គឺថាមានប្រវែង តែបួនទំព័រទេ ហើយការសម្ភាសពីរម៉ោង។ ហើយមានការកត់ត្រាប្រហែលជា ខ្សែអាត់ហ្នឹងតែ១០ ទៅ ១៥នាទីទេ គឺថាប្រតិចារឹកកត់ត្រាតែបួនទំព័រ។ អ្វីនៅក្នុង៤៨នាទីផ្សេងទៀតនោះ គឺថាសាក្សីបានផ្តល់ ចម្លើយឲ្យគាត់ ហើយឲ្យសាក្សីហ្នឹងអានចម្លើយទៅនឹងសំណួរ។ មិនមែនជាការអនុវត្តនៅក្នុងកន្លែង ផ្សេងទៀតនៅតុលាការទេ ប៉ុន្តែខ្ញុំមិនដឹងថា ការអនុវត្តបែបនោះត្រូវខុសនោះទេ។ ប៉ុន្តែបើសិនជាយើង ធ្វើការសម្ភាសនៅករណីនេះគប្បីតែសួរ ហើយឆ្លើយ។ មិនត្រូវឲ្យសាក្សីគាត់អានចម្លើយពីមុនមកយក ជាចម្លើយពេលនេះទេ គឺថាៗយើង លើកលែងតែយើងបញ្ជូនបញ្ជីសំណួរទៅគាត់មុន ហើយគាត់ សរសេរឆ្លើយ ហើយគាត់យកមកអាន។ ប៉ុន្តែខ្ញុំមិនដឹងច្បាស់ទេ ប៉ុន្តែនៅក្នុងករណីកំណត់ហេតុនេះ យើងឃើញថា មានភាពមិនប្រក្រតី។

[១៣:៣៨:២២]

យើងមានសាក្សីពីមុនមួយហើយ ដែលលោក លោកស្រីចៅក្រមជ្រាប ដែលបានផ្តល់បទ សម្ភាសន៍ ហើយគឺយើងដឹងទេ រហូតទាល់តែគាត់មកឆ្លើយ បានដឹងថាមុនពេលដែលគាត់ -- គឺថាគាត់ មុននឹងមកផ្តល់បទសម្ភាសន៍៤ម៉ោង ដែលគេឲ្យឯកសារទៅគាត់មុន ហើយបានគេយកកត់ត្រាពេល ក្រោយ។ ហើយនៅពេលនេះនៅក្នុងសេចក្តីសង្ខេបនេះ យើងខ្ញុំគិតថា នេះគឺជាស្ថានភាពដែលត្រូវតែ មានការបំភ្លឺ។ ប្រតិចារឹក គឺថាប្រហែលជា គឺថាអាចនឹងចេញមក១០*មីនុត* ក្រោយម៉ោងមួយថ្ងៃនេះ ដែលខ្ញុំថា ខ្ញុំនឹងបានការបំភ្លឺពីសហសេវិករបស់ខ្ញុំ ឃើញបញ្ហានេះ។

ដូច្នេះ ខ្ញុំចង់បានការណែនាំពីអង្គជំនុំជម្រះ ថាតើត្រូវអនុវត្តដូចម្តេច? ថាតើត្រូវសួរសាក្សីនេះឲ្យ បំភ្លឺ ឬក៏ទុកឲ្យភាគីសួរដេញដោលគាត់អំពីហេតុការណ៍ អំពីការឆ្លល់របស់អង្គជំនុំជម្រះ ឬក៏របស់យើង

ខ្ញុំ ដើម្បីឱ្យយើងព្យាយាម ដើម្បីទាញអត្ថប្រយោជន៍ពីដំណើរការនីតិវិធីនេះ។ នេះហើយជាចំណុចដែលខ្ញុំចង់លើកឱ្យបានទាន់ពេល។ ហើយខ្ញុំសង្កេតឃើញថាមានភាពមិនប្រក្រតី ដែលយើងចង់សួរដេញដោលរឿងនេះ ហើយសហព្រះរាជអាជ្ញាប្រហែលជាចង់ធ្វើបែបនេះដែរ។ ក្នុងករណីដែលថា គាត់អាចនឹងពឹងផ្អែកទៅលើកំណត់ហេតុទីពីរ ជាជាងកំណត់ហេតុទីមួយរបស់សាក្សីរូបនេះ។ លើកលែងតែយើងមានការរំពឹកសាក្សីឱ្យជ្រាបរឿងនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

ហើយសូមអរគុណប្រធាន ហើយសូមអរគុណលោកមេធាវីដែលបានលើកឡើងបញ្ហានេះនៅពេលនេះ។ ខ្ញុំគិតថា នេះដូចជាឆាប់ពេកដែលលោកលើកឡើងនោះ ប៉ុន្តែខ្ញុំយល់ហើយអ្វីដែលលោកលើកឡើងនោះ ខ្ញុំបានឃើញប្រតិចារឹកនៅពេលដែលដាក់ជូនជាភាសាបារាំងនោះ ហើយខ្ញុំបានមើលខ្ញុំមើលឃើញថាវា គឺថាវាដូចគ្នាទៅនឹងកំណត់ហេតុលាយលក្ខណ៍អក្សរ។ ដូច្នេះ ហើយគឺថា មិន-- ការទាមទារ គឺថាមិន -- ការកត់ត្រាជាខ្មែរអាត់នោះគឺថា វាមិនផ្ទុះបញ្ជាំង។ ដូច្នេះហើយ យើងត្រូវតែបន្តសួរសាក្សីនោះ បើសិនជាមានបញ្ហាអ្វីកើតឡើងវាអាចនឹងលេចឡើងនៅពេលសួរសក្ខីកម្មនោះឯង។ ដូច្នេះហើយ មេធាវីប្រកាន់តែជំហរមួយដែលថា -- ហើយតុលាការត្រូវតែបន្តការស្តាប់សក្ខីកម្មរបស់គាត់ ហើយយើងនឹងគួរតែបន្តសួរគាត់ ដូច្នេះហើយជាគោលបំណង នេះហើយជាគោលបំណងដែលយើងចង់កោះអញ្ជើញសាក្សីដើម្បីឱ្យគាត់បំភ្លឺថាហេតុការណ៍ពេលសម្ភាសនោះដូចម្តេច ដើម្បីឱ្យតុលាការបានជ្រាបនោះបាទ។

[១៣:៤១:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥០:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះមានការកត់សម្គាល់ពីមេធាវីការពារក្តីលោក អៀង សារី ពាក់ព័ន្ធនឹងនីតិវិធីនៃធ្វើកំណត់ហេតុ និងប្រតិចារឹកនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតរបស់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ប៉ុន្តែដើម្បីឱ្យបញ្ហានេះច្បាស់លាសនៅក្នុងកិច្ចដំណើរការនេះ ហើយពេល

នេះក៏មានវត្តមានសាក្សីរូបនេះនៅក្នុងកិច្ចដំណើរការសវនាការហើយដែរ។ ដូច្នេះ ដើម្បីឲ្យជាក់ច្បាស់នោះ គឺអង្គជំនុំជម្រះកោះអញ្ជើញសាក្សីមកចូលសវនាការ ហើយនិងមានសំណួរមួយចំនួនពាក់ព័ន្ធនឹងបញ្ហានេះ ដើម្បីដោះស្រាយនូវអ្វីដែលបានលើកឡើងដោយមេធាវីអន្តរជាតិការពារក្តីលោក អៀង សារី ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីដំណាក់កាលមុន ដែលបានរៀបចំធ្វើឡើងនៅចំពោះសាក្សីរូបនេះ។

[១៣:៥១:៤៤]

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី TCW-564 ហើយនិងមេធាវីប្រឹក្សារបស់គាត់ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៥៣:៣៣]

**ប្រធានអង្គជំនុំ៖**

សួស្តីលោកសាក្សី! អម្បាញ់មិញនេះ លោកបានស្តាប់ការណែនាំរបស់មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលក្នុងការឆ្លើយតបនៅពេលដែលមានសំណួរហើយ។ យើងបញ្ជាក់បន្ថែមថា នៅពេលដែលមានការតាំងសំណួរពីអង្គជំនុំជម្រះ ឬភាគី លោកស្តាប់សំណួរឲ្យបាន ហើយបន្ទាប់មកទៀតលោករង់ចាំបន្តិច អង់ បង្អង់បន្តិចដើម្បីរង់ចាំមើលភ្លើងសញ្ញាក្រហមដែលនៅពីមុខលោក ដែលលើឧបករណ៍ស្រូបសំឡេងនោះ គឺនៅពេលដែលមានភ្លើងក្រហម សូមលោកចាប់ផ្តើមនិយាយ ដើម្បីឲ្យប្រព័ន្ធសំឡេងរបស់លោកហ្នឹងបានចូលទៅប្រព័ន្ធនៃការបកប្រែភាសា ទាំងពីរភាសាផ្សេងទៀត ដើម្បីប្រើប្រាស់នៅក្នុងកិច្ចដំណើរការសវនាការនេះ។

[១៣:៥៤:២៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សាក្សី តើលោកមានឈ្មោះអ្វីដែរ? ឈ្មោះប្រើប្រាស់ជាផ្លូវការរបស់លោកសព្វថ្ងៃនេះ?

**លោក រ៉ចាម តុន៖**

**ឆ៖** ជម្រាបសួរលោកប្រធាន សូមគោរពលោកប្រធាន។ បាទ ខ្ញុំឈ្មោះ រ៉ចាំ តុន បន្ទាប់មកទៀត គឺឈ្មោះ ភី ភួន បន្ទាប់ទៀតហៅខាងក្រៅ វីជាម។

**ស៖** លោកចេះអក្សរខ្មែរដែរឬទេ?

**ឆ៖** ចេះមើលបាន សរសេរបានខ្លះ។ តែមិនបានរៀនពីការសរសេរខ្សែសង្វាក់ទេ កាលជំនាន់នុ៎ងនោះ។

**ស៖** បាទ អរគុណ។ តើលោកអាចប្រកបឈ្មោះទីមួយរបស់លោកបានដែរឬទេ? សរសេរយ៉ាងម៉េចទៅឈ្មោះទីមួយរបស់លោក?

**ឆ៖** ឈ្មោះទីមួយរបស់ខ្ញុំបាទ រ៉ចាំ តុន។ “រ” “រ៉ចាំ”។ “ច” ដាក់ស្រះ “ាំ” រ៉ូចាំ តុន។ បន្ទាប់មកទៀត ភី ភួន។

**ស៖** សរសេរ លោកអាចប្រកបណ៎ា ប្រកបឈ្មោះលោក “រ” “រ៉ចាំ តុន” សរសេរយ៉ាងម៉េចទៅ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** ចាំមានភ្លើងសិនណ៎ា។ ចាំៗមានភ្លើងនៅក្បាលមីក្រូឲ្យសញ្ញាភ្លើងក្រហម សូមលោកចាប់ផ្តើមនិយាយ។ មានន័យថា ពេលដែលភ្លើងក្រហមហ្នឹង មានន័យ ក្បាលមីក្រូនៅមុខលោកហ្នឹង ចាប់ផ្តើមប្រតិបត្តិការហើយ។

[១៣:៥៦:២៧]

**ឆ៖** “រ” ដាក់ស្រះ “អ” ណ៎ា “រ”, “រ៉” អាហ្នឹង “រ៉”, “ច ដាក់ស្រះ ា” “ម” ចាម។ “តុន” “ត” ដាក់ស្រះ “ុ” និង “ណ” -- និង “ន” តុន។

**ស៖** បាទ អរគុណ។ ច្បាស់ហើយ។ លោក រ៉ចាម តុន តើលោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ឥឡូវខ្ញុំអាយុ ៦៥ឆ្នាំ។

**ស៖** បាទ អរគុណ។ ហើយតើលោកមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណាដែរ?

**ឆ៖** សព្វថ្ងៃ ខ្ញុំនៅ ភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

**ស៖** បាទ អរគុណ។ ចុះលោកសព្វថ្ងៃ លោកប្រកបមុខរបបរកស៊ីធ្វើអ្វី?

**ឆ៖** សព្វថ្ងៃ ធ្វើស្រែ ធ្វើចម្ការ។

**ស៖** បាទ អរគុណ។ តើលោកឪពុកបង្កើតរបស់លោកឈ្មោះអី?

**ឆ៖** លោកឪពុកខ្ញុំ រ៉ចាម ប៉ាទូតក្វក។

**ស៖** ម្តងទៀង សូមយឺតៗ។ និយាយមួយៗ ឈ្មោះៗឪពុកបង្កើតរបស់លោក?

**ឆ៖** ប៉ា-ទូត-ក្វែក។

[១៣:៥៨:២៤]

**ស៖** បាទ អរគុណ។ ចុះម្ដាយបង្កើតរបស់លោក គាត់ឈ្មោះអី?

**ឆ៖** រ៉ចាំ ប៉ែច។

**ស៖** ចុះប្រពន្ធរបស់លោកវិញ គាត់ឈ្មោះអី?

**ឆ៖** ប្រពន្ធឈ្មោះ ស្រេង គឹមលី។

**ស៖** បាទ អរគុណ។ តើលោកមានកូនប៉ុន្មាននាក់?

**ឆ៖** មានកូនបួននាក់។

**ស៖** បាទ អរគុណ។ តើលោកអាចជម្រាបដល់អង្គជំនុំជម្រះបានទេ ថាតើទីលំនៅកន្លែងកំណើតរបស់លោក លោកនៅទីកន្លែងណា? កន្លែងកើត?

**ឆ៖** ខ្ញុំកើតនៅភូមិកែត ឃុំតាឡាវ ស្រុកអណ្ដូងពេជ្រ ខេត្តរតនគិរី។

[១៣:៥៩:៥១]

**ស៖** បាទ អរគុណ។ អណ្ដូងពេជ្រ ឬក៏ អណ្ដូងមាស?

**ឆ៖** គេហៅ អណ្ដូងពេជ្រ ប៉ុន្តែឥឡូវគេហៅ អណ្ដូងមាស។

**ស៖** បាទ អរគុណ។ អណ្ដូងពេជ្រ ឬក៏អណ្ដូងមាស?

**ឆ៖** គេហៅអណ្ដូងពេជ្រ ប៉ុន្តែឥឡូវគេហៅ អណ្ដូងមាស។

**ស៖** បាទ អរគុណ។ ហើយតើលោកមានជនជាតិដើមអីដែរ?

**ឆ៖** ខ្ញុំជនជាតិចារាយ។

[១៤:០០:២១]

**ស៖** បាទអរគុណលោក រ៉ចាម តុន។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការរាយការណ៍កាលពីព្រឹកមិញ ថាតាមសមត្ថភាពដែលលោកដឹង គឺលោកមិនមានញាតិ ឬក៏ញាតិពន្ធ -- ជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីនៃរឿងក្ដីនេះទេ គឺភាគីដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាជនជាប់ចោទ។ តើរបាយការណ៍នេះជាការពិតដែរឬទេ?

**ឆ៖** ពិតហើយ ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង។

**ស៖** ហើយព្រឹកមិញនេះ ក៏ក្រឡាបញ្ជីបានរាយការណ៍ផងដែរថា លោកបានធ្វើសម្បថនៅមុខអ្នកតាដំបងដែកប្រចាំនៅ អ.វ.ត.ក នេះហើយ។ តើពិតមែនដែរឬទេ?

**ឆ៖** ពិតមែនហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយនៅក្នុងកិច្ចដំណើរការសវនាការនេះ ក្នុងនាមលោកជាសាក្សី អង្គជំនុំជម្រះសូមជម្រាបអំពីសិទ្ធិ និងករណីយកិច្ចដូចខាងក្រោមនេះ៖

ក្នុងនាមលោកជាសាក្សី ក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះអង្គជំនុំជម្រះនេះ លោកអាចបដិសេធនៅក្នុងការឆ្លើយតបនៅក្នុងសំណួរ ឬក៏ធ្វើអំណះអំណាងណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

អំពីករណីយកិច្ចក្នុងនាមលោកជាសាក្សី លោកត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះ។ លោកត្រូវតែឆ្លើយតបទៅនឹងសំណួរនានាដែលភាគី ឬអង្គជំនុំជម្រះសួរចំពោះលោក។ លើកលែងតែក្នុងករណីដែលឆ្លើយតបទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចដែលយើងបានប្រាប់អំពីសិទ្ធិរបស់លោកដូចខាងលើអម្បាញ់មិញនេះ។

លោកជាសាក្សី ត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលខ្លួនបានឃើញ បានដឹង បានឮ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិការណ៍ ព្រឹត្តិហេតុទាំងឡាយណាពាក់ព័ន្ធទៅនឹងសំណួរ ដែលភាគី ឬចៅក្រមអង្គជំនុំជម្រះសួរលោក។

[១៤:០២:៤៤]

លោកសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលខ្លួនបានឃើញ បានដឹង បានឮ បានចាំ ហើយដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ។

**ប្រធានអង្គជំនុំ៖**

តើលោកយល់ដែរឬទេ?

**លោក វ៉ាចាម តុន៖**

យល់ហើយ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរគុណ។ ហើយសំណួរជាបន្ត លោក វ៉ាចាម តុន តើលោកមានដែលធ្លាប់ផ្តល់កិច្ច

សម្ភាសន៍ជាមួយអ្នកស៊ើបអង្កេត នៃការិយាល័យស៊ើបអង្កេតដែរឬទេ នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំមុនកន្លងមកនេះ?

**លោក វ៉ាចាម តុន៖**

**ឆ៖** បាទ ខ្ញុំមានកិច្ចសម្ភាសន៍ខ្លះៗដែរ។

**ស៖** ហើយតើកិច្ចសម្ភាសន៍ យើងសួរនេះតែកិច្ចសម្ភាសន៍របស់លោកដែលធ្វើឡើងជាមួយនឹងមន្ត្រីអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ចំពោះការធ្វើសម្ភាសផ្សេងទៀតហ្នឹង មិនពាក់ព័ន្ធនឹងសំណួររបស់យើងដែលសួរនៅពេលនេះទេ។ តើលោកធ្លាប់បានធ្វើសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងរយៈពេលកន្លងមកនេះប៉ុន្មានលើកដែរ?

[១៤:០៤:២៣]

**ឆ៖** តែពីរលើកទេ។

**ស៖** បាទ អរគុណ។ តើលោកអាចចងចាំបានទេថា សម្ភាសហ្នឹងលើកទីមួយ ធ្វើនៅពីពេលណាមក ហើយធ្វើនៅកន្លែងណា?

**ឆ៖** លើកទីមួយ ធ្វើនៅ នៅស្រុកម៉ាឡៃហ្នឹង នៅឃុំម៉ាឡៃ នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

**ស៖** នៅពេលណាដែរ លោកចងចាំដែរទេ?

**ឆ៖** កាលហ្នឹងដូចជាឆ្នាំ២០០៧។

**ស៖** បាទអរគុណ។ ហើយចុះលើកទីពីរ តើការធ្វើសម្ភាសហ្នឹងនៅទីកន្លែងណា? ហើយនៅពេលណាដែរ លោកចាំដែរឬទេ?

[១៤:០៥:២៧]

**ឆ៖** លើកទីពីរ ហ្នឹងនៅផ្ទះខ្ញុំបាទ នៅឆ្នាំ២០០៨ ដូចជា ខែ៩ ឆ្នាំ២០០៨។

**ស៖** បាទអរគុណ។ ហើយពេលដែលលោកមុនមកផ្តល់សក្ខីកម្មនៅពេលនេះ តើលោកធ្លាប់បានឃើញ ឬក៏បានអាននូវសេចក្តីកំណត់ហេតុដែលលោកបាន ធ្លាប់បានធ្វើសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតពីរដង ចំនួនពីរដងដែលលោកបាននិយាយអម្បាញ់មិញនេះដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានអានសាចុះសាឡើងដែរ ប៉ុន្តែអត់ចាំទេ។ ចាំវាមិនគ្រប់ខ។

**ស៖** បាទអរគុណ។ ហើយ -- តាមសមត្ថភាពដែលលោកដឹង លោកចាំ តើលោកអាចបញ្ជាក់បានដែរឬទេថា ការស្តាប់ចម្លើយដែលលោកបានអាន ដែលលោកបាននិយាយអម្បាញ់មិញនេះ ដើម្បីរំឭកការចងចាំនេះ តើវាត្រឹមត្រូវ និងស៊ីសង្វាក់គ្នា ឬក៏ស្របគ្នាទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតចំនួនពីរដង នៅស្រុកម៉ាឡៃ នៅខេត្តបន្ទាយមានជ័យ ឬក៏ផ្ទះរបស់លោកនោះដែរឬទេ?

[១៤:០៧:២៧]

**ឆ៖** ឃើញដូចគ្នាទាំងពីរលើកនោះ មើលទៅដូចគ្នាទេ លើកទីមួយ លើកទីពីរ ដូចគ្នា អត់មានអីប្លែកទេ។

**ស៖** បាទអរគុណ។ ហើយនៅក្នុងដំណើរការប្រព្រឹត្តទៅ នៃការសួរធ្វើសម្ភាសជាមួយលោកកាលណោះ តើលោកនៅចងចាំបានដែរទេថា ការសួរធ្វើសម្ភាសជាមួយលោកកាលណោះ តើលោកនៅចងចាំបានដែរទេថា ការធ្វើសម្ភាសនោះគឺ គេតាំងសំណួរចំពោះលោក ឲ្យលោកឆ្លើយ ឬក៏គេធ្វើនីតិវិធីផ្សេងពីនេះ បានន័យថា គេសួរ ឬក៏គេប្រាប់ចម្លើយដែលលោកត្រូវតែឆ្លើយតាមគេ អ៊ីចេះអ៊ីចុះដែរឬទេ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំបានរៀបរាប់អ្វីដែលខ្ញុំបាន បានជួបប្រទះ ហើយខ្ញុំរៀបរាប់តាមហ្នឹង តាំងពីដើមហ្នឹងគឺថា តាំងពី៦៧មកៗ ខ្ញុំរៀបរាប់ហូរហែមកអ៊ីចឹង។

[១៤:០៨:៤៧]

**ស៖** អ៊ីចឹងចុះពេលគេសួរ គេមានតាំងសំណួរសួរ សួរឆ្លើយៗដែរឬទេ ពេលដែលអ្នកស៊ើបអង្កេតសួរលោកមួយសំណួរ ហើយលោកត្រូវឆ្លើយតបទៅនឹងសំណួរហ្នឹង បន្ទាប់មកគេតាំងសំណួរផ្សេងទៀត មួយបន្ទាប់ទៀត ហើយលោកឆ្លើយអ៊ីចឹង ឬក៏ប្រព្រឹត្តទៅតាមនីតិវិធីខុសពីនេះ?

**ឆ៖** គាត់លើកសំណួរទៅ ខ្ញុំឆ្លើយ។ ខ្ញុំឆ្លើយសំណួររបស់គាត់ហ្នឹងទៅ។ អ្នកដែលស៊ើបអង្កេតហ្នឹងគាត់លើកឡើងសំណួរហ្នឹងទៅ ស្អីដែលខ្ញុំដឹង ខ្ញុំឆ្លើយ តាមហ្នឹងទៅ។

**ស៖** បាទ អរគុណ។ ហើយចុះពេលដែលកិច្ចសម្ភាសន៍ហ្នឹងបានធ្វើចប់ តើនីតិវិធីគេធ្វើយ៉ាងដូចម្តេច? នៅពេលដែលសួរៗ អ្នកស៊ើបអង្កេតនោះសួរលោកចប់ តើនីតិវិធីប្រព្រឹត្តទៅបន្ត នៅពេលដែលចប់ការសួរចម្លើយនេះ ការធ្វើសម្ភាសនេះ តើនីតិវិធីចុងក្រោយគេធ្វើយ៉ាងដូចម្តេច? លោកចងចាំ

ដែរទេ?

[១៤:១០:០២]

**ផ៖** គាត់សួរ សួរខ្ញុំឆ្លើយៗ ដល់ទីបញ្ចប់គាត់អាន ដែលគាត់សួរហើយខ្ញុំឆ្លើយហ្នឹង គាត់អានហើយ អានចប់ហើយ ឯកភាពគ្នាហើយ បានខ្ញុំផ្ដិតមេដៃ។

**ស៖** បាទ អរគុណ។ ហើយធ្វើដូច្នេះទាំងពីរលើក ឬយ៉ាងដូចម្ដេច?

**ផ៖** ទាំងពីរលើកៗអ៊ីចឹងដែរ។

**ស៖** លោកចាំទេ នៅក្នុងនីតិវិធីនៃការធ្វើសម្ភាសជាមួយលោកកាលណោះ តើមានថតសំឡេងដែរឬទេ? សំឡេងសួរឆ្លើយនៅក្នុងការធ្វើសម្ភាសនោះ?

**ផ៖** គាត់មានថតសំឡេងដែរ សរសេរហើយថតសំឡេង ប៉ុន្តែពេលហ្នឹងមិនបានចាក់សំឡេងទេ។ មិនបានចាក់ស្ដាប់ទេណាបាទ។

[១៤:១១:៣៥]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ តើលោក លោកស្រីចៅក្រមមានសំណួរអ្វីចង់សួរទៅដល់សាក្សីរូបនេះដែរឬទេ?

នៅក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ គឺលោកមានមេធាវីប្រឹក្សាមួយរូបគឺលោក លឹម ប៊ុនហេង នៅជិតលោកនេះ គឺលោកមេធាវីប្រឹក្សាសាក្សី ដែលអង្គជំនុំជម្រះបានផ្ដល់ឲ្យលោកតាមរយៈអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ដើម្បីធានាថា នៅក្នុងការផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ គឺលោកមិនមានឱកាសណាមួយដែលលោកឆ្លើយទៅនឹងសំណួរដែលមានដាក់បន្ទុកលើខ្លួនឯង ដាក់កំហុសលើខ្លួនឯងនៅក្នុងកិច្ចដំណើរការនេះទេ។ លើកលែងតែលោកពេញចិត្តនៅក្នុងការឆ្លើយនឹងសំណួរនោះដោយខ្លួនឯង ដោយស្ម័គ្រចិត្ត។ នោះជារឿងមួយដោយឡែក ប្រសិនបើលោកមិនចង់ឆ្លើយទេ គឺសិទ្ធិរបស់លោកដែលយើងប្រាប់អម្បាញ់មិញនេះ គឺរួចហើយ។ ហើយមេធាវីនឹងជំនួយប្រឹក្សាជាមួយលោកអំពីបញ្ហានេះ។

បាទ ជាកិច្ចបន្តគឺដោយអនុលោមតាមវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយនិងលិខិតប្រគល់ភារកិច្ចទទួលខុសត្រូវក្នុងការសួរដេញដោលសាក្សីដែលអង្គជំនុំជម្រះបានចេញកន្លងមក អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី វ៉ាចាម តុន មុនភាគីដទៃទៀត។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៤:១៣:២៤]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់ដែលមានវត្តមាននៅទីនេះ ហើយក៏សូមជម្រាបសួរលោកសាក្សីផងដែរបាទ។

**ការតាំងសំណួរដោយតំណាងសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សី ខ្ញុំមានសំណួរមួយចំនួនដែរចង់សួរលោកឲ្យលោកជួយបញ្ជាក់។ ហើយសំណួរដំបូងរបស់ខ្ញុំនោះគឺចង់ឲ្យលោកជួយរៀបរាប់ត្រួសៗអំពីការដែលលោកចូលបដិវត្តន៍ ថាតើមានអ្វីខ្លះជំរុញទឹកចិត្តលោកឲ្យចូលក្នុងបដិវត្តន៍ហ្នឹង? ហើយលោកចូលបដិវត្តន៍ហ្នឹងនៅពេលណាដែរ?

**លោក វ៉ាថាម តុន៖**

**ឆ៖** ខ្ញុំចូលធ្វើបដិវត្តន៍ពីថ្ងៃ២៤ ខែ៨ ៦៣។ មូលហេតុដែលខ្ញុំបានចូលធ្វើបដិវត្តន៍ថា ខ្ញុំមានបងថ្លៃខ្ញុំមួយ គាត់ណែនាំខ្ញុំថា "យើងទាំងអស់គ្នាជាជនជាតិភាគតិច កន្លងមកនេះមិនដែលមានអ្វីមកពាក់ព័ន្ធជាមួយយើងទេ។ ដូច្នេះពេលនេះដែលគេបើកផ្លូវឲ្យយើង គេថាចូលរួមធ្វើបដិវត្តន៍"។ គាត់មានមតិអ៊ីចឹង។ ហើយមួយរយៈខ្ញុំពិចារណាខ្លួនឯងផង ហើយនិងពិគ្រោះពិភាក្សាជាមួយម៉ែឪខ្ញុំផង គាត់ថាម៉ែឪខ្ញុំថា "ចូលទៅកូន! បើគេចូលបាន យើងក៏ចូលបានដែរ។ គេទៅធ្វើអី យើងក៏ទៅធ្វើនឹងគេបានដូចគ្នា"។ គាត់ ថា "ចូលទៅ មិនអីទេ"។ ខ្ញុំសម្រេចចិត្តថា ចូលទៅ ចូលធ្វើបដិវត្តន៍អ៊ីចឹងទៅ។

[១៤:១៥:៤៩]

**ស៖** បាទ អរគុណ។ តើបន្ទាប់មកទៀត បន្ទាប់ពីលោកចូលបដិវត្តន៍ហ្នឹងហើយ តើបន្ទាប់មកទៀតលោកបានចូលជាសមាជិកបក្សនៃបក្សកុម្មុយនីស្តកម្ពុជា ឬក៏ជាសម្ព័ន្ធយុវកកអីដែរទេពេលនុ៎ង?

**ឆ៖** ខ្ញុំបាន ចូលបាន ពី៦៣មក ដល់៦៨ ខ្ញុំបានចូលសម្ព័ន្ធៗយុវកក ៦៨។ ដល់ឆ្នាំ៧១ ខ្ញុំបានចូលបក្ខជន បាទ។

**ស៖** តើការដែលលោកចូលជាបក្ខជនហ្នឹង តើមានអ្នកណាណែនាំឲ្យលោកចូលដែរទេ?

**ឆ៖** មានបងៗ ដែលថាឃើញ គេឃើញថាយើងធ្វើការល្អ យើងបំពេញកិច្ចការប្រចាំថ្ងៃ ប្រចាំខែល្អ គេថាគេទៅឲ្យយើងចូលជាយុវកក ឲ្យយើងចូលជាបក្ខជន ដើម្បីមានសិទ្ធិដឹកនាំ។ គេណែនាំឲ្យចូល ចូលនឹងគេទៅ។

**ស៖** បាទ អរគុណ។ លោកបញ្ជាក់ថា "បងៗណែនាំឲ្យចូល" តើ "បងៗ" នោះជាអ្នកដែរ? លោកអាចនៅចាំឈ្មោះ ឬក៏តួនាទីរបស់គាត់ដែរទេ?

[១៤:១៧:៥១]

**ឆ៖** បងៗ គាត់ស្លាប់ហើយ។ ខ្ញុំចូលយុវកកហ្នឹង គឺឈ្មោះ បងម៉ានៗ ស្លាប់ហើយ។ គាត់ស្លាប់ៗ តាំងពី៧៤ ម្ល៉េះ គាត់ស្លាប់។ បន្ទាប់ទៀតចូលបក្ខជន បងៗ សួរ ហុង។ ៧១ ហ្នឹងគាត់ឲ្យខ្ញុំចូល។

**ស៖** តើលោកនៅចាំទេ ថានៅពេលនោះលោកៗ ម៉ាន ឬ/និងលោក សួរ ហុង ហ្នឹងគាត់មានតួនាទីអីដែរពេលនុ៎ង?

**ឆ៖** បងម៉ាន ហ្នឹង ខ្ញុំហៅគាត់ បងម៉ាន ហ្នឹង គាត់ -- កាលហ្នឹងគាត់ធ្វើប្រធានតំបន់នៅព្រះវិហារ។ ដល់ខ្ញុំចូលបក្ខជនហ្នឹង បង សួរ ហុង គាត់ធ្លាប់រស់នៅជាមួយគ្នាទៅ គាត់មានតួនាទីដឹកនាំពួកយើងខ្ញុំហ្នឹងទៅ ក៏នៅជាមួយគ្នា គាត់ជារៀមច្បង ដូចថាគោរពស្រឡាញ់គាត់ គាត់ណែនាំឲ្យចូលក៏ចូលតាមគាត់ហ្នឹងទៅ។ គាត់តួនាទីគាត់ គ្រប់គ្រងយើងទាំងអស់គ្នាហ្នឹង។

**ស៖** បាទ អរគុណ។ ចុះនៅអំឡុងពេលដែលលោកចូលក្នុង -- ចូលជាសមាជិកបក្សនៃបក្សកុម្មុយនីស្តកម្ពុជាហ្នឹង តើលោកមានបានចូលរួមរៀនសូត្រវគ្គនយោបាយ ឬក៏វគ្គរៀនសូត្រអីផ្សេងៗអំពីមាគ៌ា និងគោលនយោបាយរបស់បក្សដែរទេ?

**ឆ៖** បានរៀនដែរ បានរៀន។ រៀនហូរហែ រួចចាប់ពីចូលធ្វើបដិវត្តន៍ហ្នឹង គឺថាដូចខ្ញុំមានមតិអំមិញហ្នឹង បងម៉ាន គាត់បង្រៀនគោលនយោបាយធ្វើបដិវត្តន៍ហ្នឹងគឺថា ស្នេហាជាតិ ស្នេហាប្រជាជន ស្នេហាបដិវត្តន៍ អាហ្នឹងគាត់បង្រៀន។ ហើយបងៗផ្សេងៗក៏អប់រំប្រហែលៗគ្នាហ្នឹង អប់រំ។ ខ្ញុំសូមចប់។

**ស៖** លោកថាបងៗផ្សេងៗដែលបានអប់រំបង្រៀនដែរហ្នឹង តើបងៗហ្នឹងមានឈ្មោះអ្វីខ្លះដែរ?

**ប្រធានអង្គជំនុំ៖**

ឈប់ៗសាក្សីកុំអាល់ អង់បន្តិចចាំៗក្បាលមីក្រូប្រតិបត្តិការសិនណ៎ា!

**លោក វ៉ាចាម តុន៖**

**ឆ៖** បង្រៀនហ្នឹង ដំបូងហ្នឹងគឺ បងម៉ាន ហ្នឹង ខ្ញុំនៅជាមួយគាត់ គាត់បង្រៀន បងម៉ាន។ បន្ទាប់មេពីគាត់ទៀត បងយ៉ែមៗ។ បងយ៉ែម ហ្នឹងគាត់នៅក្រចេះ គាត់ឡើងទៅរតនគិរីហ្នឹង គាត់

បង្រៀនដែរ។ បន្ទាប់ទៅទៀត ខ្ញុំតែងតែហៅអ៊ំទី១៧ អ៊ំ ប៉ុល ពត ហ្នឹងគាត់បង្រៀន។ ខ្លួនគាត់ហ្នឹងក៏បង្រៀន គ្រួសារគាត់ហ្នឹងក៏បង្រៀន។ បន្ទាប់មកទៀតដែលខ្ញុំស្គាល់ហ្នឹង អ៊ំ អៀង សារី ក៏បង្រៀនដែរ គ្រួសារគាត់ក៏បង្រៀនដែរ។ បង្រៀនដូចៗគ្នា។ បង្រៀនជាប់ហូរហែអ៊ីចឹង។

[១៤:២២:២៦]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** បាទ អរគុណ។ ចុះលោកមានធ្លាប់ដែលចូលរៀនវគ្គរៀនសូត្រណាដែលបង្រៀនដោយលោក នួន ជា អីដែរទេ?

**ឆ៖** បាទ ខ្ញុំបានចូលរៀន អ៊ំ នួន ជា ក៏បានចូលរៀនដែរ។ អ៊ំ ខៀវ សំផន ក៏បានចូលរៀនដែរ។

**ស៖** លោកថា អ៊ំ នួន ជា, អ៊ំ ខៀវ សំផន បានចូលរៀនដែរ។ តើគាត់ចូលរៀន ឬក៏គាត់បង្រៀន?

**ឆ៖** គាត់បង្រៀនបាទ។

**ស៖** តើលោកអាចនៅៗចាំបានទេថា វគ្គបង្រៀននេះនៅពេលណា ហើយនៅកន្លែងណាខ្លះ លោកអាចចាំបានខ្លះទេ?

[១៤:២៣:៥០]

**ឆ៖** វគ្គបង្រៀន បងម៉ាន នេះគាត់បង្រៀនគេហៅនៅមាត់ស្ទឹងអូរកប គាត់បង្រៀន។ គាត់បង្រៀនបីថ្ងៃ។ បន្ទាប់មកទៀត អ៊ំ អៀង សារី គាត់បង្រៀន។ អាហ្នឹងគាត់បង្រៀន -- អ៊ំ អៀង សារី គាត់បង្រៀនឆ្នាំ៦៧ បង្រៀនកន្លះខែដែរ។ អ៊ំ អៀង សារី បង្រៀននៅភូមិ គេហៅនៅភូមិកាតែ នៅក្នុងស្រុកបរកែវ ខេត្តរតនគិរី ៦៧ ដែរ។ បន្ទាប់មកទៀតបង្រៀនហ្នឹង អ៊ំ ប៉ុល ពត បង្រៀននៅមន្ទីរ១០០ ថ្ងៃខ្លះគាត់ឧទ្ទេសនាម ថ្ងៃខ្លះគ្រួសារគាត់ឧទ្ទេសនាម។ បន្ទាប់មកទៀត ដូចខ្ញុំថាបងៗ សូ ហុង ហ្នឹងគាត់បង្រៀនដែរ។ ហើយនិងរំដោះភ្នំពេញហើយហ្នឹង អ៊ំ ខៀវ សំផន បង្រៀនដែរ។ រំដោះភ្នំពេញហើយ អ៊ំ នួន ជា ក៏បង្រៀនដែរ។ កាលនុ៎ងលោកអ៊ំ យុន យ៉ាត ហ្នឹងក៏បង្រៀនដែរ ធ្លាប់បង្រៀនដែរ។

**ស៖** បាទ អរគុណ។ តើលោកដឹងទេនៅជាទូទៅនៅក្នុងការបង្រៀនរបស់អ្នកដែលលោកបានរៀបរាប់ឈ្មោះអម្បាញ់មិញហ្នឹង តើគេលើកបញ្ហាអ្វីដែលខ្លះដែលជាចម្បងគេហ្នឹង?

[១៤:២៧:១៦]

**ឆ៖** គាត់លើកជាចម្បងគេហ្នឹងគឺថា ទីមួយទស្សនៈសភាពការណ៍រួម ទាំងក្នុងប្រទេស ទាំង

ក្រៅប្រទេស អាហ្នឹងទីមួយ។ ឯឃើញហ្នឹង ឃើញទិដ្ឋភាពរួមហ្នឹង ក្នុងប្រទេស ហើយនិងក្រៅប្រទេស។ ហើយបន្ទាប់មកទៀត គឺរៀន គឺថាឯកសារដែលថាធ្វើបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យហ្នឹង។ ហើយបន្ទាប់មកទៀត គឺរៀនពីទស្សនៈគោលជំហរសតិអារម្មណ៍ និងចាត់តាំង បង្រៀនអ៊ីចឹង។ បន្ទាប់ពីហ្នឹងទៀតគឺថា ធ្វើជីវទស្សនៈបដិវត្តន៍ គឺហៅថាធ្វើជីវទស្សនៈបដិវត្តន៍ពេលហ្នឹង។ ទិតៀនស្វ័យទិតៀនខ្លួនឯង ហើយមានអ្នកជួយ ដើម្បីកែលម្អតទៅមុខទៀត។ ជាទូទៅរៀនអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំសូមទោសដែលខ្ញុំត្រូវនិយាយកាត់ គឺថាមានការបកប្រែសំណួរមួយដែលមិនត្រឹមត្រូវជាភាសាអង់គ្លេស គឺនិយាយពីការដួលរំលំនៃរបបទីក្រុងភ្នំពេញ។ ខ្ញុំគិត -- គឺមានគេប្រាប់ខ្ញុំថាឈ្មោះមួយហ្នឹងគឺ បកប្រែទៅជាភាសាអង់គ្លេសខុស គឺឈ្មោះដែលត្រូវបានបកប្រែជាភាសាអង់គ្លេសហ្នឹង គឺវាខុស។ គឺរហស្សនាមមួយហ្នឹង គឺបកប្រែទៅជាភាសាអង់គ្លេសហ្នឹងគឺខុស។

[១៤:២៩:១៧]

**ប្រធានអង្គជំនុំ៖**

លោកតំណាងអយ្យការសូមបញ្ជាក់ឡើងវិញ ត្រង់ចំណុចដែលថាខុសហ្នឹងដើម្បីឲ្យលោកសាក្សីឆ្លើយឲ្យបានត្រឹមត្រូវឡើងវិញ ចៀសវាងមានការខុស ឬក៏មានការភ័ន្តច្រឡំ។

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** អ៊ីចឹងសូមលោកសាក្សី សូមលោកជួយបញ្ជាក់ឡើងវិញ ព្រោះថាប្រហែលជាមានការបកប្រែខុស។ សហការីខ្ញុំក៏បានប្រាប់ដែរថា ខ្ញុំក៏ដឹងថាប្រហែលជាមានការបកប្រែខុសដែរ ប៉ុន្តែយើងចង់ឲ្យដឹងឲ្យច្បាស់ទាំងអស់គ្នាថា ជាពិសេសឲ្យលោកជួយបញ្ជាក់ថា លោកបាននិយាយថាអ្នកដែលបានបង្រៀនបន្ទាប់ពីរំដោះភ្នំពេញហើយ តើមានអ្នកណាខ្លះ? សូមជួយបញ្ជាក់ឈ្មោះអ្នកបង្រៀនហ្នឹងឡើងវិញបាទ?

[១៤:៣០:១៨]

**លោក វ៉ាចាម គុន៖**

**ឆ៖** ក្រោយរំដោះហើយហ្នឹង គឺរៀន ទីមួយនោះគឺថា អ៊ំ ខៀវ សំផន គាត់បង្រៀន កាលហ្នឹងយើងហៅ សាលាបច្ចេកទេសសូវៀត គាត់បង្រៀននៅកន្លែងហ្នឹង។ ហើយបន្ទាប់មកទៀត បង ស្វរ ហុង ហ្នឹង គាត់បង្រៀន កាលមុនគេហៅថា ក្រសួងពាណិជ្ជកម្មអ្វេះ! ដែលនៅជាប់ក្រសួងការពារជាតិរាល់ថ្ងៃនេះ។ ហើយអង្កាល់ណោះ គេបង្រៀននៅកន្លែងនុ៎ង គាត់បង្រៀន។ ហើយបន្ទាប់មកទៀត អ៊ំ យុន យ៉ាត គាត់បង្រៀននៅសាលាសូវៀតហ្នឹងដែរ គាត់បង្រៀននៅកន្លែងនុ៎ង។

**ស៖** តើពេលនោះ មានលោក នួន ជា មានបង្រៀនទេ? តាមអ្វីដែលខ្ញុំបានស្ដាប់ឮមុនហ្នឹង លោកហាក់បីដូចជាឆ្លើយថា មានលោក នួន ជា បង្រៀនដែរ តើអ៊ីចឹងមែនដែរទេ?

[១៤:៣១:២៩]

**ឆ៖** គាត់បង្រៀនដែរ អ៊ំ នួន ជា គាត់បង្រៀនដែរ។ គាត់ កាលនុ៎ងគាត់បង្រៀននៅ វិហារព្រះកែវនោះ បង្រៀននៅវិហារព្រះកែវ។

**ស៖** បាទ អរគុណ។ ខ្ញុំបន្តសំណួរខ្ញុំតទៅទៀត មុននេះ លោកបានជម្រាបជូនអង្គសវនាការថា ការបង្រៀននេះ គឺគេលើកឡើង ដែលក្នុងមានពីសភាពការណ៍រួមក្នុងប្រទេស និងក្រៅប្រទេស។ អ៊ីចឹង សូមលោកជម្រាបជូនអង្គសវនាការឲ្យបានលម្អិតបន្តិចថា តើពេលនោះ គេពិភាក្សាយ៉ាងណាខ្លះអំពីខ្លឹមសារនៃសភាពការណ៍រួមក្នុងប្រទេស និងក្រៅប្រទេសហ្នឹង?

**ឆ៖** ចំណុចនេះ ខ្ញុំមិនបានចាំល្អិតទេ។ ប៉ុន្តែជាៗគោលការណ៍គេថា ឧទ្ទេសនាមសភាពការណ៍ក្រៅប្រទេសហ្នឹង គឺឧទ្ទេសនាមពេលហ្នឹងគឺឧទ្ទេសនាមប្រទេសណាខ្លះ ដែលឧបត្ថម្ភដល់ចលនាតស៊ូរបស់យើង។ ប្រទេសខ្លះ នៅអព្យាក្រឹត្យ ប្រទេសខ្លះដែលគេមានមនោសញ្ចេតនាជាមួយយើង ហើយប្រទេសខ្លះដែលគេប្រឆាំងយើង។ អាហ្នឹង ក៏គាត់វែកញែកឲ្យច្បាស់ៗដែរ ឲ្យឃើញ អាហ្នឹង។ គេហៅថា ដើម្បីយើងមើលកម្លាំងលើឆាកអន្តរជាតិ។

[១៤:៣៣:០៧]

ឯសភាពការណ៍ក្នុងប្រទេស គឺថាឧទ្ទេសនាមសភាពការណ៍រួមរបស់ចលនារបស់យើង គឺថា ខាងនយោបាយនេះ ប្រជាជនចូលរួមកម្រិតណា ខាងនយោបាយ។ ឧបត្ថម្ភ គាំទ្រ ចលនារបស់យើងកម្រិតណាៗ គឺគាត់ឧទ្ទេសនាមឲ្យយើងឃើញអាហ្នឹង។ ហើយបានឧទ្ទេសនាមកម្លាំងមហាជនដែលចូលរួមនេះ គ្រប់ជនជាតិទាំងអស់ចូលរួមដើម្បីប្រឆាំងសត្រូវរួមដែលយើងបានកំណត់នេះ គឺថាទាល់តែ

ប្រមូលកម្លាំងក្នុងប្រទេសនេះ គឺធ្វើជាស្នូល។ បើប្រមូលកម្លាំងហ្នឹងបានហើយ គ្រប់ស្រទាប់វណ្ណៈទាំងអស់ ដែលប្រមូលទាំងអស់ហ្នឹង ដើម្បីជាកម្លាំងបន្តការតស៊ូ។ បើមានកម្លាំងប្រជាជន គឺមានកម្លាំងចង់ធ្វើអ្វីៗបានទាំងអស់។ អ៊ីចឹង ចង់ឲ្យឃើញអ៊ីចឹង។ គេច្បាស់លាស់អ៊ីចឹងហ្មង។ បើយើងមានកម្លាំងពីរហ្នឹងទៅហើយ គឺកម្លាំងយោធាអត់ចោទទេ បើកម្លាំងសេដ្ឋកិច្ចក៏អត់ចោទដែរ បើមានកម្លាំងហ្នឹងហើយ។ អាហ្នឹង គាត់តែងតែអប់រំអ៊ីចឹង។

[១៤:៣៤:២១]

**ស៖** បាទ អរគុណ។ នៅក្នុងបង្រៀននោះ តើគេបានផ្ដល់ជាឯកសារអ្វីខ្លះ ដល់អ្នកដែលចូលរៀនហ្នឹងដែរទេ?

**ឆ៖** មានឯកសារគ្រប់គ្នាដែរ ឯកសារមានគ្រប់គ្នា ឲ្យតែអ្នកចូលរៀនប៉ុន្មាន គេមានឯកសារគ្រប់គ្នា។ គឺថាក្នុងវគ្គមួយៗមានទាំងអស់ គឺសម្រាប់យើងចប់ពីរៀនហ្នឹងហើយ យើងត្រូវតែមើលដើម្បីយើងធ្វើបណ្ដើរ រៀនបណ្ដើរ ដកស្រង់ពិសោធនបណ្ដើរ កែលម្អបណ្ដើរៗអ៊ីចឹងបាទ។

**ស៖** លោកអាចបញ្ជាក់បានទេថា ឯកសារដែលគេចែកឲ្យនោះមានជាឯកសារអ្វីខ្លះ? លោកនៅចាំទេ?

**ឆ៖** គោលៗ ដូចខ្ញុំបានបញ្ជាក់អំមិញហ្នឹង គេថា សភាពការណ៍ក្រៅប្រទេស វាមានមួយផ្នែករបស់វាអ៊ីចឹងទៅណា។ ហ្នឹងឯកសារហ្នឹងមួយ។ ឯកសារមួយទៀត គេនិយាយពីចលនារបស់យើង ទៅនឹងខាងនយោបាយដែលប្រជាជនគាំទ្រហ្នឹង។ គាំទ្រ ឧបមាថា តំបន់រំដោះយើងប៉ុន្មាន គឺគេសរសេរទាំងអស់។ តំបន់ដែលនៅកាន់កាប់បណ្ដោះអាសន្នហ្នឹង គេសរសេរដែរ ឲ្យយើងឃើញដែរ។ ហើយតំបន់ដែលសហ្នឹង ក៏គេសរសេរឲ្យយើងឃើញដែរ។ សរសេរហ្នឹង ដើម្បីយើងតាមដានមើលសភាពការណ៍ ហ្នឹងអ៊ីចឹង គាត់ឲ្យអ៊ីចឹង។ ហើយឯកសារដែលធ្វើជីវទស្សនៈបដិវត្តន៍ហ្នឹង គាត់ក៏មានដែរ ឲ្យដែរ។ ហើយឯកសារមួយទៀតចុងក្រោយ គឺយកវិធានការតទៅមុខទៀត ម្នាក់ៗត្រូវធ្វើអី ក្នុងឋានៈខ្លួនជាសមាជិករបស់បក្ស ត្រូវធ្វើអីម្នាក់ៗ ហើយម្នាក់ៗត្រូវទទួលខុសត្រូវអី ម្នាក់ៗត្រូវកែលម្អអី។ អាហ្នឹងត្រូវមានតែម្ដង ជាធម្មតាត្រូវមានអ៊ីចឹង។

[១៤:៣៦:៤៤]

**ស៖** បាទអរគុណ។ ឯកសារទាំងនោះតើលោកដឹងជាចំណងជើង ឧទាហរណ៍ជាសៀវភៅ ឬក៏ជាទស្សនាវដ្ដីអី តើមានឈ្មោះថា ចំណង -- មានឈ្មោះថាយ៉ាងម៉េចដែរទេ?

**ឆ៖** ដែលពេលយើងរៀនហ្នឹង អត់មានអីទេគេថា គេសរសេរហ្នឹងហើយកាលហ្នឹង សរសេរហើយដាក់កាបោនហ្នឹង ហើយនិងចែកគ្នាអ៊ីចឹងទៅណា។ ដល់រំដោះភ្នំពេញហើយបានមាន១អីអូសនោះណា បានមានអីអូស។ កាលនៅក្នុងព្រៃអត់មានទេអ៊ីចឹង។ ដល់១ក្រោយមកទៀតបានគេហៅថាមានជាទង់យុវជន ហើយមានជាទង់បដិវត្តន៍ នៅក្នុងនោះមាន ហើយមានជាទង់រណសិរ្សមាន ហើយគេបោះជាឯកសារអ៊ីចឹងគេមាន។ មានប៉ុណ្ណឹងទេ។

**ស៖** តើលោកនៅចាំដែរទេថា ទង់យុវជនរណសិរ្ស ឬក៏ទង់បដិវត្តន៍ហ្នឹង គេចេញផ្សាយនៅក្នុងឆ្នាំណាដែរ?

**ឆ៖** តាមខ្ញុំចាំនោះ ចាប់ពី៧៦មកបានមាន ៧៦មក។

**ស៖** ជាបន្តទៀត ខ្ញុំនឹងសួរលោកទាក់ទងទៅនឹងបទពិសោធន៍ ដែលលោកបានចូលរួមក្នុងចលនាបដិវត្តន៍ ក៏ដូចជាចូលក្នុងបក្សកុម្មុយនីស្តកម្ពុជា ជាពិសេសគឺនៅក្នុងអំឡុងពេលដែលលោកនៅខេត្តរតនគិរី ពីឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៧០។ នៅពេលដែលលោកស្នាក់នៅក្នុងខេត្តរតនគិរី ពីឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៦០ (ស៊ីក) ហ្នឹង តើលោកធ្លាប់បានជួបថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តណាដែរទេ? នៅពេលណា? ហើយកន្លែងណាដែរ?

[១៤:៣៩:៣០]

**ឆ៖** ខ្ញុំជួបអ្នកដឹកនាំមុនគេបង្អស់ គឺថា បងម៉ាន ឈ្មោះបងម៉ាន ហ្នឹងឯង ជួបគាត់ ហើយបាននៅការពារគាត់។ អាហ្នឹងទីមួយ។ ដល់ទីពីរ ៦៧ ហ្នឹង គឺថា ជួបអ៊ំ អៀង សារី។ អ៊ំ អៀង សារី គាត់កាលហ្នឹង គាត់មានសំបុត្រក្នុងបំពង់ហ្នឹងមួយ គាត់ថាឲ្យនាំទៅខាងវៀតណាម១ ពីរបីថ្ងៃបានទៅរកឃើញ ព្រោះយើងក៏មិនដឹងថាគេនៅត្រង់ណាដែរ ប៉ុន្តែឃើញគេនៅវាច្រើនណាស់ណាជិតយើងហ្នឹង។ បីបួនថ្ងៃបានយកសំបុត្រហ្នឹងទៅដល់១គេ។ ទៅដល់គេហ្នឹង វៀតណាម កាលដែលយើងទៅដំបូង គេមិនស្គាល់យើង គេមិនមើលយើងទេ ប៉ុន្តែដល់ពេលបានទទួលសំបុត្រហ្នឹងបាន ដូចថា ឃើញយើងបានគេគោរព បានគេស្រឡាញ់។ អាហ្នឹងលើកទីពីរ ខ្ញុំស្គាល់គាត់លើកទីមួយ ប៉ុន្តែលើកទីពីរបន្ទាប់បងម៉ាននោះ។

ដល់លើកទីបីហ្នឹង អ៊ំ ប៉ុល ពត ហ្នឹងគឺខែ១២-៦៧ គាត់ទៅដល់។ ទៅដល់គាត់ឈឺ។ គាត់ឈឺហ្នឹង ដល់មន្ទីរពួកខ្ញុំក៏សែងគាត់ទៅដេកពេទ្យវៀតណាម។ ដេកពេទ្យវៀតណាមជាហើយ ក៏បកមកវិញមក។ គាត់មក បានមកនៅមន្ទីរ១០០ហ្នឹង។ គាត់នៅមន្ទីរ១០០ទៅ អ៊ំ អៀង សារី គាត់នៅមន្ទីរ

១០២ អ៊ីចឹងទៅ។ អ៊ីចឹងរៀបរាប់នៅក្នុងខេត្តរតនគិរីអ៊ីចឹង។

**ស៖** បាទអរគុណ។ ការដែលលោកជួបជាមួយលោក -- ជាថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដូចជា លោក អៀង សារី ឬក៏លោក ប៉ុល ពត ហ្នឹងតើមាននរណាណែនាំលោកឱ្យស្គាល់ដែរទេ ឬក៏លោកជួបដោយវិធីណា?

**ឆ៖** ខ្ញុំជួបន៎ែ ដូចខ្ញុំថា បញ្ជាក់ពីដើម គឺបងថ្លៃខ្ញុំហ្នឹង បងឡើន ហ្នឹង។ បងឡើន ហ្នឹងគាត់នៅប្រចាំជាអចិន្ត្រៃយ៍នៅរតនគិរី ហើយខ្ញុំស្គាល់តាមគាត់ហ្នឹង។

[១៤:៤២:១៨]

**ប្រធានអង្គជំនុំ៖**

អរគុណសាក្សី អរគុណតំណាងសហព្រះរាជអាជ្ញា។

ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យ នៅបន្ទប់រង់ចាំដល់អ្នកសាក្សីអ្នកជំនាញ ដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឱ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០៤ នាទី)*

[១៥:០៤:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សី យើងមុននឹងឈប់សម្រាកអម្បាញ់មិញលោកបានបញ្ជាក់ថា លោកបាននាំ ប៉ុល ពត ដែលមានជំងឺទៅវៀតណាម។ តើលោកអាចបញ្ជាក់បានទេថា ប៉ុល ពត គាត់ឈឺអីគេពេលនុ៎ង?

**លោក រ៉ោម តុន៖**

**ឆ៖** ពេលនុ៎ងជំងឺរបស់គាត់ មែនទែនទៅគឺថា គ្រុនចាញ់តែម្ដង គឺថាគ្រុនចាញ់។ គាត់ទៅសម្រាករយៈពេល១ខែ ជាគាត់មកវិញមក។

**ស៖** អ៊ីចឹងមានន័យថា គាត់ជាហើយបានគាត់មកវិញ គឺរយៈពេល១ខែ។ ហើយតើមានមូលហេតុអ្វីទេ ដែលថាចាំបាច់ត្រូវជូនគាត់ទៅដល់ពេទ្យវៀតណាម? តើលោកមានដឹងពីហេតុផលហ្នឹងដែរឬទេ?

**ឆ៖** ហេតុផលល្អិត ខ្ញុំអត់ដឹងទេ។ ដឹងតែគ្រាន់ថា គាត់មកដល់មន្ទីរពួកខ្ញុំហ្នឹងហើយ គឺថាក៏ខ្ញុំទៅសែងគាត់ទៅ។ បើគាត់ឈឺហើយ សែងទៅ។ ហើយដល់តែគាត់ជាគេឲ្យយើងទៅទទួល សែងគាត់មកវិញដែរ។ គាត់បានសម្រាកនៅមន្ទីរពួកខ្ញុំហ្នឹង។ គាត់សម្រាកនៅហ្នឹងកន្លះខែហ្នឹង បានគាត់ចេញទៅធ្វើការបាន។

[១៥:០៦:៤០]

**ស៖** បាទ អរគុណ។ សំណួរជាបន្តទៀត ទាក់ទងទៅនឹងការងាររបស់លោកនៅអំឡុងពេលឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៧០ហ្នឹង តើលោកធ្លាប់ធ្វើការងារអីឲ្យ ប៉ុល ពត ឬក៏ អៀង សារី អីដែរទេនៅពេលនោះ?

**ឆ៖** ចន្លោះហ្នឹង គឺថាខ្ញុំធ្វើការ ដូចថាក្រោមបញ្ជារបស់គាត់ ក្រោមការណែនាំរបស់គាត់ គឺថាខ្ញុំជានីរសារក៏ខ្ញុំរត់សំបុត្រ រត់សំបុត្រទៅតាមស្រុក។ អាហ្នឹងជានីរសារ។ ហើយជាអចិន្ត្រៃយ៍ គឺថាធ្វើស្រែ។ ធ្វើស្រែ២៤ហិកតានៅកាលណោះ ប្រើក្របីកាលនៅហ្នឹងអ៊ីចឹង។ ដល់ពេលយើងធ្វើស្រែអ៊ីចឹងទៅ នែ៎ កាលហ្នឹងយើងមានកងទ័ព ហៅថាកងទ័ពសម្រាប់ការពារនៅភូមិភាគឦសានហ្នឹងកាលហ្នឹង ៣០០នាក់មកជួយស្ទូងស្រែ ខែដែលនេះហ្នឹង គឺការងារជាក់ស្ដែងគឺអ៊ីចឹង។

ហើយបន្ទាប់មកទៀត គឺថាខែប្រលងប្រណាំងៗ ពីអង្គាល់ហ្នឹងគេបើកយុទ្ធនាការខែប្រលងប្រណាំងបីខែ ប្រលងប្រណាំងហ្នឹង គឺថាបុគ្គលជាប់ហ្នឹង ហើយនិងមន្ទីរដែលអ្នកដែលជាប់ហ្នឹង គឺត្រូវទទួលរង្វាន់។ ទទួលរង្វាន់ហ្នឹង ពេលនុំង ខ្ញុំជាប់លេខមួយដែរ បុគ្គលខ្ញុំជាប់លេខមួយ។ មន្ទីររបស់ខ្ញុំក៏ជាប់លេខមួយដែរ។ អ៊ីចឹងគឺក្នុងរយៈកាលដែលប្រលងប្រណាំង អាហ្នឹងគឺថាក្នុងឆ្នាំ៦៩ ប្រលងប្រណាំងអ៊ីចឹង។ ចន្លោះហ្នឹង គឺដូចខ្ញុំរៀបរាប់អំមិញគឺថា ជានីរសារផង ធ្វើស្រែផង ហើយចន្លោះហ្នឹងគឺថា៦៩ហ្នឹង គឺអង្គាល់ហ្នឹងអាមេរិកាំងវាវាតត្បាតខ្លាំងណាស់ដល់រតនគិរី។ វាទម្លាក់គ្រាប់បែកផង ហើយវាចុះវាតត្បាតតាមភូមិឃុំក៏ច្រើនដែរអង្គាល់នុំង។ យើងនៅតែក្នុងព្រៃ។ ដល់អ៊ីចឹង វាក្នុងការរស់នៅវាចល័តចុះ ចល័តឡើង មានការលំបាកដែរក្នុងការចល័តចុះចល័តឡើង។ ហើយមន្ទីរតូចតាចហ្នឹងយើងចល័តចុះចល័តឡើង ដើម្បីចល័តកម្លាំងកុំឲ្យវាដឹង។ អានេះ ខ្ញុំចង់បញ្ជាក់ថា ចន្លោះហ្នឹងគឺជាការងារ គឺអ៊ីចឹង។

[១៥:០៩:៤៥]

ដល់១៨ មីនា ៧០ រដ្ឋប្រហារប្រិប អាហ្នឹងតំបន់រំដោះទូលាយតែម្តង គឺថា៥ខេត្ត គឺខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ព្រះវិហារ គឺក្រចេះ ទូលាយតែម្តង ១៨ មីនា៧០ រដ្ឋប្រហារប្រិប ហ្នឹងគឺសភាពការណ៍ល្អតែម្តង ល្អពេលហ្នឹង គឺយើងនៅក្នុងរតនគិរី យើងអាចចល័តទៅនេះ ចល័តទៅនោះស្រួលហើយ។ អ៊ីចឹងអាហ្នឹងខ្ញុំចង់បញ្ជាក់ពីការងារពេលគឺអ៊ីចឹង ប៉ុន្តែជាមូលដ្ឋានគឺយើងនៅក្នុងព្រៃ។ នៅក្នុងព្រៃនៅនុំង គឺថាប្រជាជនគាត់នៅក្នុងព្រៃដែរ យើងក៏នៅក្នុងព្រៃដែរ ពីព្រោះអាមេរិកាំងវាវាតត្បាតខ្លាំង អាហ្នឹងគឺមិនអាចនៅតាមភូមិបានទេ។ ហើយខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងទេ។

**សៈ** តើការងារលោកដែលជានីរសាររត់សំបុត្រហ្នឹង តើលោកធ្វើឲ្យទាំង អៀង សារី និង ប៉ុល ពត ឬក៏លោកធ្វើឲ្យអ្នកណាមួយ?

[១៥:១១:០៤]

**ឆៈ** គឺចល័ត ព្រោះគាត់នៅខាងជើងទន្លេសេសាន ហើយពួកខ្ញុំនែ៎នេះហ្នឹង គឺនៅជាប់សមរភូមិនោះ គឺខាងៗត្បូងទន្លេសេសាន ម្ខាងទន្លេម្នាក់។ ដូច្នេះគឺថា មុនដំបូងគាត់នៅខាងត្បូងទន្លេ ដល់ក្រោយមកទៀត វាវាតត្បាតខ្លាំង គាត់នៅខាងជើងទន្លេ។ ដល់អ៊ីចឹងចន្លោះហ្នឹង ត្រូវចល័តចុះចល័តឡើង។ ចល័តចុះឡើង។ ទៅឲ្យអ៊ំ អៀង សារី ផង ឲ្យអ៊ំ ប៉ុល ពត ផង ហើយមកៗនេះ មកបងៗតាមមូលដ្ឋានទៀត ដែលៗនៅរតនគិរីកម្មាភិបាលនៅច្រើនដែរកាលនុំង គឺបងៗដែលក្រោមឱវាទរបស់គាត់គ្រប់ហ្នឹង

គឺថាមានតាម គេហៅថាតាមមូលដ្ឋាន ដូចថានៅតាមបរកែវផង ខាងនែ៎ៗវ៉ឺនសៃផង ហើយខាងអណ្តូងមាសហ្នឹងផង គឺយើងចល័ត ហើយនៅក្នុងព្រៃ រត់ៗ ធ្វើការរបៀបអ៊ីចឹងបាទ។

**ស៖** បាទ អរគុណ។ តើលោកនៅចាំទេថាតើការដែលលោករត់សំបុត្រហ្នឹងយកពីលោក អៀង សារី និង ប៉ុល ពត ហ្នឹង តើលោកយកទៅឲ្យអ្នកណាខ្លះ? នៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំលើកឧទាហរណ៍អ៊ំមិញថា អ៊ំ អៀង សារី គាត់នៅខាងត្បូងទន្លេ ហើយអ៊ំ ប៉ុល ពត គាត់នៅខាងជើងទន្លេ ទៅយកសំបុត្រពីអ៊ំ អៀង សារី ទៅឲ្យគាត់ ហើយយកសំបុត្រពីគាត់មកឲ្យអ៊ំ អៀង សារី បាទ។

**ស៖** បាទ អរគុណ។ ចុះលោកដឹងដែរទេថា នៅពេលនោះលោក អៀង សារី គាត់មានតួនាទីធ្វើអីដែរ? គាត់មានមុខងារធ្វើអី? ហើយភារកិច្ចគាត់ធ្វើអី?

[១៥:១៣:២៦]

**ឆ៖** ភារកិច្ចពេលហ្នឹង គឺគាត់ថា គឺនៅនុ៎ង គឺនៅជាអចិន្ត្រៃយ៍ហ្នឹង មានតែ ប៉ុល ពត ហើយមានតែគាត់។ អ៊ីចឹងមានតែគាត់។ បើថាគាត់ទៅនៅខាងជើងហ្នឹង គឺពីរនាក់ គឺវាត្រូវឆ្លើយឆ្លងគ្នា គឺគាត់ -- កាលហ្នឹងគាត់ឧទ្ទេសនាមគាត់ថាគាត់ជា -- គាត់ទទួលខុសត្រូវក្នុងភូមិភាគឦសានហ្នឹង គាត់ទទួលខុសត្រូវរួមនៅហ្នឹង។ អ៊ីចឹងបានខ្ញុំនិយាយអំមិញថា គាត់បង្រៀនកម្មាភិបាលកាល៦៧ ហ្នឹង កម្មាភិបាលដែលតាំងពីមកពីស្រុកវ៉ឺនសៃផង ស្រុកបរកែវផង ស្រុកលំផាត់ផង កាលហ្នឹងរតនគិរីមានតែបីស្រុកទេ។ បីស្រុកៗហ្នឹងមកប្រមូលផ្តុំ គាត់បង្រៀន។ អ៊ីចឹងខ្ញុំឃើញសកម្មភាពៗជាក់ស្តែងរបស់គាត់ធ្វើការងារហ្នឹង ទាំងគាត់ ទាំងគ្រួសារគាត់ ព្រោះគាត់នៅជាប់ជាមួយគ្នាពេលនុ៎ង។

[១៥:១៤:៣៧]

**ស៖** បាទ អរគុណ។ ចុះលោកដឹងទេថាការងាររបស់ ប៉ុល ពត វិញ តើគាត់ធ្វើអីដែរនៅពេលនុ៎ង?

**ឆ៖** ការងារអ៊ំ ប៉ុល ពត ខ្ញុំឃើញជាក់ស្តែងហ្នឹង គឺថា គឺគាត់សរសេរៗ ជាឯកសារសរសេរជាសារហ្នឹង ប៉ុល ពត តែចេញពីគាត់ហ្នឹងបានចេញទៅតាមភូមិភាគផ្សេងៗហ្នឹង។ ដូចថាទៅខាងៗវ៉ឺនសៃ មានហ្នឹងទៅ ហើយមក បរកែវ ហើយមកលំផាត់ ឃើញសំបុត្រនេះចេញពីគាត់តែម្តង ចេញពីកន្លងគាត់ហ្នឹង ពីគាត់ហ្នឹង ឃើញៗគាត់ធ្វើការងារហ្នឹង។ ហើយបើ ពេលខ្លះគាត់អប់រំកម្មាភិបាលដែលនៅរតនគិរីហ្នឹង គឺតាំងពី កាលហ្នឹងយើងហៅតាំងតំបន់ តាំងពីស្រុកក៏អប់រំដែរ។

[១៥:១៦:០៣]

**ស៖** បាទ អរគុណ។ មុននេះលោកបានជម្រាបជូនអង្គសវនាការដែរថា មន្ទីររបស់ ប៉ុល ពត គឺឈ្មោះថាមន្ទីរ១០២ -- អឺ! ១០០ ហើយមន្ទីររបស់លោក អៀង សារី មានឈ្មោះថា មន្ទីរ១០២។ តើចម្ងាយពីមន្ទីរ១០០ ហើយនិង១០២ ហ្នឹងមានឆ្ងាយពីគ្នាដែរទេ?

**ឆ៖** មន្ទីរ ១០០ ហើយនិង១០២ ឆ្ងាយពីគ្នាប្រហែលជាបីគីឡូទេ មិនឆ្ងាយទេ។ ប៉ុន្តែក្នុងព្រៃយើងទៅយូរណាស់ណ៎ា បើថាបើនិយាយតែផ្ទៃដីហ្នឹងវាមិនឆ្ងាយទេ ប៉ុន្តែដល់ដើរជាក់ស្តែងវាយូរដែរណា ផ្លាប់ផ្លូវៗក្នុងព្រៃ។

**ស៖** បាទ អរគុណ។ លោកអាចជម្រាបជូនអង្គសវនាការបានទេថា ការយាមកាម ក៏ដូចជាការពារអីនៅមន្ទីរ១០០ និងមន្ទីរ១០២ ហ្នឹងគេធ្វើយ៉ាងម៉េចទៅ?

**ឆ៖** ពីរកន្លែងហ្នឹង គឺនែ៎ការពារ គេថានៅនុ៎ង គឺបងជនជាតិទាំងអស់តែម្តង នៅមន្ទីរទាំងពីរហ្នឹង គឺកម្លាំងតែ៦០នាក់ទេ។ មន្ទីរ១០០ ហ្នឹងក៏៣០នាក់ មន្ទីរ១០២ ហ្នឹងក៏៣០នាក់ដែរ។ គេនៅការពារកន្លែងហ្នឹង គេថា ម៉េចដែលគេហៅថា ការពារអ្នកដឹកនាំ។ ការពារអ្នកដឹកនាំ គឺថាមានក្នុងមានក្រៅ។ មានក្នុង គឺថាក្នុងហ្នឹងប្រហែលជាពីរគីឡូ ឬមួយគីឡូជាងពីមន្ទីរ។ ទៅក្នុងអ៊ីចឹង ប៉ុន្តែមន្ទីរផ្ទាល់អ៊ីចឹងយើងនៅជុំៗ រៀបចំជាបីមុំៗ ចង្ក្រាន។ អាហ្នឹងអ៊ីចឹង រៀបចំនៅអ៊ីចឹង។ អាហ្នឹង គឺថាបីហ្នឹង គាត់ណែនាំគាត់ថា យើងរក្សាការសម្ងាត់បាន យើងឈ្នះ៥០ភាគរយ បើយើងរក្សាការសម្ងាត់មិនបានទេ អាហ្នឹងយើងចាញ់គេហើយ។ អ៊ីចឹងក៏អនុវត្តតាមហ្នឹងទៅ។

[១៥:១៨:៤៧]

**ស៖** នៅអំឡុងពេលនុ៎ង តើលោកដែលពិនិត្យឃើញទេថា ទំនាក់ទំនងការងាររវាងលោក ប៉ុល ពត ហើយនិងលោក អៀង សារី ហ្នឹងមានភាពជិតស្និទ្ធយ៉ាងម៉េចដែរ?

**ឆ៖** ពិនិត្យជាក់ស្តែងទៅ គឺថាជិតស្និទ្ធ គឺថាស្និទ្ធស្នាលដូចជាមិត្តភក្តិ ដូចជាៗបងប្អូនអ៊ីចឹង។ នៅហ្នឹងគឺថាស្រឡាញ់គ្នាដូចជាបងប្អូនអ៊ីចឹង ស្រឡាញ់គ្នាក្នុងនាមជាមិត្តរួមតស៊ូជាមួយគ្នា ឃើញស្រឡាញ់ៗគ្នា អត់មានអីៗទៀត គឺថាគោរពគ្នាទៅវិញទៅមក ហើយស្រឡាញ់គ្នាទៅវិញទៅមក។ ហើយមានអីៗ ឃើញគាត់ចែកគ្នាហូបហ្នឹង គាត់ចែកគ្នាហូប ស្រឡាញ់ល្អតើ ឃើញគំរូល្អ យើងខាងក្រោមៗ យើងអ៊ីចឹងក៏ល្អដែរ ឃើញថាល្អដែរ គាត់ល្អអ៊ីចឹង។

[១៥:២០:០០]

**ស៖** បាទ អរគុណ។ ចុះនៅក្នុងអំឡុងពេលដែលនៅខេត្តរតនគិរី នៅមន្ទីរ -- នៅខេត្តរតនគិរីហ្នឹងតើ ប៉ុល ពត មានធ្លាប់ចេញទៅក្រៅប្រទេសអីទេ ពេលនុ៎ង?

**ឆ៖** ក្នុងឆ្នាំ -- ខ្ញុំមិនចាំដឹងជាឆ្នាំ -- ដើមឆ្នាំ៦៩ មិនមែនចុងឆ្នាំទេ គាត់ចេញដំណើរទៅក្រៅ ទៅវៀតណាម ហើយចេញពីវៀតណាមទៅប៉េកាំងនោះ។ អ៊ីចឹង អង្គាល់ហ្នឹងអ៊ំ អៀង សារី ទេ គាត់នៅប្រចាំការនោះ គាត់គ្រួសារគាត់ទៅៗក្រៅហ្នឹងហើយ។

**ស៖** តាមអ្វីដែលលោកបញ្ជាក់អម្បាញ់មិញថា អ៊ំ អៀង សារី គាត់នៅប្រចាំនៅនុ៎ង។ អ៊ីចឹងបានន័យថា នៅពេលដែល ប៉ុល ពត គាត់អត់នៅគឺលោក អៀង សារី គាត់ជាអ្នកទទួលបន្ទុកជំនួស ប៉ុល ពត តើអ៊ីចឹងមែនដែរទេ?

[១៥:២១:១០]

**ឆ៖** បាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំគិតថា យើងគួរតែសួរថា នៅពេលដែល ប៉ុល ពត មិននៅតើអ្នកណាគួរជាអ្នកទទួលខុសត្រូវ? ខ្ញុំគិតថា នេះជាបញ្ហាតូចតាច ប៉ុន្តែលោកខាងព្រះរាជអាជ្ញាមិនគួរទុកឲ្យមានបញ្ហានេះទេ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្តទៀតលោកតំណាងសហព្រះរាជអាជ្ញា!

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណ។

[១៥:២២:០០]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** មុននេះបន្តិចលោកបានជម្រាបជូនអង្គសវនាការដែរ ដែលទាក់ទងទៅនឹងការធ្វើស្រែ ហើយលោកក៏បានបញ្ជាក់ថា មានពេលនោះ មានកងទ័ពមកជួយធ្វើស្រែដែរ។ អ៊ីចឹងតើលោកដឹងទេថា កងទ័ពនៅពេលនោះគាត់មានភារកិច្ចធ្វើអ្វីខ្លះក្រៅពីមកជួយធ្វើស្រែហ្នឹង?

**លោក វ៉ាថាម គុន៖**

**ឆ៖** បាទ អង្កាល់ហ្នឹងក្នុងឆ្នាំ៦៨, ៦៩អី -- អង្កាល់ហ្នឹងឃើញជាក់ស្ដែង គឺថាមាន១ការវាតត្បាតរបស់ខ្មាំង ដល់អ៊ីចឹងគឺថាកម្លាំងហ្នឹងត្រូវតែទប់ទល់។ ទប់ទល់យ៉ាងម៉េច គឺថាដូចថានៅស្រុកបរកែវ គឺថាទីតាំងធំរបស់វា គឺពេលហ្នឹងគេនៅស្រុកបរកែវទេ។ អណ្ដូងមាសអត់មានទេ អាហ្នឹងគឺតំបន់រំដោះយើង។ ខាងវ៉ឺនសៃហ្នឹង វានៅទីរួមស្រុកវ៉ឺនសៃ តែនៅក្រៅពីហ្នឹងអត់មានទេ។ ហើយស្រុកលំផាត់ពេលនុ៎ងទីរួមស្រុកវានៅ ប៉ុន្តែក្រៅហ្នឹងអត់មានអីទៀតទេ។ ដូច្នេះយើងគឺថា ឃ្វាលកុំឲ្យវាចេញពីបន្ទាយរបស់វា ធ្វើម៉េចឲ្យវានៅនឹងកន្លែង។ កន្លែងខ្លះយើងអាចថា ផ្ដាច់ស្បៀងវាបាន យើងផ្ដាច់។ មិនឲ្យវាទាក់ទងគ្នា។ អាហ្នឹងគឺអ៊ីចឹង ពេលហ្នឹងគឺអ៊ីចឹង។

[១៥:២៤:០០]

មិនឲ្យវាពង្រីក គេហៅថា ពង្រីកទីតាំង វាពង្រីកបន្ទាយវាបាន គឺថាឲ្យវានៅក្ដោបនៅក្នុងបន្ទាយវានៅតូចប៉ុណ្ណឹងទៅ។ កងទ័ពពេលហ្នឹង ខ្ញុំចង់បញ្ជាក់ថា កងទ័ពពេលហ្នឹងគឺថា ពិតតែកម្លាំង ៣០០ មែន ប៉ុន្តែមិនមែនមកទាំងអស់ទេ។ មួយចំនួននៅយាមកាម ប្ដូរគ្នា មួយចំនួនមកជួយអ៊ីចឹង។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ តើនៅពេលនោះលោកដឹងទេថា នរណាគេជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងកងកម្លាំង -- កងទ័ពទាំងអស់ហ្នឹង?

**ឆ៖** នៅចុងៗ៦៨នេះ គឺថា សុន សេន ទៅដល់។ សុន សេន ទៅដល់ គឺថាការងារយោធាគឺ សុន សេន រៀបចំ គាត់អ្នករៀបចំ។ គាត់ហើយនិងគ្រួសារគាត់ គឺនៅជាមួយគ្នា គឺរៀបចំការងារហ្នឹង។

**ស៖** បាទ អរគុណ។ នៅក្នុងអំឡុងពេលពី៦៧ ដល់ឆ្នាំ១៩៧០ ហ្នឹង តើមានថ្នាក់ដឹកនាំណាផ្សេងទៀត ក្រៅពីអ្នកដែលលោកបានលើកមុននេះបន្តិចហ្នឹង មានដែរទេ រស់នៅកន្លែងនុ៎ង?

**ឆ៖** ដដែលហ្នឹង ដូចខ្ញុំបានបញ្ជាក់អម្បាញ់មិញហ្នឹងគឺថា ពី៦៧ នេះ មាន អ៊ំ អៀង សារី, មាន អ៊ំ ប៉ុល ពត គ្រួសារគាត់, អ៊ំ អៀង សារី គ្រួសារគាត់ ហើយនិងចុង៦៨ អ៊ំ សុន សេន ទៅដល់ៗ គាត់ទៅដល់។ កុយ ធួន ទៅដែរ ប៉ុន្តែចល័តទេ ចល័ត គាត់នៅប្រហែលបួនដប់ថ្ងៃ គាត់មកវិញ ហ្នឹង កុយ ធួន។ អ៊ំ នួន ជា ទៅដែរៗ ប៉ុន្តែចល័ត គាត់ភាគច្រើន គាត់មកក្រោមនេះ មកខាងក្រចេះនេះ ហ្នឹង អ៊ីចឹង។ នៅចន្លោះហ្នឹង គឺមានចេញចូលអ៊ីចឹង។

[១៥:២៦:២៨]

**សៈ** ចុះលោក នួន ជា គាត់ឧស្សាហ៍ទៅនុំងដែរទេ?

**ឆៈ** តាមខ្ញុំបានឃើញនេះ ខ្ញុំបានឃើញមែនទែន ខ្ញុំបានឃើញតែម្ដងទេ។ ម្ដងហ្នឹង កាលហ្នឹង ចុង៦៩ ហើយ។ គាត់ទៅប្រហែលមួយខែ្កតទេ ទៅប្រហែលបួនដប់ថ្ងៃ គាត់មកវិញ។

**សៈ** បាទ អរគុណ។ តើលោកនៅចាំទេថា លោក នួន ជា គាត់ទៅនុំងបួនដប់ថ្ងៃហ្នឹង គាត់ទៅធ្វើអី?

**ឆៈ** គាត់ជួបជុំគ្នាគាត់ គឺថាមានអ៊ំ ប៉ុល ពត ហ្នឹង, អ៊ំ អៀង សារី ហើយនិងអ៊ំ នួន ជា ហើយមាន កុយ ធួន ទៅជុំគ្នា ពេលហ្នឹងទៅជុំគ្នា។

**សៈ** តើលោកដឹងទេ ឬក៏នៅចាំដែរទេ ថាការដែលនៅទៅជុំគ្នាហ្នឹង គឺគេជុំគ្នាដើម្បីធ្វើអ្វីដែរ?

**ឆៈ** ល្អិត ខ្ញុំមិនបានៗដឹងទេ ប៉ុន្តែខ្ញុំឃើញគាត់ ក្រោយពីបានជួបជុំគ្នាអ៊ីចឹងហើយ ហើយត្រឡប់ទៅវិញរៀងខ្លួនហើយ ក្រោយពីហ្នឹងអ៊ំ ប៉ុល ពត គាត់ហៅពួកយើងដែលនៅជុំវិញហ្នឹងរៀន។ រៀន គាត់បញ្ជាក់ពីសភាពការណ៍ៗថា ក្នុងប្រទេស ខេត្តណាៗៗ វាៗមានសភាពការណ៍អ៊ីចេះៗៗ។ កម្លាំងរបស់យើងក៏ឧទ្ទេសទៅអ៊ីចេះៗៗ ឃើញគាត់ឧទ្ទេសនាម ក្រោយពីប្រជុំហ្នឹង គាត់ឧទ្ទេសនាម ប្រាប់ពួកយើងអ៊ីចឹង ដើម្បីឲ្យយើងយល់ពីសភាពការណ៍ ដើម្បីគឺថាបង្កើនសមត្ថភាពទទួលខុសត្រូវ ហើយនិងប្រយុទ្ធគ្រប់បែបយ៉ាងដើម្បីដល់ទិសដៅរបស់យើងដែលចង់បានបាទ។

[១៥:២៨:00]

**សៈ** បាទ អរគុណ។ ចុះលោកមានស្គាល់មនុស្សម្នាក់ឈ្មោះ ប៉ង់ ដែរទេ? ហើយ ប៉ង់ មានវត្តមានរតនគិរីដែរទេ អំឡុងពេលនុំង?

**ឆៈ** ប៉ង់ តាំងពីបានជួបអ៊ំ ប៉ុល ពត ពី៦៧ ខែ១២ ហ្នឹង ប៉ង់ គាត់ទៅដែរ គាត់នៅនុំងដែរ។

**សៈ** តើលោកដឹងទេថា ពេលនុំង ប៉ុង គាត់មានតួនាទីធ្វើអ្វី?

**ឆៈ** ប៉ង់ ពេលនុំងគឺថា នែ៎ឧបមាថាមន្ទីរ១០០ហ្នឹង អ៊ំ ប៉ុល ពត គាត់នៅហ្នឹង គឺ ប៉ង់ គាត់នៅហ្នឹង។ គឺ ប៉ង់ គាត់ទទួលខុសត្រូវ គឺថាកិច្ចការខាងរដ្ឋបាល ចាត់ចែងខាងក្រៅហ្នឹង គឺលើ ប៉ង់ ទាំងអស់។ ឧបមាថា ខាងស្រុកណា មកទាក់ទងយ៉ាងម៉េចៗ ហើយកម្លាំងកងទ័ព មកទាក់ទងយ៉ាងម៉េច គឺទាក់ទងមក ប៉ង់ ហ្នឹងឯង។ ប៉ង់ ចូលទៅជួបគាត់។ អាហ្នឹង ពេលហ្នឹងនែ៎ សុន សេន មិនទាន់មកដល់ទេ គឺ ប៉ង់ ហ្នឹងហើយ ដំណើរការនោះបាទ។

**សៈ** បាទ អរគុណ។ តើលោកដឹងទេ ថានៅខេត្តរតនគិរីហ្នឹង មានកន្លែង ដូចជាកន្លែងមន្ទីរ

សន្តិសុខអីដែរទេ?

**ឆ៖** ខ្ញុំពេលហ្នឹង ខ្ញុំអត់ដឹងទេ មន្ទីរសន្តិសុខអត់ដឹងទេ អត់ដឹងតែម្តង។

**ស៖** បាទ អរគុណ។ ចុះលោកនៅចាំទេថា ថ្នាក់ដឹកនាំបក្ស ដែលនៅខេត្តរតនគិរីហ្នឹង គាត់នៅខេត្តរតនគិរីហ្នឹងរហូតដល់ពេលណា? ហើយគាត់ចាកចេញទៅណាដែរ?

[១៥:៣១:៤៥]

**ឆ៖** នៅ -- អ្នកដឹកនាំនៅខេត្តរតនគិរីនេះ ដូចខ្ញុំរៀបរាប់អំមិញនេះ គឺថាមាន បងម៉ាន, មាន អ៊ំ អៀង សារី, មាន អ៊ំ ប៉ុល ពត ហើយបន្ទាប់ក្រោយមកទៀត មាន សុន សេន ជាគ្រួសារនោះ។ ប្អូនរូបនេះ គឺថានៅរតនគិរីនេះ គឺឃើញគាត់។ ខ្ញុំស្តាប់ច្រឡំសំណួរបន្តិច។

**ស៖** តើលោកចង់ឲ្យខ្ញុំបញ្ជាក់សំណួរឡើងវិញ ឬក៏មិនបាច់ទេ?

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មី ពីព្រោះគាត់ដូចជាភ្លេចសំណួរដែលលោកសួរហើយ។

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធាន។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** សំណួរខ្ញុំ គឺថាតើថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ដែលបោះទីតាំងនៅខេត្តរតនគិរីហ្នឹង គាត់នៅទីហ្នឹង រហូតដល់ពេលណា? ហើយនៅពេលដែលគាត់ចាកចេញ តើគាត់ចាកចេញទៅខាងណាដែរបាទ?

**លោក រ៉ចាម តុន៖**

**ឆ៖** បាទ ពីចុង ៦៩ នេះ អ៊ំ ប៉ុល ពត ហើយគ្រួសារគាត់ចេញទៅវៀតណាម ចេញទៅប៉េកាំង។ បងម៉ាន គាត់មកខេត្តព្រះវិហារ ហៅខេត្តព្រះវិហារ។ អង្គាល់នុ៎ង អ៊ំ អៀង សារី ក៏នៅប្រចាំការនៅហ្នឹង ហើយនិង សុន សេន និងគ្រួសារគាត់ នៅប្រចាំការហ្នឹងដែរ។ ប៉ុន្តែដល់ ៦៩ គាត់ទៅវៀតណាមហើយ គាត់ទៅប៉េកាំងហើយ ខែ៥ គាត់ -- អ៊ំ ប៉ុល ពត គាត់មកវិញ។ ខែ៥ ហ្នឹង ខ្ញុំទៅទទួលគាត់នៅកន្ទុយនាគហ្នឹង ហ្នឹងខែ៥។ ខែ៥ហ្នឹង។ ដល់ៗពេលហ្នឹង នៅរតនគិរីហ្នឹង គឺថា អ៊ំ អៀង សារី ហើយនិង សុន សេន នៅហ្នឹង។ ដល់ ប៉ុល ពត ចុះមកខែ៥ ឆ្នាំ៧០ មក ចុះមកៗនេះ ចុះមកខេត្ត

ខេត្តកំពង់ចាម។ នៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ អាហ្នឹង ខ្ញុំក៏មកដែរ មកជាមួយគ្នាហ្នឹង កាលទទួលគាត់ពីកន្ទុយនាគហ្នឹងមក។ អាហ្នឹង បានពួកខ្ញុំមានគ្នា៧០នាក់ កាលហ្នឹងនៅអមដំណើរគាត់មក។ ធ្វើដំណើរពីនោះ ពីកន្ទុយនាគមកដល់កំពង់ចាមនោះ ប្រាំពីរខែដើរបាទ។

**ស៖** បាទអរគុណ។ តើលោកមានបានដឹងដែរទេថា មូលហេតុអីបានជាមានការផ្លាស់ទីតាំងដូច្នេះ?

**ឆ៖** គាត់ប្រាប់ថា ឥឡូវហ្នឹងសភាពការណ៍ ថាប្រែប្រួលហើយ ប្រែប្រួលវិវត្តន៍កាន់តែល្អហើយ។ ដូច្នេះ យើងត្រូវធ្វើការងារនេះគឺថា តែបែងចែកកម្លាំងយើង។ កម្លាំងមួយចំនួនទៅខាងក្រៅដើម្បីរកមិត្តភក្តិខាងក្រៅ ដើម្បីជួយឧបត្ថម្ភចលនាយើង។ កម្លាំងមួយចំនួននៅក្នុងប្រទេសនេះ ដើម្បីដឹកនាំកម្លាំងក្នុងប្រទេស ទាំងយោធា ទាំងកម្លាំងប្រជាជននេះ គឺថាត្រូវដំណើរការ។ អ៊ីចឹងបានកាលហ្នឹងអ៊ំអៀង សារី នៅហ្នឹង សុន សេន ក៏នៅហ្នឹងដែរ។ ដល់ជាក់ស្តែង សុន សេន គាត់គ្រប់គ្រងខាងយោធា អៀង សារី គាត់គ្រប់គ្រងរួម ក្នុងខេត្តរតនគិរីហ្នឹង។ ហើយគាត់មកពីនោះហ្នឹង ឆ្នាំ៧០ ខែ៥ គាត់ចុះមក ធ្វើដំណើរមកដល់ក្រោមទៅ។

[១៥:៣៦:៣៤]

**ស៖** បាទ អរគុណ។ អម្បាញ់មិញលោកបានបញ្ជាក់ថា ការផ្លាស់ប្តូរទីតាំងពីខេត្តរតនគិរី គឺមកស្ទឹងត្រង់ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ដែរទេថា ស្ទឹងត្រង់ហ្នឹងនៅចំណុចណា ភូមិណា ឃុំណា?

**ឆ៖** ស្រុកស្ទឹងត្រង់ហ្នឹង គឺថា ត្រង់ហ្នឹងគេហៅ ភូមិត្រពាំងព្រៃ ភូមិត្បែង ភូមិត្រពាំងទឹម ភូមិបង្កីដង្រេន ហើយភូមិបឹង មួយជួរហ្នឹង។ ហើយគេហៅទួលសំបូរដែរ ក្នុងព្រៃហ្នឹង គេហៅ ទួលសំបូរ ចេញពីគីឡូ១៣ទៅនោះ ចាក់ទៅស្រុកព្រែកប្រសប់ ឆ្លាយទៅក្រចេះផ្លូវហ្នឹង។

**ស៖** បាទ អរគុណ។ តើទីតាំងទាំងអស់នោះ បើប្រៀបធៀបជាមួយនឹងកន្លែងមួយ ស្ទឹងមួយដែលហៅ ឈ្មោះថា ស្ទឹងជីនិត តើវានៅឆ្ងាយពីហ្នឹងដែរទេ ឬក៏ចម្ងាយជិតយ៉ាងណាដែរ?

**ឆ៖** បើយើងចេញពីមន្ទីរក្នុងព្រៃមក យើងត្រូវឆ្លងស្ទឹងជីនិតហ្នឹងហើយ បានមកដល់ភូមិគេហៅ ភូមិត្រពាំងទឹម អ៊ីចឹងបាទ។ មិនឆ្ងាយប៉ុន្មានទេ។

**ស៖** បាទ អរគុណ។ ចុះលោកនៅចាំដែរទេថា ទីតាំងថ្មី ដែលថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាមកបោះទីតាំងថ្មីនោះ តើទីតាំងថ្មីហ្នឹងមានឈ្មោះអី ឬក៏នៅតែឈ្មោះចាស់ដដែល?

**ឆ៖** កាលហ្នឹង គេថា មន្ទីរស-៧១។

**ស៖** បាទ អរគុណ។ តើលោកអាចជម្រាបជូនអង្គសវនាការបានទេថា មន្ទីរស-៧១ហ្នឹងមាន តួនាទីធ្វើអីដែរ?

[១៥:៣៩:០៨]

**ឆ៖** កន្លែងមន្ទីរនោះជាកន្លែងមន្ទីរសំខាន់ណាស់ ក្រោយពីរដ្ឋប្រហារមកគឺថា កន្លែងទីបញ្ជាការទូទាំងប្រទេសណ៎ា កន្លែងហ្នឹងហើយប្រមូលផ្តុំនៅកន្លែងហ្នឹង។ កម្មាភិបាលមជ្ឈិមទាំងអស់ប្រមូលផ្តុំនៅទាំងអស់ តំបន់ទាំងអស់ គណៈស្រុកទាំងអស់ ទៅរៀនសូត្រនៅកន្លែងហ្នឹងទាំងអស់។ ទីបញ្ជាការរួមចាប់តាំងពីរដ្ឋប្រហារមក គឺកន្លែងហ្នឹងហើយ។

**ស៖** បាទ អរគុណ។ ហើយចំពោះលោកផ្ទាល់ តើលោកឧស្សាហ៍ ជួបលោក ខៀវ សំផន ដែរទេ នៅក្នុងអំឡុងពេលនោះ?

**ឆ៖** នៅមន្ទីរហ្នឹងហើយដែរ ខ្ញុំជួបគាត់លើកទីមួយហើយ កន្លែងហ្នឹងជួបលើកទីមួយ។ តែពីមុនធ្លាប់ស្តាប់សំឡេងគាត់តាមវិទ្យុ ហើយតាមអ៊ំ ប៉ុល ពត គាត់ឧទ្ទេសនាមថាយើងទៅដល់ៗស្រុកស្ទឹងត្រង់ហ្នឹង ទៅដល់ខេត្តកំពង់ចាម យើងអាចមានគ្នាច្រើននៅកន្លែងហ្នឹង។ ហើយទៅដល់នុំងជួបគាត់តែ -- ជួបគាត់ គាត់មកលេងកន្លែងផ្ទះបាយរបស់ខ្ញុំខាងក្រៅហ្នឹង ហើយមានអីដូចជាបងប្អូនបង្កើតអ៊ីចឹងល្អកល្អើននៅក្នុងព្រៃ សប្បាយដែរ។ អ្នកដឹកនាំស្គាល់យើង យើងស្គាល់អ្នកដឹកនាំទៅ មានអីសប្បាយចិត្តៗ អត់មានព្រួយបារម្ភអីទេ គឺស្រួលតែម្តងអ៊ីចឹងបាទ។

**ស៖** ចុះលោកដឹងទេថា លោក ខៀវ សំផន គាត់មានតួនាទីធ្វើអ្វីដែរ?

[១៥:៤១:១៨]

**ឆ៖** ឃើញគាត់សរសេរ គាត់មានផ្ទះគាត់តូចមួយ គាត់មានតុមួយ គាត់សរសេរៗ។ មិនដឹងគាត់សរសេរអីខ្លះៗ ខ្ញុំមិនដឹងទេ ប៉ុន្តែឃើញគាត់អង្គុយសរសេរហ្នឹង មួយថ្ងៃៗគាត់សរសេរៗតែម្តង។ គាត់ពូកែខាងសរសេរណាស់ ព្រោះខាងខ្មែរយើងគាត់ចេះ ហើយបារាំងគាត់ចេះដែរណ៎ា គាត់សរសេរ។ សរសេរល្អណាស់។

**ស៖** តើលោកដឹងទេ ឬក៏លោក ខៀវ សំផន បានប្រាប់លោកដែរទេថាគាត់សរសេរហ្នឹង សរសេរពីអីគេ?

**ឆ៖** គាត់មិនបានប្រាប់ទេ ប៉ុន្តែឃើញ -- ដល់សរសេរទៅគាត់មានក្រុមរបស់គាត់ គឺថា

សរសេរក្រុមរបស់គាត់ហ្នឹង គឺសរសេរពី -- អង្កាល់ហ្នឹងគឺថាយើងគាត់ហៅថា “រណសិរ្សរួបរួមជាតិកម្ពុជា”។ បើគិតខាងកម្លាំងរណសិរ្សហ្នឹង គឺលើគាត់ទាំងស្រុងហើយ គាត់សរសេរជាភាសាខ្មែរ ជាភាសាបរទេសហ្នឹងលើគាត់ហើយ។

**ស៖** ចុះនៅពេលនុ៎ងលោកមានដឹងទេថា តើខ្លឹមសារសរសេរអំពី “រណសិរ្សរួបរួមជាតិកម្ពុជា” ហ្នឹងមានខ្លឹមសារយ៉ាងម៉េចខ្លះ លោកមានដឹងតាមរយៈ -- លោកដឹងដោយផ្ទាល់ ឬក៏តាមនរណា ប្រាប់ដែរទេ?

[១៥:៤៣:០៦]

**ឆ៖** ខ្ញុំឃើញហ្នឹង គឺកាលហ្នឹងគឺថា ផ្សាយតាមវិទ្យុក៏ស្តាប់ដែរ ហើយដល់ក្រោយមកទៀតក៏មានឯកសារគឺថា និយាយអំពីគឺថា “រណសិរ្សរួបរួមជាតិកម្ពុជា” ហ្នឹង ត្រូវប្រមូលកម្លាំងណាៗ គាត់សរសេរ ហ្នឹងក៏ឃើញជាមើលៗមិនមែនតែខ្ញុំ មើលទាំងអស់គ្នាហ្នឹង ទាំងក្នុងចំណោមក្រុមហ្នឹងគេមើលទាំងអស់គ្នា។ ហើយពេលខ្លះគាត់បង្រៀនដែរៗ បង្រៀន គឺថាកម្លាំងរណសិរ្សហ្នឹង ថាធ្វើម៉េចៗគាត់បង្រៀនដែរ ឲ្យយល់ពីកម្លាំងរណសិរ្សហ្នឹង។ សារៈសំខាន់អ្វីខ្លះ នៅក្នុងប្រទេសយ៉ាងម៉េចក្រៅប្រទេសយ៉ាងម៉េច គាត់បញ្ជាក់ច្បាស់ៗអ៊ីចឹង។

[១៥:៤៤:០៦]

**ស៖** បាទ អរគុណ។ ចុះលោកនៅចាំទេថាគាត់បង្រៀនហ្នឹង តើគាត់ពន្យល់ថាយ៉ាងម៉េចខ្លះទៅ? កម្លាំងរណសិរ្សក្រៅប្រទេសក្នុងប្រទេសហ្នឹង គាត់ពន្យល់ថាម៉េចខ្លះលោកមាននៅចាំបានទេ?

**ឆ៖** កម្លាំងរណសិរ្សហ្នឹង តាមខ្ញុំចាំហ្នឹងគឺថា ទីមួយ គឺថាត្រូវប្រមូលកម្លាំងបញ្ញវន្តទាំងអស់ បញ្ញាជន បញ្ញវន្តហ្នឹងជាមួយគ្នាហ្នឹង គឺត្រូវប្រមូលទាំងអស់ ប្រមូលកម្លាំងហ្នឹង។ ហើយបន្ទាប់មកទៀត ត្រូវប្រមូលកម្លាំង គឺថាកម្លាំងក្នុងប្រទេសយើង គឺកម្លាំងជាតិទាំងមូលហ្នឹង គឺខ្លះហ្នឹង កាលហ្នឹងគេបែងចែកវណ្ណៈខ្លះ អ្នកខ្លះនុ៎ងគេថា នេះក៏យើងប្រមូលទាំងអស់ យើងធ្វើជារណសិរ្សដើម្បីប្រមូលកម្លាំងឲ្យធំទូលាយក្នុងប្រទេស។ កម្លាំងហ្នឹង គឺមិន -- យើងមិនសំដៅតែកម្មករ កសិករមួយមុខទេ គឺទាល់តែប្រមូលកម្លាំងរណសិរ្សហ្នឹងឲ្យធំទូលាយក្នុងប្រទេសហ្នឹង។ គាត់បញ្ជាក់ឲ្យច្បាស់ៗអ៊ីចឹង គាត់ថា “យើងមិនត្រូវរឿងឆ្ងល់អីទេអាហ្នឹង គឺថាកម្លាំងជាតិយើងទាំងមូល គឺថាទាល់ប្រមូលផ្តុំទាំងអស់ហ្នឹងបាន វាទៅជាកម្លាំងសាមគ្គីជាតិទាំងមូលវាល្អ ហើយវាមានកម្លាំងខ្លាំងក្លាទាំងក្នុងប្រទេសផង សម្រាប់ក្រៅប្រទេសផង” បាទ។

[១៥:៤៥:៥៤]

**ស៖** បាទ អរគុណ។ ចុះអម្បាញ់មិញលោកបានបញ្ជាក់ថា ពេលនុ៎ងលោក ខៀវ សំផន បានបង្រៀនថាមានការបែងចែកវណ្ណៈខ្លះ។ តើបែងចែកវណ្ណៈខ្លះនុ៎ង វណ្ណៈ បែងចែកយ៉ាងម៉េចទៅ? លោកអាចបញ្ជាក់បានទេ?

**ឆ៖** អង្កាល់ហ្នឹង--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប ចាំស្ដាប់សេចក្ដីជំទាស់ពីមេធាវី ខៀវ សំផន ជាមុនសិន។ សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ អម្បាញ់មិញនេះ តាមខ្ញុំស្ដាប់សម្ដីរបស់សាក្សី គាត់អត់បានឆ្លើយថា លោក ខៀវ សំផន បញ្ជាក់ពីការបែងចែកវណ្ណៈខ្លះនោះទេ គឺគាត់និយាយអំពីការរួបរួមគ្នានៃវណ្ណៈទាំងអស់របស់កម្ពុជា។ ដូច្នេះ នៅពេលដែលសហព្រះរាជអាជ្ញាលើកសំណួរនេះ វាទៅជាបង្វែរឲ្យសាក្សីយល់ច្រឡំ ហើយឆ្លើយខុសពីការពិតបាទ។ សូមអរគុណ។ សូមជំទាស់នឹងសំណួរនេះ។

[១៥:៤៧:០៤]

**លោក សេង ប៊ុនឃាង៖**

បាទ សូមអរគុណលោកប្រធាន។ សាក្សីពិតជាបានឆ្លើយថា ខៀវ សំផន បានបង្រៀនអំពីការប្រមូលកម្លាំងទាក់ទងទៅនឹងវណសិរ្ស ហើយច្បាស់ណាស់ លោកមេធាវីក៏អាចបើកមើលក្នុងប្រតិចារឹកថា គាត់បានលើកឡើងអំពីការបែងចែកវណ្ណៈខ្លះ។ នេះគឺជាការពិតដែលមាន -- ដែលសាក្សីបានឆ្លើយ។ ហើយដើម្បីបញ្ជាក់ឲ្យច្បាស់លាស់ សូមអនុញ្ញាតពីលោកប្រធានដើម្បីសួរទៅសាក្សីទៅលើបញ្ហានេះបាទ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក សេង ប៊ុនឃាង៖**

បាទ អរគុណលោកប្រធាន។

[១៥:៤៧:៤៩]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** លោកសាក្សីដូចដែលលោកមេធាវីការពារអម្បាញ់មិញ បានឡើងមកជំទាស់ថា លោកមិនបាននិយាយអំពីការបង្រៀនរបស់លោក ខៀវ សំផន ថាមានការបែងចែកវណ្ណៈទេ។ តើជាការត្រឹមត្រូវដែរទេ?

**លោក វ៉ាចាម គុន៖**

**ឆ៖** អម្បាញ់មិញខ្ញុំបាននិយាយាថា ការបង្រៀនរបស់គាត់ គឺថា គឺពាក្យថា រណសិរ្សហ្នឹង គឺថាប្រមូលកម្លាំងទាំងក្នុងប្រទេស និងក្រៅប្រទេស។ ហើយកម្លាំងក្នុងប្រទេសហ្នឹង គឺវាមានការបែងចែកជាវណ្ណៈណា វាមាន មិនមែនតែវណ្ណៈកម្មករ កសិករទេ គឺមិនមែនកម្លាំងពីរទេ កម្លាំងក្រៅពីហ្នឹងប្រមូលទាំងអស់ អ៊ីចឹងណា។ អាហ្នឹងខ្ញុំៗលើកឡើងអ៊ីចឹងបាទ។ គឺវាអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់របស់មេធាវីការពារក្ដីឲ្យលោក ខៀវ សំផន គ្មានប្រសិទ្ធភាពទេ។ សាក្សីឆ្លើយនឹងសំណួរចុងក្រោយរបស់លោកតំណាងសហព្រះរាជអាជ្ញា ប្រសិនបើលោកនៅចងចាំ។ បើអត់ទេតំណាងសហព្រះរាជអាជ្ញាតាំងសំណួរជាថ្មី ដើម្បីឲ្យគាត់ចងចាំនូវសំណួរ ក្ដាប់បាននូវសំណួរដែលលោកសួរ បំណងឲ្យគាត់ឆ្លើយ។

[១៥:៤៩:១៧]

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** បាទ ដើម្បីឲ្យមានភាពឆាប់របាស់នោះ ខ្ញុំនឹងសួរសំណួរនេះជាថ្មីឡើងវិញតែម្ដងទៅ។ សំណួរសួរថា តើការបង្រៀនរបស់លោក ខៀវ សំផន អំពីការបែងចែកវណ្ណៈនោះ តើការបែងចែកវណ្ណៈហ្នឹង គាត់បានលើកឡើងពីអ្វីខ្លះ?

**លោក វ៉ាចាម គុន៖**

**ឆ៖** ខ្ញុំដឹងតែរួមៗ ដូចខ្ញុំបញ្ជាក់អម្បាញ់មិញហ្នឹង ខ្ញុំថា ប្រមូលកម្លាំងទាំងក្នុងប្រទេស ទាំងក្រៅប្រទេស យើងមិនមែនតែនែ -- មិនមែនតែយកវណ្ណៈពីដូចថា កម្មករ កសិករទេ ក្រៅពីកម្មករកសិករប្រមូលទាំងអស់ ដើម្បីឲ្យបានកម្លាំងនេះវាធំទូលាយសម្រាប់ជាតិយើងទាំងមូល។

**ស៖** បាទ អរគុណ។ សំណួរជាបន្តទៅទៀត ចង់ដឹងថានៅអំឡុងពេលដែលធ្វើដំណើរផ្លាស់ទីពីខេត្តរតនគិរីនៅឆ្នាំ១៩៧០ តើពេលនុំងលោក អៀង សារី គាត់បានចូលរួមដំណើរជាមួយថ្នាក់ដឹកនាំបក្ស

ក្នុងការផ្លាស់ទីនេះដែរទេ?

**ឆ៖** លោក អៀង សារី អត់បានមកចូលរួមទេ ព្រោះគាត់នៅប្រចាំនៅខេត្តរតនគិរីដដែល។

**ស៖** បាទ អរគុណ។ ចុះលោកដឹងទេថា លោក អៀង សារី គាត់នៅប្រចាំនៅខេត្តរតនគិរីហ្នឹង រហូតដល់ពេលណាដែរ?

[១៥:៥១:២០]

**ឆ៖** តាមៗខ្ញុំចាំគឺថា គាត់នៅក្នុងខេត្តរតនគិរីហ្នឹង គឺថាដូចជាដើមឆ្នាំ៧១ គាត់ទៅវៀតណាម គាត់ទៅប៉េកាំងដែរ។ ហ្នឹងគាត់ទៅនុ៎ង។ ហើយពេលនុ៎ង សុន សេន ក៏គាត់ចុះមកដែរ ចុះមកៗនេះ ប្រចាំនៅខេត្តកំពង់ធំ សុន សេន ចុះមកដែរ។ អត់មានអ្នកណានៅទេរតនគិរី មានតែថ្នាក់ភាគទេនៅរតនគិរីពេលនុ៎ង។

**ស៖** អ៊ីចឹងតើ អៀង សារី ដែលគាត់ទៅប៉េកាំង តើគាត់ទៅប៉េកាំងរហូតដល់ពេលណាដែរ?

**ឆ៖** គាត់ទៅប៉េកាំងហ្នឹងចាប់ពីដើមឆ្នាំ៧១ ហ្នឹង រហូតដល់រំដោះ១៧ មេសា ៧៥ ហ្នឹងបានគាត់មកដល់ប្រទេសវិញ។

**ស៖** បាទ អរគុណ។ តើលោកដឹងដែរទេ ថានៅពេលដែលលោក អៀង សារី នៅប៉េកាំងហ្នឹង គាត់មានតួនាទីធ្វើអ្វីនៅទីនោះ?

[១៥:៥២:៥៨]

**ឆ៖** ខ្ញុំមិនបានដឹងថា ផ្ទាល់តាមរយៈប្រជុំអីទេ ប៉ុន្តែខ្ញុំដឹងតាមរយៈថា ន៏ផ្សាយវិទ្យុ។ គាត់គឺថា បេសកជនពិសេសរបស់ចលនាតស៊ូដើម្បីទៅអមសម្តេចឪ នៅប៉េកាំងនុ៎ង ដើម្បីធ្វើការងារទូតនៅខាងក្រៅ។

**ស៖** ចុះលោកនៅមានចាំបានទេថា ការផ្សាយវិទ្យុដែលបញ្ជាក់ថា លោក អៀង សារី ធ្វើជាបេសកជនពិសេស ដើម្បីធ្វើការងារទូតនៅខាងក្រៅនោះ តើគាត់ធ្វើអ្វីខ្លះដែរ? លោកមានដឹងទេ ឬក៏ចាំបានទេការផ្សព្វផ្សាយនុ៎ង?

**ឆ៖** អង្កាល់នុ៎ងខ្ញុំស្តាប់វិទ្យុប៉េកាំងទេ ប្រកាសថា គេថាគាត់គឺជាបេសកជនពិសេសរបស់ចលនាតស៊ូ ដើម្បីទៅអមសម្តេចឪនៅប៉េកាំងហ្នឹង គឺគេប្រកាសអ៊ីចឹង។ គឺស្តាប់បានតាមវិទ្យុអ៊ីចឹង។ វិទ្យុប៉េកាំងប្រកាសតែម្តង ដើមឆ្នាំ៧១ហ្នឹង។

[១៥:៥៤:២០]

**ស៖** បាទ អរគុណ។ ចុះចំពោះរូបលោកផ្ទាល់ នៅអំឡុងពេលដែលនៅមន្ទីរស-៧១ ហ្នឹង តើពេលនុ៎ងលោកមានតួនាទីធ្វើអ្វីដែរ?

**ឆ៖** ខ្ញុំពេលនោះ នៅមន្ទីរស-៧១ ហ្នឹងគឺ ខ្ញុំនៅក្នុងកងការពារៗមន្ទីរហ្នឹង នៅក្នុងកងការពារហ្នឹង។ ហើយខ្ញុំជនចល័តទេ ខ្ញុំមែនទែន ខ្ញុំជិះម៉ូតូ ចួនអីមកភូមិភាគ ចួនណាខ្ញុំមកមន្ទីរភូមិភាគនិរតីនេះ មន្ទីរភូមិភាគបូព៌ា មន្ទីរភូមិភាគ៣០៤នេះ ខ្ញុំច្រើនចល័តអីចឹង។ បាននៅមន្ទីរគឺថា កម្លាំងការពារនៅហ្នឹង នៅមន្ទីហ្នឹង កាលធ្វើនៅមន្ទីរហ្នឹង។

**ស៖** ចុះទាក់ទងនឹងការងារចល័តរបស់លោកហ្នឹង តើលោកទៅជាមួយអ្នកណាដែរពេលនុ៎ង?

**ឆ៖** ខ្ញុំទៅម្នាក់ឯង គឺថាភារកិច្ចខ្ញុំនាំសារ គឺថាខ្ញុំមានម៉ូតូសេអិលមួយ កាំភ្លើងខ្លីមួយដើម អាកាបត់មួយដើម នាំសំបុត្រស្នាមទៅភូមិភាគនេះ ទៅភូមិភាគនោះ។

**ស៖** តើការនាំសំបុត្រស្នាមរបស់លោកទៅភូមិភាគនេះ ទៅភូមិភាគនោះហ្នឹង តើអ្នកណាជាអ្នកឲ្យលោកយកសំបុត្រស្នាមនោះទៅ?

**ឆ៖** សំបុត្រហ្នឹង គឺថាចាត់ចែងបន្ទាប់ហ្នឹងគឺថា កាលណោះ ខ្ញុំ គេហៅ បងប៉ង់ៗ។ បងប៉ង់ហ្នឹង គាត់ចាត់ចែង។ ថាយកសំបុត្រទៅនេះ យកសំបុត្រទៅនោះ គាត់ចាត់ចែង។

[១៥:៥៦:៤៥]

**ស៖** អីចឹងដើម្បីឲ្យប្រាកដ តើកាលនុ៎ងលោកធ្វើជាអ្នកយកសំបុត្រ ឬក៏ជាអ្នករត់សំបុត្រហ្នឹងឲ្យថ្នាក់ដឹកនាំណាមួយដែរ មានកំណត់ច្បាស់ទេ អំពីតួនាទីរបស់លោកពេលនោះ?

**ឆ៖** ពេលនោះគឺថា សំបុត្រមួយជូនភូមិភាគ២០៣ ហ្នឹងគឺថា លោកតា សោ ភឹម យកទៅឲ្យគាត់ ហើយភូមិភាគ៣០៤ ហ្នឹងឲ្យទៅបង កុយ ធួន។ បើមកភូមិភាគនិរតីនេះ គឺយកមកឲ្យ តាម៉ុក។

**ស៖** អីចេះ -- បាទអរគុណ។ សំណួរខ្ញុំសួរចង់ដឹងអីចេះថា កាលដែលលោកជាអ្នករត់សំបុត្រយកទៅឲ្យភូមិភាគនេះ ភូមិភាគនោះហ្នឹង តើការងាររបស់លោកហ្នឹង លោកធ្វើឲ្យអ្នកណាដែរ ថ្នាក់ដឹកនាំប្រទេសមួយណាដែរ?

**ឆ៖** ខ្ញុំធ្វើឲ្យក្រុមដឹកនាំហ្នឹងហើយ។ ធ្វើឲ្យអ៊ំ ប៉ុល ពត ហ្នឹងហើយ នៅជំនាន់ -- កាលនៅជាមួយ គាត់ហ្នឹង បម្រើគាត់ គាត់ប្រើអី ធ្វើហ្នឹងហើយ។

**ស៖** បាទ អរគុណ។ ចុះលោក ប៉ុល ពត គាត់ដែលចេញទៅតាមភូមិភាគ ដូចដែលលោកទៅដែរទេ?

**ឆ៖** គាត់ទៅតើ ២០៣ ក៏គាត់ទៅ។ ៣០៤ ក៏គាត់ទៅ។ នៅភូមិភាគនិរតីក៏គាត់ទៅ។

**ស៖** តើលោកចាំទេ ថាការដែលលោក ប៉ុល ពត ទៅតាមភូមិភាគ តាមអីហ្នឹង តើគាត់ទៅធ្វើអ្វីដែរ?

**ឆ៖** ទៅជាមួយគាត់ហ្នឹង ទៅដល់អាកន្លែងមន្ទីររបស់ភូមិភាគហ្នឹង។ ទីមួយ ជួបគណៈភូមិភាគហ្នឹង ជំហានទីមួយ។ ជំហានទីពីរ ឃើញអញ្ជើញគណៈតំបន់គណៈស្រុកហ្នឹងមកធ្វើការ ខ្ញុំឃើញធ្វើតែអ៊ីចឹង។

[១៥:៥៩:៣០]

**ស៖** ចុះលោកមានដឹងទេ ថាការអញ្ជើញភូមិភាគ គណៈស្រុក គណៈអីមកធ្វើការ តើធ្វើការអ្វីដែរ?

**ឆ៖** តាមរយៈដែលខ្ញុំ ខ្ញុំយាមទេ កាលណាគាត់ធ្វើការកន្លែងណា ខ្ញុំយាមកន្លែងហ្នឹង។ ឲ្យយាមនោះគឺថា ធ្វើការ គឺថាទីមួយ ដូចខ្ញុំបានបញ្ជាក់ដែលគាត់បង្រៀនអ៊ីចឹង។ ទីមួយ គាត់ឧទ្ទេសនាមសភាពការណ៍រួមដែរ ក្នុងប្រទេសនិងក្រៅប្រទេស។ ហើយធ្វើជាទស្សនៈបដិវត្តន៍ ហើយបានលើកវិធានការតទៅទៀត។ ធ្វើដូចគ្នាទេ។ ធ្វើតែធ្វើភូមិភាគក៏អ៊ីចឹងដែរ។ ធ្វើតំបន់ក៏អ៊ីចឹង ធ្វើនៅស្រុកក៏ធ្វើអ៊ីចឹងដែរ ធ្វើដូចគ្នា។ ប៉ុន្តែគ្រាន់យើងលម្អិតតាមនែ ចំណុចខ្លាំងអីរបស់ខេត្តហ្នឹង ចំណុចខ្លាំងអីរបស់តំបន់ហ្នឹង ចំណុចខ្លាំងអីរបស់ស្រុកហ្នឹង ចំណុចខ្សោយអី ហើយត្រូវកែលម្អយ៉ាងម៉េច? គាត់ណែនាំច្បាស់ៗ ហើយគេស្តាប់បាន ហើយគេបានធ្វើបានល្អដែរ អ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ អរគុណសាក្សី។ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលសមល្មមសម្រាកហើយដែរ។ អង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក គឺថ្ងៃព្រហស្បតិ៍ ទី២៦ ខែកក្កដា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាសការនៅថ្ងៃស្អែកនេះនឹងបន្តធ្វើដោយការតាំងសំណួរដេញដោលចំពោះសាក្សី រ៉ចាម តុន ដោយសហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញាជាបន្ត។ ហើយសូមភាគី និងសាធារណជនជ្រាប។

[១៦:០១:២៣]

លោក រ៉ចាម តុន ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះត្រូវ

បន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្ម។ ហើយមេធាវីប្រឹក្សាសាក្សីដូចគ្នា។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញចុះ ហើយនិងឲ្យនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

ដោយឡែកលោក អៀង សារី ក្នុងករណីដែលមានពាក្យសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការ ដូចដែលគាត់បានធ្វើកន្លងមកនេះ បើសិនជាមានករណីនេះកើតឡើង សូមទំនាក់ទំនងជាមួយនឹងក្រឡាបញ្ជីសវនាការ ដើម្បីទទួលព័ត៌មាន ហើយឲ្យរក្សាទុកគាត់នៅបន្ទប់ឃុំខ្លួនដែលមានរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ អង្គជំនុំជម្រះនឹងពិនិត្យពិចារណាសម្រេចលើសំណើសុំរបស់គាត់ឲ្យបានមុនពេលដំណើរការពិភាក្សាដេញដោលស្តាប់សក្ខីកម្មសាក្សី។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣នាទី)*